**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# វិធានការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **វណ្ណ សុខនាង**
**អ៊ុច ច័ន្ទវាសនា**

សាស្ត្រាចារ្យណែនាំ
លោក **ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវសារណាខ្ញុំបាទ ដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី ១៩ មហាវិទ្យាល័យនីតិសាស្ត្រ ដែលមានសមាជិកពីររូបគឺ៖

**១.លោក វណ្ណា សុខនាង**

**២.លោក អ៊ូច ច័ន្ទវាសនា**

## សូមគោរពជូនចំពោះ

លោកឪពុក អ្នកម្ដាយ ដែលជាអ្នកមានគុណដ៏លើសលុប ដោយលោកទាំងពីរបាន ផ្ដល់កំណើត លះបង់អស់នូវកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ នូវចិត្តសន្ដោសប្រណីក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងជួយឧបត្ថម្ភគ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈតាំងពីកូននៅកុមារភាព រហូតដល់កូនទាំងអស់គ្នាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកទាំងពីរខិតខំធ្វើការដោយមិនគិតពីការនឿយហត់របស់លោកទាំងទ្វេឡើយ។

គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលនេះធ្វើឱ្យកូនៗទាំងពីរចងចាំ និងមិនអាចបំភ្លេចបាននូវការលះបង់របស់លោកមានគុណទាំងពីរដែលជាម្លប់ដ៏ប្រពៃហើយ និងជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់កូនៗគ្រប់រូបមានទំហំធំធេងគ្មានអ្វីប្រៀបផ្ទឹមបានឡើយ។ ទាំងអស់នេះដែលស្ថិតក្នុងការចងចាំរបស់កូនៗជានិច្ច និងគ្មានថ្ងៃបំភ្លេចបានដែលស្ថិតក្នុងដួងព្រលឹងកូនៗជាដរាបគ្មានថ្ងៃសាបសូន្យឡើយ។

លោក លុយ ចណ្ណា សាកលវិទ្យាធិការ និងលោកសាកលវិទ្យាធិការរង រួមទាំងគណៈគ្រប់គ្រង សាស្ត្រាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីររូបបានចូលសិក្សានៅសាកលវិទ្យាល័យនេះ ហើយថែមទាំងយកចិត្តទុកដាក់ ខិតខំអប់រំ និងពង្រឹងវិន័យសកលវិទ្យាល័យតាំងពីចូលរៀនរហូតមកដល់ការសរសេរនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ដោយសារតែទីកន្លែងនេះហើយជាថ្នាលបណ្ដុះបណ្ដាលឱ្យយើងទាំងពីររូបបានសិក្សាស្វែងយល់នូវទិដ្ឋភាពគ្រប់យ៉ាងដែលមានទាំង ទិដ្ឋភាពផ្នែកទ្រឹស្ដី និងទិដ្ឋភាពផ្នែកសង្គម ហើយធ្វើឱ្យយើងខ្ញុំទាំងពីររូបបានក្លាយជានិសិត្សល្អ មិត្តភក្ដិល្អនិងពលរដ្ឋល្អក្នុងសង្គមជាតិ។

សូមថ្លែងអំណរគុណជូនចំពោះលោក ញឹក វុទ្ធី ប្រធានការិយាល័យសិក្សាស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបុគ្គលិកទាំងអស់ដែលបានជួយសម្របសម្រួលបែបបទរដ្ឋបាល និងជួយសម្រួលកិច្ចការផ្សេងៗនៃកិច្ចការស្រាវជ្រាវសារណានេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកសាស្ត្រាចារ្យ ហោ សុភ័ណ្ឌ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកផ្ទាល់ក្នុងការ ដឹកនាំសរសេរសារណា ដោយលោកបានផ្តល់អនុសាសន៍ល្អៗ និងចំណេះដឹងបន្ថែមប្រកបដោយបទពិសោធន៍ ថែមទាំងជួលកែសម្រួលនូវចំណុចមួយចំនួនលើខ្លឹមសារនៃសារណានេះ យ៉ាងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ដោយមិនគិតពីការនឿយហត់ ដោយក្នុងគោលបំណងដើម្បីឱ្យកើតឡើងជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យ ហើយក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ ជួន ប៊ុនធី ដែលបានផ្តល់នូវដំបូន្មានដើម្បីលម្អនូវចំណុចខ្វះខាតក្នុងសារណាដល់ខ្ញុំបាទទាំងពីរ។

ជាចុងក្រោយខ្ញុំបាទទាំងពីរ សូមប្រសិទ្ធិពរជ័យសិរីបវរជូនដល់លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់សូមសមប្រកបតែនឹងព្រះពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឃ្លៀតឡើយ។

# អារម្ភកថា

ដោយបានធ្វើការឆ្លងកាត់ការសិក្សារអស់រយៈពេល០២ឆ្នាំរួចមក ទៅលើមុខជំនាញថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សង្កេតឃើញថា ចំពោះការសិក្សាក្នុងអំឡុងឆ្នាំទី០៣ និងឆ្នាំទី០៤ ធ្វើអោយខ្ញុំបាទទាំងពីរបានសិក្សាស្វែងយល់ច្រើនទៅលើផ្នែកនីតិវិធីព្រហ្មទណ្ឌ ដែលជាប្រតិបត្តិការនៃការដំណើរការរឿងក្តីដោយតុលាការព្រហ្មទណ្ឌ។ ដើម្បីជាកិច្ចក្នុងការបញ្ចប់ឆ្នាំសិក្សានេះដែរ បានធ្វើអោយខ្ញុំបាទទាំងពីរ ក៏បានសម្រេចចិត្តលើកយកនូវប្រធានបទមួយ ដែលធ្លាប់បានសិក្សាកន្លងមក ដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីលើកយកមកចងក្រងធ្វើជាសារណាក្នុងការបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។ មិនត្រឹមតែប៉ុណ្ណោះដោយមានការឆ្លងកាត់ការពិចារណាក៏ដូចជាការណែនាំពីលោកគ្រូជាសាស្ត្រាចារ្យ ជាអ្នកទទួលបន្ទុកក្នុងការដឹកនាំការសរសេរសារណាទើបធ្វើឱ្យខ្ញុំបាទទាំងពីរ បានជ្រើសរើសលើកយកនូវប្រធានបទមួយគឺ "វិធានការស្រាវជ្រាវបទល្មើសដោយចៅក្រមស៊ើបសួរ"។

ក្នុងការជ្រើសរើសប្រធានបទនេះដែរ ជាប្រធានបទមួយដែលត្រូវបានលើកយកមកបកស្រាយ ដោយសូមដោយយកបកស្រាយតែមួយចំណុចនៃកិច្ចដំណើរការរបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ដោយហេតុឃើញថាមានការសិក្សាស្រាវជ្រាវច្រើន ក៏ដូចជាការសរសេរសារណាច្រើន ចំពោះប្រធានបទដែលទាក់ទងទៅនឹងចៅក្រមក្រមស៊ើបសួរ ដោយក្នុងនោះទៀតសោតពុំសូវមានការសរសេរអោយបានច្បាស់លាស់ ក៏ដូចជាស៊ីជម្រៅទៅលើវិធានការស្រាវជ្រាវបទល្មើសដោយចៅក្រមស៊ើបសួរទេ។ ដោយសារតែមានភាពខ្វះខាត ក៏ដូចជាការខ្វះចន្លោះនេះហើយទើបជម្រុញអោយយើងខ្ញុំសម្រេចចិត្តរៀបចំតាក់តែងនូវ ប្រធានបទមួយនេះធ្វើជាសារណាដើម្បីឱ្យមានលក្ខណល្អប្រសើរ ច្បាស់លាស់ និងស៊ីជម្រៅទៅលើប្រធានបទនេះអោយងាយស្រួលយល់ ថែមទាំងទំនើបជាងមុនផងដែរ។

ជាចុងក្រោយខ្ញុំបាទទាំងពីរសង្ឃឹមថា គ្រប់កិច្ចការស្រាវជ្រាវ រួមទាំងឯកសារយោងដែលយកមកតាំងបង្ហាញក្នុងស្នាដៃនេះ ដោយគ្រាន់តែមានគោលបំណងសិក្សាតែប៉ុណ្ណោះ បើមានកំហុសខុសឆ្គងណាសូមខណ្ឌីអភ័យទោស និងជូនកែលម្អក្នុងស្នាដៃសារណានេះ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី១
## មូលដ្ឋានគ្រឹះនៃការស៊ើបសួរ

**ផ្នែកទី១ ទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរ** ........................ ៤

**កថាខណ្ឌទី១ សញ្ញាណទូទៅចៅក្រមស៊ើបសួរ** ........................................ ៥

១.តើចៅក្រមស៊ើបសួរជាអ្នកណា? ........................................................ ៥

២. គោលបំណងនៃការបង្កើត ................................................................ ៦

**កថាខណ្ឌទី២ នាពដែលអាចបំពេញមុខការបាន** ........................................ ៧

១. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ........................................................ ៧

២. វិសមតិភាពមុខងារ ........................................................................ ៨

**កថាខណ្ឌទី៣ ទម្រង់ការដាច់ខាតដែលត្រូវគោរព** ...................................... ៩

១. ការសម្ងាត់នៃការស៊ើបសួរ ................................................................ ៩

២. ការធ្វើកំណត់ហេតុដែលធ្វើជាលាយលក្ខណ៍អក្សរ .................................. ១០

**ផ្នែកទី២ ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**.១១

**កថាខណ្ឌទី១ ការដាក់ពាក្យប្តឹង** ........................................................ ១២

១.បណ្តឹងបរិហារ ............................................................................ ១២

២. ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........................ ១៦

**កថាខណ្ឌទី២ អធិបញ្ជារបស់នាយចំនានុក្រម** ........................................ ២១

១. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ .................................................... ២២

២. រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ................................................................ ២២

**កថាខណ្ឌទី៣ ការស្នើសុំដោយយុត្តាធិការព្រហ្មទណ្ឌ** .................................. ២៣

១. ការស្នើសុំឱ្យស៊ើបសួរបន្ថែមដោយចៅក្រមស៊ើបសួរ ................................ ២៣

២. ការបញ្ជូនរឿងឱ្យស៊ើបសួរដោយចៅក្រមជំនុំជម្រះ .................................. ២៤

## ជំពូកទី២
## អំណាចសំខាន់ៗលើការស្រាវជាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

**ផ្នែកទី១ អំណាចស្រាវជ្រាវដោយខ្លួនឯងផ្ទាល់** ........................................ ២៦

**កថាខណ្ឌទី១ អង្គហេតុដែលមានសញ្ញាណធាតុផ្សំបទល្មើស** ........ ២៦
១. អង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ២៨
២. អង្គហេតុគ្មានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ៣៤
**កថាខណ្ឌទី២ អង្គហេតុមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី** ........ ៣៦
១. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ........ ៣៧
២. ករណីមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវបណ្ដឹង ........ ៤០
**ផ្នែកទី២ អំណាចស្រាវជ្រាវតាមដីកាចាត់ឱ្យស៊ើបសួរជំនួស** ........ ៤២
**កថាខណ្ឌទី១ ការចាត់តាំងចៅក្រមផ្សេងឱ្យស៊ើបសួរជំនួស** ........ ៤២
១. ការចាត់តាំងចៅក្រមនៅសាលាដំបូងដែលមានសមត្ថកិច្ច ........ ៤៣
២ . ការចាត់តាំងចៅក្រមសាលាដំបូងផ្សេងទៀត ........ ៤៤
**កថាខណ្ឌទី២ ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យស៊ើបសួរជំនួស** ........ ៤៥
១. ការចាត់តាំងមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌ ........ ៤៥
២. ប្រតិបត្តិការតាមការចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ........ ៤៦
**ផ្នែកទី៣ អំណាចស្រាវជ្រាវតាមការស្នើសុំ** ........ ៤៧
**កថាខណ្ឌទី១ ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា** ........ ៤៧
១. លក្ខខណ្ឌក្នុងការស្នើសុំ ........ ៤៨
២. ការប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចបដិសេធ ........ ៤៨
**កថាខណ្ឌទី២ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ** ........ ៤៩
១. លក្ខខណ្ឌក្នុងការស្នើសុំ ........ ៤៩
២. ការប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចបដិសេធ ........ ៥០
**កថាខណ្ឌទី ៣ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី** ........ ៥១
១. លក្ខខណ្ឌក្នុងការស្នើសុំ ........ ៥១
២. ការប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចបដិសេធ ........ ៥១
**សេចក្ដីសន្និដ្ឋាន** ........ ៥៣
**ឯកសារយោង** ........ ៥៤
**អនុសាសន៍**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាយើង គឺបានកំណត់អំពីបែបបទ និងរបៀបរបបដើម្បីធ្វើចំណាត់ការបណ្តឹងជាបទល្មើសព្រហ្មទណ្ឌណាមួយ។ នៅពេលដែលមានបណ្តឹងដាក់មកកាន់ស្ថាប័នតុលាការនៅសាលាជម្រះក្តីជាន់ទាប ដែលមានសាលាដំបូងរាជធានី-ខេត្ត ជាស្ថាប័នដំបូងដែលទទួលគ្រប់ពាក្យបណ្តឹងទាំងឡាយ ដែលជាជំហានក្នុងការការដំណើរបណ្តឹង និងទាមទារឱ្យតុលាការចេញសាលក្រម ទោះជាបណ្តឹងនោះត្រូវបានធ្វើឡើងដោយបុគ្គល ដែលជាជនរងគ្រោះក្តីដោយតតិយជនក្តី ឬមន្ត្រីនគរបាលយុត្តិធម៌ក្តី។ ក្នុងនោះដែរ គេឃើញថាចំពោះក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ក៏បានស្តែងបង្ហាញឱ្យឃើញនៅដំណាក់កាលដាច់ដោយឡែកពីគ្នា ដែលមានដំណាក់កាលស៊ើបអង្កេតដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលនៃការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការចោទប្រកាន់ធ្វើឡើងដោយព្រះរាជអាជ្ញា និងដំណាក់ការចុងក្រោយ គឺដំណាក់កាលជំនុំជម្រះរហូតដល់ការប្រកាសសាលក្រម។

ដោយពិនិត្យទៅលើដំណាក់កាលទាំងអស់ខាងលើនេះ អាចបង្ហាញឱ្យឃើញដែរថាដំណាក់កាលចៅក្រមស៊ើបសួរនេះ គឺជាដំណាក់កាលមួយ ដែលស្ថិតនៅកណ្តាលនៃកិច្ចនីតិវិធីរវាងមន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការ ហើយជាដំណាក់កាលនៃនីតិវិធីថ្មីផងដែរ។ មុននឹងឈានដល់ការបើកការស៊ើបសួរនេះទៀតសោតគឺថាលុះត្រាតែព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការបើកកាស៊ើបសួររបស់ចៅក្រមស៊ើបសួរ ជាកិច្ចនីតិវិធីសំខាន់ណាស់ដែលទាក់ទងទៅនិងការស្វែងរកនូវភាពពិតនៃអង្គហេតុ ដែលបង្ហាញអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសទៅលើបុគ្គល ដែលចោទប្រកាន់ដោយព្រះរាជអាជ្ញាតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងនោះផងដែរចៅក្រមស៊ើបសួរមានកាតព្វកិច្ចស្វែងរកភស្តុតាងទាំងដោះបន្ទុក និងដាក់បន្ទុក។ អំណាចរបស់ចៅក្រមស៊ើបសួរដែលបានផ្តល់ដោយក្រមនីតីវិធីព្រហ្មទណ្ឌ ដែលមានអំណាចក្នុងការស្រាវជ្រាវបទល្មើស និងបង្ហាញនូវការពិតនៃរឿងហេតុដែលទាក់ទិននឹងបទល្មើស ដែលតំណាងអយ្យការបានប្តឹងមកខ្លួនរួមទាំងវិធានមួយចំនួនដែលផ្តល់ឱ្យចៅក្រមដោយភ្ជាប់ជាមួយនឹងមុខងាររបស់ចៅក្រមស៊ើបសួរផងដែរ ម្យ៉ាងទៀតក៏ផ្តល់សិទ្ធិសំណាចចៅក្រមស៊ើបសួរ ក្នុងការឃុំខ្លួន និងដាក់ទណ្ឌកម្មទៅលើជនត្រូវចោទផងដែលដោយជាអំណាចផ្តល់ដោយវិធានការនិរន្តរាយរួមមាន ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន និងការត្រួតពិនិត្យតាមផ្លូវតុលាការ។ ដោយសារតែយើងមិនធ្វើការបកស្រាយទៅលើដំណាក់កាលទាំងអស់ ដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌទេ គឺយើងធ្វើការ

ពន្យល់ និងបកស្រាយត្រឹមតែដំណាក់កាលនៃវិធានការមួយ ដែលជាកិច្ចការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរក្នុងទំហំនៃប្រធានបទខាងលើគឺ "វិធានការស្រាវជ្រាវបទល្មើសដោយចៅក្រមស៊ើបសួរ" យកមកធ្វើការបកស្រាយតែប៉ុណ្ណោះ។

ការស្រាវជ្រាវនេះគឺមានគោលបំណងដើម្បីបង្ហាញឱ្យឃើញកាន់តែច្បាស់ និងកាន់តែស៊ីជម្រៅទៅលើតួនាទីនិង ភារកិច្ចរបស់ចៅក្រមស៊ើបសួរក្នុងការប្រើប្រាស់វិធានការស្រាវជ្រាវបទល្មើសនេះដើម្បីស្វែងរកការពិតនៅក្នុងអង្គហេតុ។ ទាំងនេះដែលយើងនឹង ធ្វើការបកស្រាយថាចៅក្រមស៊ើបសួរមានវិធានអ្វីខ្លះទៅលើការស្វែងរកនូវការពិតនោះ ដែលរួមមាន ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ការឆែកឆេរ ការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ និងការស្តាប់ទូរស័ព្ទជាអាទ៍ ដែលសុទ្ធសឹងតែជាវិធាន ដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងតឹងរឹងក្នុងការប្រើប្រាស់វិធានការនីមួយៗនេះផងដែរ។

លទ្ធផលនៃការស្រាវជ្រាវមួយនេះ និងរំពឹងថាអាចចងក្រងធ្វើជាសៀវភៅក៏ដូចជាឯកសារក្នុងបណ្ណាល័យច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដើម្បីជាការរក្សាទុកជាទស្សនទានជាគំនិតជូនប្អូនៗជំនាន់ក្រោយក្នុងការបំពេញនូវចំណេះដឹង ក្នុងនាមជាអ្នកកំពុងអនុវត្តផ្នែកទ្រឹស្តីដោយផ្សារភ្ជាប់ជាមួយគ្នាទៅនិងការអនុវត្តជាក់ស្តែង លើក្រមនីតិវិធីព្រហ្មទណ្ឌចំពោះផ្នែកចៅក្រមស៊ើបសួរ ទៅលើដំណើរការនៃការប្រព្រឹត្តនៅក្នុងសាលាដំបូងនីមួយៗ ជាជំនួយដល់ការស្វែងរកការពិតដែលនឹងមានរៀបរាប់ នៅក្នុងសារណានេះចាប់តាំងពីកិច្ចដំបូងនៃការប្រើវិធានការស្រាវជ្រាវបទល្មើសរហូតដល់កិច្ចបញ្ចប់។

មុននឹងចាប់ផ្តើម តើចៅក្រមស៊ើបសួរត្រូវធ្វើកិច្ចណាខ្លះ? ក្នុងអំឡុងពេលស្រាវជ្រាវត្រូវធ្វើដូចម្តេចខ្លះ?

បន្ទាប់មកនឹងមានឯកសារជារូបរាងយ៉ាងដូចម្តេច ហើយនឹងបន្តទៅណាទៀតរហូតដល់ពេលបញ្ចប់កិច្ចការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ។

ដើម្បីធ្វើការបកស្រាយទៅលើប្រធានបទ "អំណាចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ" នេះឱ្យកាន់តែស៊ីជម្រៅនិង ការបន្ថែមឱ្យយល់កាន់តែច្បាស់នោះយើងបានធ្វើការបែងចែកជាពីរជំពូករួមមាន៖

**ជំពូកទី១ មូលដ្ឋានគ្រឹះនៃការស៊ើបសួរ**

**ជំពូកទី២ វិធានការសំខាន់ៗនៃការស្រាវជ្រាវដោយចៅក្រមស៊ើបសួរ**

# ជំពូកទី១
# មូលដ្ឋានគ្រឹះនៃការស៊ើបសួរ

ដើម្បីជាភាពងាយស្រួលដល់អ្នកសិក្សា ក៏ដូចជាធ្វើការស្វែងយល់ពីអំណាចរបស់ចៅក្រម ដែលមានក្នុងកិច្ចនីតិវិធីស្រាវជ្រាវស្វែងរកបទល្មើសនេះឱ្យកាន់តែច្បាស់ គឺគប្បីយល់ដឹងផងដែរថា ចៅក្រមដែលអាចបើកកិច្ចស៊ើបសួរនេះបាន គាត់ជាចៅក្រមអាសនៈដែលស្ថិតក្នុងយុត្តាធិការស៊ើបសួរ។ បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានរំលេចយ៉ាងលម្អិតអំពីមូលដ្ឋានគ្រឹះរបស់ចៅក្រមស៊ើបសួរក្នុងកិច្ចស៊ើបសួរនេះផងដែរ។ ដោយសារតែក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជាបទប្បញ្ញត្តិដែលចែងពីកិច្ចនីតិវិធី ដើម្បីធ្វើយ៉ាងណាឱ្យមានប្រសិទ្ធិភាពក្នុងការស្វែងរកបទល្មើស ឬភាពពិតក្នុងអង្គហេតុជារឿងព្រហ្មទណ្ឌ។ នៅពេលដែលមានបទល្មើសមួយត្រូវបានលេចឡើងនោះ ប្រាកដណាស់ គេសង្កេតឃើញថាតែងមានវត្តមានរបស់នគរបាលយុត្តិធម៌ ការធ្វើការចោទប្រកាន់របស់អយ្យការ ក៏ដូចជាការស៊ើបសួរដែលច្បាប់តម្រូវដែលមានចៅក្រមស៊ើបសួរ ដើម្បីធ្វើកិច្ចស៊ើបសួរនេះ ដែលអមដោយមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ជាសេនាធិការ។ បើពិនិត្យទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ បានឱ្យដឹងថាការស៊ើបសួរនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ គឺជាដំណាក់កាលមួយ ដែលស្ថិតនៅចន្លោះកណ្តាលនៃដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការ ហើយដំណាក់កាលស៊ើបសួរនេះ គឺបានផ្តល់នូវសិទ្ធិដល់ចៅក្រមស៊ើបសួរយ៉ាងធំធេង និងឯករាជ្យចំពោះការស្វែងរកការពិតនៃអង្គហេតុ និងរកភស្តុតាងទៅលើភាពសមហេតុសមផលទាំងដាក់បន្ទុក និងដោះបន្ទុកផងដែរ។[1]

ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយ ដោយអាចធ្វើការចោទជាសំណួរបានថា "តើទំនាក់ទំនងអ្វីខ្លះដែលធ្វើឱ្យចៅក្រមស៊ើបសួរ ត្រូវមានអំណាចក្នុងការបើកការស៊ើបសួរ?" តាមរយៈការចោទសួរនេះ នឹងធ្វើការបកស្រាយ ក៏ដូចជាបង្ហាញជូននៅក្នុងផ្នែកខាងក្រោមនេះ។

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១២៧។

## ផ្នែកទី១ ទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរ

ចំពោះទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរនេះដែរ នឹងបង្ហាញឱ្យកាន់តែច្បាស់ថា ចៅក្រមស៊ើបសួរជាតួអង្គសំខាន់ដែលមានភារៈកិច្ច ក៏ដូចជាសិទ្ធិអំណាចក្នុងកិច្ចដំណើរការបើកការស៊ើបសួរនេះ។ ត្រង់ចំណុចនេះមានន័យថា មានតែចៅក្រមដែលស្ថិតនៅក្នុងយុត្តាធិការស៊ើបសួរប៉ុណ្ណោះ ទើបមានសមត្ថកិច្ចក្នុងការដំណើរការ ក៏ដូចជាប្រតិបត្តិនូវនីតិវិធីស៊ើបសួរនេះបាន ដោយអំណាចនេះត្រូវផ្តល់ឱ្យចៅក្រមស៊ើបសួរដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ និយាយមកវិញ ដោយអាចនិយាយបានថាទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងការស៊ើបសួរនេះគឺជាទំនាក់ទំនងមួយដែលមិនអាចកាត់ផ្តាច់គ្នាបាន។ ជាមូលដ្ឋាននៃការស៊ើបសួរ ចៅក្រមស៊ើបសួរគាត់អាចបើកការស៊ើបសួរតាមរយៈពីររបៀបគឺ តាមការប្តឹងសុំបើកការស៊ើបសួរពីព្រះរាជអាជ្ញា **(ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)**[2] ប្រសិនបើបទល្មើសជាបទល្មើសឧក្រិដ្ឋ បទមជ្ឈិម[3] និងម្យ៉ាងទៀត ចៅក្រមស៊ើបសួរក៏អាចបើកការស៊ើបសួរបានផងដែរ ក្រោយតែពីព្រះរាជអាជ្ញាដែលតំណាងឱ្យផលប្រយោជន៍សង្គមធ្វើការតម្កល់រឿងទុលឥតចាត់ការ[4] នោះក៏អាចឱ្យភាគីខ្លួនឯងផ្ទាល់អាចធ្វើការប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បើកការស៊ើបសួរបានផងដែរ តាមរយៈការប្តឹងសុំពីដើមបណ្តឹងរដ្ឋប្បវេណីឬជនរងគ្រោះបាន **(ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍នៅមុខចៅក្រមស៊ើបសួរ)**[5] គឺមានន័យថាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺអាចធ្វើបាននៅពេលដែលមានការបើកការស៊ើបសួរហើយ ឬម្យ៉ាងទៀត ក៏អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានផងដែរនៅពេលដែលពុំទាន់មានចំណាត់ការបើកការស៊ើបសួរ។

ចំពោះការបើកការស៊ើបសួរ គឺវាជាសមត្ថកិច្ចផ្តាច់មុខរបស់ចៅក្រមស៊ើបសួរ ហើយនៅក្នុងវិធានការនៃកិច្ចបើកការស៊ើបសួរនេះ គឺជាអំណាចរបស់ចៅក្រមស៊ើបសួរ ដោយតែងតែមានការប៉ះពាល់ដល់ប្រយោជន៍មួយចំនួនទៅលើជនជាប់ចោទ ដែលជាការបំពានទៅលើសិទ្ធិបុគ្គលផងដែរ។ ការប៉ះពាល់ទាំងនេះ ដែលចេញមកពីវិធានការស៊ើបសួរ ដោយទាមទារចាំបាច់ឱ្យចៅក្រមស៊ើបសួរត្រូវប្រើប្រាស់នូវវិធានការនិរន្តរាយ **(ជាអំណាចបង្ខំ)** ឬការប្រើប្រាស់នូវវិធានការស្រាវជ្រាវបទល្មើស **(ដែលប៉ះពាល់ទៅលើសិទ្ធិឯកជន)**។ យ៉ាងណាមិញ បើក្រឡេកពិចារណាឡើងវិញ យើងអាចចោទ

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៤៤ កថាខណ្ឌទី២។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១២២។

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៤១។

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៥ កថាខណ្ឌទី១។

ជាសំណួរបានថា តើចៅក្រមស៊ើបសួរជាអ្នកណា? ហើយបែបបទនៃការចាត់តាំងនៃការស៊ើបសួរមានដំណើរការយ៉ាងដូចម្តេច? ហើយតើការបង្កើតឱ្យមានចៅក្រមស៊ើបសួរនេះក្នុងគោលបំណងអ្វី?

**កថាខណ្ឌទី១ សញ្ញាណទូទៅចៅក្រមស៊ើបសួរ**

នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានស្ថាប័នតុលាការ ដែលបម្រើឱ្យពលរដ្ឋក្នុងការស្វែងរកយុត្តិធម៌ដែលមាននៅតាមមូលដ្ឋាន ដោយនៅគ្រប់រាជធានី-ខេត្ត មានត្រូវបានបែងចែកជាសាលាដំបូងរាជធានី-ខេត្ត។ ចំពោះអ្នកដែលមានអំណាចក្នុងការសម្រេចសេចក្តី ឬហៅថាជាចៅក្រមនោះគឺត្រូវបានបែងចែកជាពីរដាច់ដោយឡែករួមមាន ចៅក្រមអសនៈ និងចៅក្រមអយ្យការ។ ក្នុងនោះផងដែរ ចំពោះចៅក្រមអសនៈក៏ត្រូវបានចែងមុខងារជាពីរ គឺជាតួអង្គដែលមានទាំងចៅក្រមជំនុំជម្រះ និងចៅក្រមស៊ើបសួរ។ ដោយតួអង្គទាំងពីរនេះស្ថិតនៅក្នុងស្ថាប័នយុត្តាធិការជំនុំជម្រះ និងយុត្តាធិការស៊ើបសួរ។ ដោយឡែកចៅក្រមអយ្យការវិញ គឺស្ថិតនៅក្នុងស្ថាប័នអយ្យការដែលនៅអមសាលាដំបូងរាជធានី-ខេត្ត ដែលមានតួអង្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងជាអ្នកទាមទារឱ្យតុលាការអនុវត្តច្បាប់ និងតំណាងឱ្យផលប្រយោជន៍សាធារណៈក្នុងសង្គម។

**១.តើចៅក្រមស៊ើបសួរជាអ្នកណា?**

ចៅក្រមស៊ើបសួរមានអត្ថន័យថា សំដៅលើចៅក្រមដែលមានតួនាទីស្វែងរកនូវភស្តុតាងដើម្បីសម្តែងឱ្យឃើញនូវភាពពិត និងផ្តល់យុត្តិធម៌ទៅឱ្យគូភាគីដែលគាត់មានអំណាចបើកស៊ើបសួរបានគឺតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់របស់ព្រះរាជអាជ្ញា ឬតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរ គឺជាចៅក្រមអសនៈដែលបំពេញមុខងារស៊ើបសួរនៅតាមបណ្តាលសាលាដំបូងដែលហៅថាមន្ទីរស៊ើបសួរ ឬនៅសាលាឧទ្ធរណ៍ជាតុលាការជាន់ខ្ពស់ ហៅថាសភាស៊ើបសួរ។[6]

នៅក្នុងសាលាដំបូងរាជធានី-ខេត្ត ចៅក្រមស៊ើបសួរ គឺចាំបាច់ត្រូវបានចាត់តាំងដោយប្រធានតុលាការ។ នៅក្នុងនោះការបំពេញភារកិច្ច ក៏ដូចជាតួនាទីនៃការស៊ើបសួរ គឺចៅក្រមស៊ើបសួរទាំងនោះ អាចបំពេញមុខងារជំនួសគ្នាបាន ប្រសិនបើមានចៅក្រមស៊ើបសួរណាម្នាក់មិនអាចបំពេញមុខងាររបស់ខ្លួនបានដោយសារមូលហេតុនៃជំងឺ ឬបញ្ហាផ្សេងៗទៀត ក្នុងនោះដែរការចាត់តាំងចៅក្រមជំនួសនេះមិនមែនមានតែចៅក្រមស៊ើបសួរទេ ដែលអាចបំពេញមុខងារជំនួសនេះ គឺក៏អាចចាត់តាំងចៅក្រមផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។[7]

---

[6] ឯកសារជំនួយស្មារតីការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ កើត រិទ្ធ។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា៥១។

### ២. គោលបំណងនៃការបង្កើត

ការយល់ដឹងពីគោលបំណងក្នុងការបង្កើតនេះជារឿងសំខាន់ ព្រោះប្រវត្តិសាស្ត្រ ធ្វើឱ្យយើងស្គាល់ខ្លួនឯង ស្គាល់ពីព្រឹត្តិការណ៍ពីអតីតកាល ក៏ដូចជាបុព្វបទសង្គមពីអតីតកាល ហើយបន្សល់ទុកដល់បច្ចុប្បន្ន។ ហើយចំពោះការដែលបង្កើតឱ្យមានប្រព័ន្ធចៅក្រមស៊ើបសួរនេះក៏មិនខុសគ្នាទៅនឹងការសិក្សាប្រវត្តិសាស្ត្រដែរ ចំពោះកម្ពុជាចាប់តាំងពីសម័យកាលមុនរហូតដល់ពេលបច្ចុប្បន្ននេះ តើប្រព័ន្ធស៊ើបសួរកកើតឡើងដោយសារអ្វី? ជាចម្លើយ ប្រព័ន្ធចៅក្រមស៊ើបសួរកម្ពុជា គឺបង្កើតឡើងដោយសារតែកម្ពុជាពីអតីតកាលស្ថិតក្រោមរបបអាណានិគមនិយមបារាំង ដោយពេលនោះកម្ពុជាក៏បានទទួលឥទ្ធិពលទាំងស្រុងពីក្រមពិភាក្សាព្រហ្មទណ្ឌបារាំងឆ្នាំ ១៨០៨ និងក្រមនីតិវិធីព្រហ្មទណ្ឌបារាំងក្រោយៗមកទៀត។ ហេតុដូចនេះ ការឈ្វេងយល់ពីគោលគំនិតដើមនៃប្រព័ន្ធចៅក្រមរបស់កម្ពុជា គឺត្រូវពឹងពាក់អាស្រ័យជាសំខាន់ទៅលើវិធានគតិយុត្តរបស់បារាំង។ ក្រៅពីច្បាប់បារាំង នៅមានសេចក្តីសម្រេចរបស់សាលាក្តីខ្មែរក្រហមក៏ជាវិភាគទានមួយធំធេង ក្នុងការសិក្សាឈ្វេងយល់អំពីប្រព័ន្ធស៊ើបសួរ បើទោះបីសាលាក្តីកូនកាត់មួយនេះ បានធ្វើឱ្យប្រព័ន្ធចៅក្រមស៊ើបសួរមានដំណើរការក៏ដោយ ក៏នៅមាននីតិវិធីមួយចំនួនមិនត្រូវគន្លងខ្លះក៏ដោយសារវត្តមានច្បាប់អន្តរជាតិ និងអ្នកច្បាប់មកពីបណ្តាប្រទេសដែលមិនប្រើប្រាស់ប្រព័ន្ធចៅក្រមស៊ើបសួរ។[8]

គោលបំណងក្នុងការបង្កើតឱ្យមានចៅក្រមស៊ើបសួរនេះ គឺដើម្បីជួយសម្រួលទៅលើវិស័យយុត្តិធម៌ក្នុងការស្វែងរកនូវភស្តុតាងទៅលើអង្គហេតុមួយដើម្បីបញ្ជាក់ពីភាពពិត ឬជាការស្វែងរកនូវអត្ថិភាព ឬនត្ថិភាពនៃបទល្មើសទៅលើបុគ្គលដែលបានប្រព្រឹត្តពិតប្រាកដដើម្បីជៀសវាងការមានការសង្ស័យការខ្វះខាតទៅលើបន្ទុក នៃភស្តុតាងដែលបានបញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌មក មុននឹងបញ្ជូនទៅយុត្តាធិការជំនុំជម្រះ។ ម្យ៉ាងវិញទៀតក្នុងការស្វែងរកការពិតនេះចៅក្រមស៊ើបសួរត្រូវមានករណីយកិច្ចស៊ើបសួរទាំងភស្តុងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ វត្តមានរបស់ចៅក្រមស៊ើបសួរពិតជាមានសារៈសំខាន់ណាស់ ក្នុងការដំណើរការរឿងក្តីព្រហ្មទណ្ឌដែលច្បាប់បានកំណត់ត្រូវមានការបើកការស៊ើបសួរ[9] គឺចៅក្រមស៊ើបសួរបំពេញកិច្ចនៃការបើកការស៊ើបសួរ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ចៅក្រមស៊ើបសួរក្នុងពេលដំណើរការរឿងក្តីរបស់ខ្លួន គឺត្រូវតែមានភាពយុត្តិធម៌ និងឈរនៅកណ្តាលគ្រប់ភាគីដែលពាក់ព័ន្ធនៃរឿងក្តីព្រហ្មទណ្ឌ។ ម្យ៉ាងទៀតស្របនឹងគោលបំណងដែលបង្កើតឱ្យមានប្រព័ន្ធចៅក្រមស៊ើបសួរនេះដែរ គឺសម្រាប់ស្វែងរកភស្តុតាងមក

[8] ចក សម្បត្តិ, «ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ៖ ខ្លឹមសារនៃប្រព័ន្ធចៅក្រមស៊ើបសួរ», *ការផ្សព្វផ្សាយរបស់សមាគមសាលាត្រជូ*, ខែវិច្ឆិកា ឆ្នាំ២០១៧, < http://salatraju.com/post/332 >, ២ ខែមិថុនា ឆ្នាំ២០១៩។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២២។

បញ្ជាក់ថាការប្តឹងសុំបើកការស៊ើបសួរដែលតំណាងអយ្យការបានចោទប្រកាន់នោះ វាគឺជាបទល្មើសព្រហ្មទណ្ឌ ឬមិនមែនជាបទល្មើសព្រហ្មទណ្ឌ។

**កថាខណ្ឌទី២ ភាពដែលអាចបំពេញមុខការបាន**

បន្ទាប់ពីបានដឹងពីសញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួររួចមក គឺគប្បីដឹងផងដែរពីមុខការរបស់គាត់វិញម្តង។ នៅក្នុងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានកំណត់អំពីមុខការរបស់ចៅក្រមស៊ើបសួរ ក្នុងការបំពេញភារកិច្ចស៊ើបសួរនេះដែរ គឺចៅក្រមស៊ើបសួរអាចបំពេញមុខការរបស់ខ្លួនដោយសន្មតទៅលើ សមត្ថកិច្ចដែលខ្លួនមាន **(សមត្ថកិច្ចដែនដី និងសមត្ថកិច្ចសម្ភារៈ)**។ មួយវិញទៀតចៅក្រមដែលមានតួនាទីក្នុងការស៊ើបសួរហើយនោះ គឺមិនអាចចាត់តាំងជាចៅក្រមជំនុំជម្រះទៀតឡើយ **(វិសមតិភាពមុខងារ)** ។

**១. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ**

នៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនេះ ត្រូវបានបែងចែកជាពីរគឺៈ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមដែនដី និងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមសម្ភារៈ។

**១.១. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរតាមដែនដី**

ចៅក្រមដែលមានសមត្ថកិច្ចគឺ[10] ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។

វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល។ ការសម្រេចនេះបិទផ្លូវតវ៉ា។ បទប្បញ្ញត្តិនេះចែងអំពីសមត្ថកិច្ចដែលចៅក្រមស៊ើបសួរមានសមត្ថកិច្ច ហើយនឹងកំណត់អំពីបញ្ហាក្នុងការដោះស្រាយ នៅពេលដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនទៅលើបណ្តឹងតែមួយក៏ដូចជាវិវាទចំពោះសមត្ថកិច្ចសាលាដំបូងជាន់គ្នាផងដែរ។ បញ្ហាត្រង់ថា

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៣។

**"តើចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចស្រាវជ្រាវបទល្មើសបានទេ ប្រសិនបើជនត្រូវចោទមិនមានវត្តមានក្នុងដែនដីរបស់ខ្លួន?"**

មិនតែប៉ុណ្ណោះក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់នូវសិទ្ធិពន្លាតសមត្ថកិច្ចជូនទៅចៅក្រមស៊ើបសួរបន្ថែមទៀត។ ចំពោះសមត្ថកិច្ចនេះដែលចៅក្រមស៊ើបសួរ ក៏អាចប្រើប្រាស់អំណាចទៅលើសមត្ថកិច្ចដែនដីដ៏ទៃទៀតបានដែរ ប្រសិនបើជនត្រូវចោទមិនមានវត្តមាននៅលើដែនដីរបស់ខ្លួន ចៅក្រមស៊ើបសួរក៏អាចត្រូវបានប្រើប្រាស់អំណាចនេះដោយចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។ ចំពោះដីការចាត់ឱ្យស៊ើបសួរជំនួសនេះ គឺត្រូវបានបែងចែកជាពីរ គឺដីកាចាត់ឱ្យស៊ើបសួរជំនួសចាត់ឱ្យចៅក្រមស៊ើបសួរផ្សេង និងដីកាចាត់ឱ្យស៊ើបសួរដែលចាត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។

### ១.២. សមត្ថកិច្ចតាមសាច់រឿងរបស់ចៅក្រមស៊ើបសួរ

ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំទទួលស្គាល់ថាតុលាការទាំងឡាយអាចប្តឹងមកខ្លួន ដោយខ្លួនឯងផ្ទាល់ដើម្បីស៊ើបសួរ ឬវិនិច្ឆ័យបទល្មើសព្រហ្មទណ្ឌឡើយ បើទោះជាតុលាការទាំងនោះបានដឹងដោយខ្លួនឯងផ្ទាល់នូវបទល្មើសក៏ដោយ។ ដូច្នេះចៅក្រមស៊ើបសួរអាចស៊ើបសួរបាន លុះត្រាតែត្រូវបានប្តឹងពីរឿងមួយដោយព្រះរាជអាជ្ញា ឬដោយជនរងគ្រោះ ដែលអាចបើកការស៊ើបសួរដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ។

ចំពោះសមត្ថកិច្ចនេះ គឺសម្តៅទៅលើការទទួលបាននូវភារៈកិច្ចក៏ដូចជាមុខការដែលទទួលបានដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលប្តឹងសុំដោយព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលបញ្ជូនមក ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។[11] ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។ បើពិនិត្យទៅលើមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺបង្ហាញឱ្យឃើញកាន់តែច្បាស់ថា ចៅក្រមស៊ើបសួរដោយផ្អែកទៅតាមអង្គហេតុជាសម្ភារៈពិតៗ ដែលបានប្តឹងសុំពីព្រះរាជអាជ្ញាចង្អុលនូវឈ្មោះបទល្មើស និងអំពីឈ្មោះបុគ្គលដែលតម្រូវឱ្យស៊ើបសួរ។ ក្នុងន័យនេះ ក៏ចង់បញ្ជាក់ថាចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរតាមតែអ្វីដែលកំណត់ក្នុងដីកានេះតែប៉ុណ្ណោះ។

### ២. វិសមតិភាពមុខងារ

ដោយស្ថិតក្រោមឈ្មោះរួមជាចៅក្រម គឺគេប្រមូលផ្តុំជនទាំងអស់ ដែលមានលក្ខន្តិកៈជាចៅក្រមដែលបំពេញមុខងារផ្សេងៗគ្នាក្នុងប្រព័ន្ធយុត្តាធិការ។ ភាពខុសគ្នានូវតួនាទីទាំងនេះនាំឱ្យមានបុព្វសិទ្ធិ និងកាតព្វកិច្ចនៅពេលបំពេញមុខងាររបស់ខ្លួន។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៥។

ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬចៅក្រមស៊ើបសួរលើរឿងណាមួយមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើមិនដូច្នេះទេសាលក្រមនឹងត្រូវចាត់ទុកជាមោឃៈ។[12] ក្នុងន័យនេះដែរ ព្រះរាជអាជ្ញា ជាមជ្ឈដ្ឋានកណ្តាលក្នុងការទទួលនៅរាល់គ្រប់ព័ត៌មានទាំងអស់ តាមគ្រប់មធ្យោបាយដែលបង្កើតបាន ជាបទល្មើសព្រហ្មទណ្ឌ ទោះបីជាព្រះរាជអាជ្ញាពុំមានសិទ្ធិអំណាចក្នុងការស៊ើបសួរក៏ដោយ ប៉ុន្តែក្នុងនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់ព្រះរាជអាជ្ញានូវសិទ្ធិក្នុងការស៊ើបអង្កេត ដោយមានជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ ក្នុងស្មារតីនៃមាត្រានេះដែរ គឺចង់បង្ហាញថាប្រសិនបើ ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញាបានទទួលនូវសំណុំរឿង ឬចាត់ការលើសំណុំរឿងហើយ គឺជាការស្វែងរកនូវភស្តុតាង ចំពោះព្រះរាជអាជ្ញា គឺស្វែងរកតែភស្តុតាងដាក់បន្ទុក ខុសពីចៅក្រមស៊ើបសួរ គឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដូចនេះហើយប្រសិនជាឱ្យព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរទៅធ្វើជាចៅក្រមជំនុំជម្រះទៀតនោះច្បាស់ណាស់ប្រាកដជាមានបុរេវិនិច្ឆ័យ ដែលធ្វើឱ្យមានភាពអយុត្តិធម៌ទៅលើជនល្មើស ហើយសាលក្រមនោះ គឺចាត់ទុកជាគ្មានបានការ គឺគ្មានអានុភាពទៅតាមផ្លូវច្បាប់ឡើយ។ ដូច្នេះដើម្បីជាការធានានូវសេចក្តីសម្រេចប្រកបដោយភាពយុត្តិធម៌ និងការស្វែងរកការពិតកាន់តែមានសុក្រឹត្យភាព។

**កថាខណ្ឌទី៣ ទម្រង់ការដាច់ខាតដែលត្រូវគោរព**

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលចេញដោយព្រះរាជអាជ្ញាទៅឱ្យចៅក្រមស៊ើបសួរមិនចងកាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរទេ។ ទោះបីជាចៅក្រមស៊ើបសួរទទួលបាននូវមុខការដាច់ខាតនៅពេលដែលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែបំពេញនិងគោរពនូវទម្រង់ការមួយចំនួនដែលបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាគោលការណ៍មួយសម្រាប់ដំណើរការស៊ើបសួរឱ្យមានភាពយុត្តិធម៌ និងជៀសវាងនូវការបំពេញនូវកាតព្វកិច្ចតាមចិត្តរបស់ខ្លួន។ ក្នុងនោះដែលយើងឃើញថាចៅក្រមស៊ើបសួរត្រូវគោរពនូវ ការសម្ងាត់នៃការស៊ើបសួរ និងការធ្វើកំណត់ហេតុដែលធ្វើជាលាយលក្ខណ៍អក្សរផងដែរ។

**១. ការសម្ងាត់នៃការស៊ើបសួរ**

ដូចដែលបានរៀបរាប់នូវមុននេះបន្តិចហើយថា ការត្រូវតែគោរពនូវគោលការណ៍មួយចំនួនផងដែរ ក្នុងនោះក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងអំពីគោលការណ៍សម្ងាត់នៃការស៊ើបសួរ។ បុគ្គលដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេស ចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា២៨៨។

មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា ៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។[13] ប៉ុន្តែការគោរពនូវការសម្ងាត់វិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើប្រាស់សិទ្ធិនៃការការពារខ្លួនឡើយ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត។ ការបំពាននៃការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[14]បើពិនិត្យទៅលើមាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌគឺបង្ហាញឱ្យឃើញនូវស្មារតីនៃមាត្រានេះថា ការបើកការស៊ើបសួរជាសម្ងាត់ គឺវាអាចផ្តល់នូវភាពងាយស្រួលក្នុងការស្វែងរកតម្រុយននៃភស្តុតាង ក៏ដូចជាអ្នកដែលបានចូលរួមប្រព្រឹត្តិបទល្មើសផ្សេងទៀតផង។ ក្នុងបញ្ញត្តិនៃមាត្រានេះទៀតសោតក៏បានដាក់កាតាព្វកិច្ចដែលមានសិទ្ធិក្នុងការចូលរួមការស៊ើបសួរ ដោយតម្រូវឱ្យបុគ្គលទាំងនោះរក្សានូវការសម្ងាត់នៅក្នុងពេលកំពុងស៊ើបសួរ គឺក្នុងគោលបំណងដើម្បីដំណើរការប្រព្រឹត្តិទៅជៀសវាងការលេចលឺទៅខាងក្រៅ ដែលអាចបណ្តាលឱ្យជនល្មើសដឹងខ្លួនជាមុន ឬរុញច្រានឱ្យជនល្មើសនោះលុបបំបាត់នូវភស្តុតាងដែលពាក់ព័ន្ធ ឬក៏អាចធ្វើឱ្យជនល្មើសដឹងអំពីសាក្សីហើយអាចទៅសម្លុតគម្រាមសាក្សីដើម្បីកុំឱ្យឆ្លើយដាក់បន្ទុកលើខ្លួន ដែលអាចធ្វើឱ្យការស៊ើបសួរពិបាកក្នុងការស្វែងរកការពិត។ ប៉ុន្តែការរក្សានូវការសម្ងាត់នេះ ក៏បង្កើតឱ្យមានអញ្ញត្រកម្មដែរ គឺថា ប្រសិនជាមានឧបសគ្គដល់ការប្រើប្រាស់សិទ្ធិរបស់ខ្លួន គឺបុគ្គលដែលមានសិទ្ធិចូលរួមក្នុងការស៊ើបសួរទាំងនេះអាចមិនរក្សាការសម្ងាត់នេះបានហើយ ក៏មិនអាចបង្ខំឱ្យទទួលនូវទណ្ឌកម្ម ឬបទល្មើសដែលអាចនឹងផ្តន្ទាទោសផងដែរ ប្រសិនជាការរក្សាការសម្ងាត់នេះអាចនឹងប៉ះពាល់ ឬអាចមានគ្រោះថ្នាក់ដល់ខ្លួន។

### ២. ការធ្វើកំណត់ហេតុដែលធ្វើជាលាយលក្ខ័ណអក្សរ

ជាគោលការណ៍រាល់កិច្ចនីតិវិធីស៊ើបសួរ ត្រូវធ្វើជាលាយលក្ខ័ណអក្សរហេតុដូចនេះហើយចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីអម។ ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីអមជានិច្ច។ ក្នុងករណីណាក៏ដោយក្រឡាបញ្ជី មិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។[15] វត្តមានរបស់ក្រឡាបញ្ជីគឺ ខានមិនបានចំពោះគ្រប់កិច្ចស៊ើបសួរទាំងអស់។ វត្តមាននេះ ត្រូវចុះក្នុងលិខិតដែលត្រូវមានចុះហត្ថលេខារបស់ក្រឡាបញ្ជី។ សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី។ ក្រឡាបញ្ជីត្រូវចម្លងលិខិតនីមួយៗនៃសំណុំរឿង តាមលទ្ធភាពដែលអាចធ្វើទៅ

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៨៣។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២១។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា១២៨។

បាន។ លិខិតចម្លងនេះត្រូវតែបញ្ជាក់ថា ត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី។ សេចក្ដីចម្លងត្រូវរៀបចំទុកនៅក្នុងសំណុំរឿងបង្ការទុក។ គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ។[16] ដូចនេះមានន័យថាទាក់ទងនឹងការធ្វើកំណត់ហេតុនេះ គឺគេផ្ដោតសំខាន់ទៅលើក្រឡាបញ្ជី ដែលអាចនិយាយបានថាជាកិច្ចការក្រឡាបញ្ជីត្រូវតែធ្វើដោយខានពុំបាន។

## ផ្នែកទី២ ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើងដឹងហើយថា នៅពេលដែលមានអង្គហេតុជាបទល្មើសណាមួយ យើងសង្កេតឃើញថាគឺរមែងមានភាគីពីរ ដោយភាគីម្ខាងជាជនរងគ្រោះ និងភាគីម្ខាងទៀតជាជនបង្ក ឬជនល្មើសជាដើម។ ចំពោះអំពើដែលមានការបំពារបំពាន ឬបង្កឱ្យកើតឡើងនូវព្យសនកម្មដល់សង្គមបែបនេះមានន័យថាជនរងគ្រោះ គឺជាអ្នកទទួលរងផ្ទាល់នូវព្យសនកម្ម និងផលវិបាកដែលបង្កឡើងដោយបទល្មើសព្រហ្មទណ្ឌ។ ដូចនេះ សិទ្ធិរបស់ជនរងគ្រោះត្រូវបានធានាការពារដោយច្បាប់។ នៅក្នុងន័យនេះ ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃ ១០ ខែសីហា ឆ្នាំ២០០៧ បានផ្ដល់នូវសិទ្ធិឱ្យជនរងគ្រោះក្នុងការធ្វើបណ្ដឹងទាំងឡាយដែលចាំបាច់ដើម្បីការពារសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ ក្នុងនោះដែររួមមានបណ្ដឹងទាមទារសំណង និងបណ្ដឹងបរិហារចំពោះបទល្មើស។

ផងដែរតាមរយៈការទាមទារនេះ ចាំបាច់ត្រូវធ្វើឡើងតាមរយៈនីតិវិធីមួយដែលភាគីនៃបណ្ដឹងដែលត្រូវគោរពតាម គឺនីតិវិធីនៃការដាក់ពាក្យបណ្ដឹង។ ដើម្បីអាចដាក់ពាក្យប្ដឹងនេះបានភាគីនៃបណ្ដឹងត្រូវធ្វើឡើងជាទម្រង់ដែលច្បាប់កំណត់ក៏ដូចជាបែបបទនៃលិខិតជាពាក្យប្ដឹងនោះ។ មួយវិញដើម្បីអាចឱ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានឱ្យស៊ើបសួរបាននោះ ក៏មានចំណែកកើតចេញពីនាយឋានានុក្រមដែលមានអំណាចក្នុងការ ធ្វើអធិបញ្ជាឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បានហើយក្នុងករណីនេះ ក៏អាចឱ្យព្រះរាជអាជ្ញាបើកការស៊ើបសួរផងដែរ គឺតាមរយៈការស្នើសុំឱ្យស៊ើបសួរដោយយុត្តាធិការព្រហ្មទណ្ឌបានផងដែរ។ មូលហេតុទាំងនេះ នឹងមានការបកស្រាយក្នុងចំណុចខាងក្រោយ។ មួយវិញទៀត ក្នុងនាមព្រះរាជអាជ្ញាជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈ និងជាអ្នកទាមទារឱ្យតុលាការអនុវត្តតាមច្បាប់ ចំពោះអង្គហេតុជាបទល្មើសព្រហ្មទណ្ឌ ក្នុងករណីនេះមិនចាំបាច់ទាល់មានការដាក់ពាក្យសុំដោយភាគីជនរងគ្រោះប្ដឹងមក ឬអ្នកដែលយល់ថាខ្លួនជាបាត់បង់នូវផលប្រយោជន៍កើតចេញពីអំពើនោះទេ គឺព្រះរាជអាជ្ញាមានកាតព្វកិច្ចចម្បងក្នុងរឿងនេះក្នុងការផ្ដើមធ្វើការចោទប្រកាន់។ យ៉ាងណាមិញ សំណុំរឿងនីតិវិធី គឺត្រូវទាមទារដោយការស៊ើប

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១២៩,កថាខណ្ឌទី ១ និងទី២។

អង្កេតដែលមានភាពឆាប់រហ័ស និងមានប្រសិទ្ធិភាព។ ភាគីនៃនីតិវិធីនេះ រួមមានដូចជាព្រះរាជអាជ្ញា ដែលមានតួនាទីចម្បង និងជនរងគ្រោះដែលមានតួនាទីបន្ទាប់បន្សំត្រូវសម្រេចថា នឹងធ្វើដូចម្ដេចបន្តទៅមុខទៀតដោយយោងទៅលើភាពជាក់លាក់ និងស្ថានភាពភស្តុតាងដែលប្រមូលបាន។ ត្រង់ចំណុចនេះហើយជាភាពចាំបាច់ដែលភាគីរងគ្រោះ ឬភាគីបណ្ដឹងត្រូវធ្វើពាក្យបណ្ដឹងរបស់ខ្លួនឱ្យមានភាពត្រឹមត្រូវជៀសវាងការលើកចោលនូវពាក្យប្ដឹងរបស់តុលាការនេះ។

**កថាខណ្ឌទី១ ការដាក់ពាក្យប្ដឹង**

ចំពោះការដាក់ពាក្យប្ដឹងនេះ គឺត្រូវធ្វើតាមទម្រង់ជាបណ្ដឹងបរិហារ និងទម្រង់ជាពាក្យប្ដឹងដោយការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ យ៉ាងណាមិញ បណ្ដឹងទាំងពីរនេះ ជាប្រភេទបណ្ដឹងដែលអាចធ្វើឱ្យបណ្ដឹងអាជ្ញាមានចលនា។ នៅក្នុងករណីមានការតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា ភ្លាមនោះគេអាចផ្ដល់ជម្រើសដល់ជនរងគ្រោះក្នុងការដាក់ពាក្យប្ដឹងដូចបានជម្រាបជូនខាងលើថា នៅពេលមានការមិនសុខចិត្តទៅ នឹងសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញានោះ ជនរងគ្រោះខ្លួនឯងអាចធ្វើបណ្ដឹងតាមរយៈការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរដែលច្បាប់បានតម្រូវ ហើយក៏មានការធ្វើការបកស្រាយជូនដូចខាងក្រោម។

**១.បណ្ដឹងបរិហារ**

បើមើលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងទៅនឹងបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ក៏មានចែងផងដែរ ថាមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកទទួលពាក្យបណ្ដឹងទាមទារ និងបណ្ដឹងបរិហារ។[17] ដោយបណ្ដឹងទាមទារនេះ ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងដោយមានការទាមទារសំណងរដ្ឋប្បវេណីបាន ដោយផ្អែកលើព្យសនកម្មដែលខ្លួនទទួលរង។ ចំណែកឯបណ្ដឹងបរិហារ គឺសំដៅទៅលើបណ្ដឹងវែកមុខបទល្មើសដែលមានបំណងបង្ហាញ ឬបកអាក្រាតនូវបទល្មើស ដើម្បីឱ្យសមត្ថកិច្ចធ្វើការត្រួតពិនិត្យ និងស្វែងរកភស្តុតាងនៅក្នុងបទល្មើស ដោយចាប់ជនល្មើសបានប្រព្រឹត្តយកមកផ្ដន្ទាទោសតាមច្បាប់។ **ឧទាហរណ៍:** ក្នុងករណីមានចោរឆក់ ឬលួចទ្រព្យសម្បត្តិជាដើម។ បណ្ដឹងបរិហារនេះអាចធ្វើឡើងតាមរយៈភាគីរងគ្រោះផ្ទាល់ និងតតិយជន ឬដោយមន្ត្រីសាធារណៈដែលគាត់បានឃើញ ឬបានដឹងពីបទល្មើសនោះ។ **ឧទាហរណ៍:** យើងដើរទៅកន្លែងមួយស្រាប់តែឃើញមានមនុស្សស្លាប់ហើយក៏មិនដឹងថានរណាជាអ្នកសម្លាប់ជនរងគ្រោះនោះដែរ ប៉ុន្តែជាគោលការណ៍យើងដែលជាអ្នកឃើញមនុស្សស្លាប់នោះក៏មានសិទ្ធិប្ដឹងទៅកាន់នគរបាលយុត្តិធម៌ ឬទៅព្រះ

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៧១។

រាជអាជ្ញាបានដូចគ្នាដែរ ដើម្បីឱ្យមានការចុះស៊ើបអង្កេត។ បណ្តឹងនេះគ្រាន់ជាសេចក្តីរាយការណ៍អំពីបទល្មើសតែប៉ុណ្ណោះ ពីព្រោះអ្នកប្តឹងនោះមិនមែនជាម្ចាស់បណ្តឹងទេ រីឯម្ចាស់បណ្តឹង គឺព្រះរាជអាជ្ញាទេ ជាម្ចាស់នៃបណ្តឹងអាជ្ញា។

ចំពោះបណ្តឹងបរិហារនេះផងដែរ នៅពេលដែលបានដាក់មកកាន់មន្ត្រីនគរបាលយុត្តិធម៌រួចមក មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតដើម្បីប្រមូលភស្តុតាងបញ្ជូនទៅកាន់អយ្យការ ឬតាមរយៈពាក្យប្តឹងបរិហារផ្ទាល់មកកាន់អយ្យការ ដោយមានគោលបំណងដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការសម្រេច ថាតើត្រូវធ្វើការចោទប្រកាន់ ឬតម្កល់ទុកតាមរយៈការថ្លឹងថ្លែងរបស់ខ្លួន។[18]ត្រង់ចំណុចនេះ មិនមែនសុទ្ធតែបណ្តឹងមកកាន់ព្រះរាជអាជ្ញាសុទ្ធតែព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬបណ្តឹងអាជ្ញាមានចលនានោះទេ។ ពាក្យថាបណ្តឹងអាជ្ញា គឺជាបណ្តឹងពិនិត្យអំពីបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះដោយដាក់ពន្ធនាគារមានកាលកំណត់ ឬដាក់ពន្ធនាគារអស់មួយជីវិត ចំពោះជនដែលប្រព្រឹត្តអំពើដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម ឬប្រឆាំងនឹងវិធានច្បាប់ព្រហ្មទណ្ឌជាដើម។ បច្ចុប្បន្ន គេឃើញថាបណ្តឹងអាជ្ញា ជាបណ្តឹងប្រឆាំងនឹងជនល្មើសដែលប្រព្រឹត្តបទល្មើសណាមួយ ដោយទាមទារឱ្យតុលាការធ្វើការផ្តន្ទាទោសជននោះ។ បណ្តឹងអាជ្ញានេះដែរ ត្រូវបានអនុវត្តដោយអយ្យការក្នុងនាមអ្នកការពារផលប្រយោជន៍ ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។ ការចាប់ផ្តើមនៃបណ្តឹងអាជ្ញា មានន័យថាព្រះរាជអាជ្ញាផ្តើមធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ (អាចជាបទឧក្រិដ្ឋ មជ្ឈិម ឬលហុ) និងសុំឱ្យអនុវត្តច្បាប់នៅចំពោះយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

បណ្តឹងអាជ្ញា មានអានុភាពអនុវត្តលើគ្រប់បុគ្គល ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយដើមកំណើត ជាតិឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។[19] ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌអាចជានីតិបុគ្គល ថ្វីត្បិតតែជាបុគ្គលសិប្បនិម្មិត ដែលបង្កើតឡើងដោយច្បាប់ក៏ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដែរ នីតិបុគ្គលនោះអាចទទួលរងនូវការពិន័យជាប្រាក់ ឬទទួលរងនូវទោសបន្ថែមណាមួយដូចជាការរំលាយនីតិបុគ្គលជាដើម។ នៅក្នុងការចោទប្រកាន់នេះ ជាតួនាទីរបស់អយ្យការតាមរយៈបណ្តឹងអាជ្ញា។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាមានតែអង្គការ

---

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៤០។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៣។

អយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។[20]ករណីនេះព្រះរាជអាជ្ញាមានភារកិច្ចដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។[21] ក្រៅពីអំណាចដឹកនាំសម្របសម្រួលសកម្មភាពនគរបាលយុត្តិធម៌ អំណាចបើកការស៊ើបអង្កេត ព្រះរាជអាជ្ញាផងដែរមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យបណ្តឹងអាជ្ញាមានចលនា មានន័យថាតាមរយៈការចោទប្រកាន់អំពីបទល្មើសណាមួយ។ ទាក់ទងនឹងការចោទប្រកាន់នេះដែរ គឺក្រោយពីទទួលបានបណ្តឹងទាមទារ ឬបណ្តឹងបរិហារពីជនណាម្នាក់ ឬទទួលរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ប្រសិនបើយល់ថាពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់នៅឡើយ។ ផងដែរអយ្យការអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្វែងរកភស្តុតាងបន្ថែម ឬបើការស៊ើបអង្កេតបឋមបាន។[22] ចំពោះពាក្យប្តឹងនេះដែរ អាចធ្វើឡើងតាមរយៈជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ ឬមន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌដូចជា មន្ត្រីគយជាដើម ឬតតិយជនដែលដឹងលឺពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។ មុននឹងធ្វើសេចក្តីសម្រេច ព្រះរាជអាជ្ញាក៏ត្រូវធ្វើការពិនិត្យទៅលើកត្តាជាច្រើនយ៉ាងដូចជា៖[23]

- តើអំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ហើយឬនៅ? ហើយត្រូវវាយតម្លៃកំណត់បទល្មើសឱ្យសមស្របទៅនឹងអំពើបានប្រព្រឹត្ត។ **ឧទាហរណ៍៖** ជនម្នាក់បានឆក់យកទូរស័ព្ទអ្នកដទៃ ត្រង់ចំណុចនេះនឹងត្រូវវាយតម្លៃអំពើប្រព្រឹត្តនោះថាជាបទលួច។
- ពិនិត្យថាតើជនសង្ស័យមានអភ័យឯកសិទ្ធិឬទេ? **ឧទាហរណ៍៖** អភ័យឯកសិទ្ធិគ្រួសារ[24] ឬអភ័យឯកសិទ្ធិការទូត។
- តើជនសង្ស័យត្រូវចោទប្រកាន់ក្នុងនាមជាអ្វីឱ្យសមស្របទៅ នឹងអំពើដែលបានប្រព្រឹត្តរបស់ជននោះ? **ឧទាហរណ៍៖** ចោទប្រកាន់ក្នុងជាចារី សហចារី ឬអ្នកសមគំនិត ឬអ្នកផ្តើមគំនិតជាដើម។
- ត្រូវពិនិត្យថាស្ថិតក្នុងដែនសមត្ថកិច្ចដែរឬទេ? ព្រះរាជអាជ្ញានៃទីកន្លែងប្រព្រឹត្តបទល្មើស។ ឧទាហរណ៍៖ បទល្មើសកើតឡើងនៅខេត្តព្រៃវែង នោះសមត្ថកិច្ចរបស់អយ្យការអមសាលាដំបូងខេត្តព្រៃវែង។

---

[20] មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៣៧ កថាខណ្ឌទី១។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[23] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *មេរៀននីតិវិធីព្រហ្មទណ្ឌ*, ២០១៧, ២៧។

[24] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១២០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា ៣៥៥។

- ព្រះរាជអាជ្ញានៃទីលំនៅជនសង្ស័យបានប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តបទល្មើសនៅរាជធានីភ្នំពេញ ហើយត្រូវបានគេដឹងថាជននោះមានទីលំនៅស្ថិតក្នុងខេត្តស្វាយរៀង ហើយជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងនៅសាលាដំបូងខេត្តស្វាយរៀង។
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យបានប្រព្រឹត្តបទល្មើស។ ឧទាហរណ៍៖ ជនល្មើសបានបាញ់ជនរងគ្រោះនៅខេត្តកំពង់ស្ពឺ ហើយបានរត់មកលាក់ខ្លួននៅភ្នំពេញ បន្ទាប់មកក៏ត្រូវចាប់ខ្លួន។ ក្នុងករណីនេះ អយ្យការអមសាលាដំបូងភ្នំពេញមានសមត្ថកិច្ច។
- ត្រូវពិនិត្យថាតើក្នុងករណីនេះ ត្រូវមានបណ្ដឹងរបស់ជនរងគ្រោះដែរឬទេ? **ឧទាហរណ៍៖** ដើម្បីអាចចោទប្រកាន់ពីបទបរិហារកេរ្តិ៍បានជាសាធារណៈបាន ចាំបាច់ត្រូវមានបណ្ដឹងពីជនរងគ្រោះ។[25]
- ត្រូវពិនិត្យថា តើបណ្ដឹងអាជ្ញាត្រូវរលត់ហើយឬនៅ?

ក្រោយពិនិត្យមូលហេតុទាំងអស់រួចហើយ ទើបព្រះរាជអាជ្ញាមានមូលដ្ឋានក្នុងការធ្វើបណ្ដឹងអាជ្ញានេះ។

ដោយបានដឹងហើយថា ការដែលអាចបើកការស៊ើបសួរបាន គឺទាល់តែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា។ ក្នុងករណីនេះ ព្រះរាជអាជ្ញាមានមធ្យោបាយច្រើនដើម្បីដាក់បណ្ដឹងអាជ្ញា។ ការជ្រើសរើសយកមធ្យោបាយទាំងនេះ អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿងនីតិវិធី ដែលរួចរាល់អាចបញ្ជូនទៅតុលាការជំនុំជម្រះ ឬក៏តម្រូវឱ្យមានការបើកការស៊ើបសួរជាទូលំទូលាយផងដែរ។ ភាពចាំបាច់នេះ ជាកាតព្វកិច្ចដោយអាស្រ័យទៅលើប្រភេទបទល្មើសដែលពាក់ព័ន្ធ។ ទោះជាបណ្ដឹងអាជ្ញានេះ អាចប្ដឹងទៅយុត្តាធិការជំនុំជម្រះក៏ដោយ ការចោទប្រកាន់អាចធ្វើទៅបានតាមរយៈជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ក្នុងនោះរួមមាន៖

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនរឿងទៅជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម។[26]

ជាជម្រើសនៃការចោទប្រកាន់នេះ តាមរយៈការការបើកការស៊ើបសួរដែលកំណត់ប្រភេទបទល្មើស រួមមានបទឧក្រិដ្ឋ បទមជ្ឈិមដែលច្បាប់តម្រូវ។ ការបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវប្ដឹងទៅចៅក្រមស៊ើបសួរដែលមានអំណាចក្នុងការបើកការស៊ើបសួរ។ ការ

[25] ក្រមព្រហ្មទណ្ឌ,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា ៣០៩។
[26] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៣។

ស៊ើបសួរ អាចបើកប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។ ដោយនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះរួមមាន៖

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកានេះត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់នេះមានលក្ខណៈសំខាន់ដែលត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវចាត់ទុកជាមោឃៈ។[27]

ចំពោះភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដែលត្រូវប្ដឹងទៅយុត្តាធិការស៊ើបសួរនោះ គឺស្ថិតក្នុងការវាយតម្លៃពីស្ថានភាពសំណុំរឿងនៃនីតិវិធីផងដែរ ថាអាចឱ្យព្រះរាជអាជ្ញា យល់ពីភាពចាំបាច់ក្នុងការបើកការស្រាវជ្រាវបទល្មើស ដើម្បីទទួលបានភស្តុតាងដែលអនុញ្ញាតឱ្យអនុវត្តបណ្ដឹងអាជ្ញាដោយសមហេតុផល។ ក្នុងទស្សនវិស័យនេះ ព្រះរាជអាជ្ញា មានផ្លូវពីរ៖ ទី១ បន្តការស៊ើបអង្កេត និងទី២ តាមរយៈការធ្វើបណ្ដឹងទៅចៅក្រមស៊ើបសួរ។ ក្នុងករណីដែលការស៊ើបសួរ ក៏មានលក្ខណៈមិនដាច់ខាត ដូចក្នុងករណីបទមជ្ឈិម ឬបទលហុ ដោយព្រះរាជអាជ្ញាធ្វើចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរ អាស្រ័យទៅលើការចម្រើនទៅមុខនៃសំណុំរឿងនីតិវិធី។ ជាទូទៅ ព្រះរាជអាជ្ញាអាចចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ នៅពេលណាដែលបុគ្គលពាក់ព័ន្ធមិនបានកំណត់អំពីអត្តសញ្ញាណ និងមិនអាចកំណត់អំពីអត្តសញ្ញាណបានក្នុងពេលបច្ចុប្បន្ន ដូច្នេះការប្ដឹងទៅយុត្តាធិការជំនុំជម្រះមិនអាចធ្វើឡើងបានឡើយ។ ព្រះរាជអាជ្ញា ក៏នឹងអាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផងដែរ ប្រសិនបើក្រោយពីពិនិត្យសំណុំរឿងនីតិវិធីខ្លួនយល់ឃើញថា ភស្តុតាងដែលខ្លួនប្រមូលបាននៅពុំមានភាពគ្រប់គ្រាន់ដើម្បីប្ដឹងទៅយុត្តាធិការជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះនោះ អាចប្រមូលបានគឺទាល់តែប្រើអំណាចបង្ខំ ហើយអ្នកមានអំណាចនោះ គឺចៅក្រមស៊ើបសួរដោយមានមន្ត្រីនគរបាលយុត្តិធម៌ជាសេនាធិការជំនួយដល់ក្នុងការស្វែងភស្តុតាង ដើម្បីបង្ហាញនូវភាពពិតក្នុងអង្គហេតុ។

## ២. ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

យើងបានដឹងដូចការរៀបរាប់ខាងលើរួចមកហើយ អំពីបណ្ដឹងបរិហារដែលប្ដឹងក្នុងគោលបំណងទាមទារឱ្យផ្ដន្ទាទោសទៅលើអំពើជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ។ យ៉ាងណាមិញ

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៤។

ទន្ទឹមនឹងនេះ ក៏មិនភ្លេចដែរបន្ទាប់ពីមានពាក្យបណ្តឹងបរិហារ មានពាក្យបណ្តឹងមួយទៀត គឺដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺធ្វើឡើងតាមរយៈជនរងគ្រោះនៃបទល្មើស អាចដាក់ពាក្យបណ្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា[28] ហើយមួយវិញទៀតការដាក់ពាក្យបណ្តឹងនេះផងដែរ គឺអាចធ្វើឡើងដោយបុគ្គលគ្រប់រូបដែលប្រកាសថាខ្លួនបាត់បង់ផលប្រយោជន៍ដោយអំពើជាបទល្មើស អាចដាក់ពាក្យប្តឹងបាន។ ចំពោះពាក្យប្តឹងសាមញ្ញនេះ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ។ នៅក្នុងប្បញ្ញាតិដំបូង នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានយកចិត្តទុកដាក់ក្នុងការធានារ៉ាប់រងនូវជោគវាសនារបស់ជនរងគ្រោះ។ ក្នុងករណីនេះ យើងមិនអាចបដិសេធក្នុងការរៀបចំបណ្តឹងតវ៉ាបានទេបើសិនជនរងគ្រោះបានបង្ហាញខ្លួន។ ហើយមានតែបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរប៉ុណ្ណោះ ទើបអាចដាក់ឱ្យបណ្តឹងអាជ្ញាមានចលនា ឬដំណើរការបាន។ មួយវិញទៀត ដើម្បីឱ្យសិទ្ធិដល់ជនដែលរងគ្រោះដោយសារតែអំពើនោះតាមរយៈបណ្តឹងរដ្ឋប្បវេណីដើម្បីជួសជុលនូវព្យសនកម្មមួយចំនួនដែលត្រូវតែះ

- ជាផលវិបាកផ្ទាល់នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតនិងនៅក្នុងពេលបច្ចុប្បន្ន។

ក្នុងនោះរួមមានព្យសនកម្មផ្នែក សំភារៈ ផ្លូវចិត្ត និងរូបកាយ។[29] ទាំងនេះហើយជាហេតុនាំឱ្យមានការប្តឹងដើម្បីទាមទារសំណង នូវរាល់ព្យសនកម្មដែលកើតឡើង និងទាមទារឱ្យតុលាការអនុវត្តតាមផ្លូវច្បាប់ ឬផ្តន្ទាទោសលើជនល្មើស។ ដូច្នេះ ព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ត្រូវធ្វើការសម្រេចថ្លឹងថ្លែងអំពីចំណាត់ការក្នុងពាក្យបណ្តឹង និងពាក្យប្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធមិបញ្ជូនមកថា[30] ត្រូវធ្វើបណ្តឹងអាជ្ញាចំពោះបទល្មើសដែលនីតិវិធីបានកសាងឬទេ? ទោះជាជនរងគ្រោះមានត្រឹមតែតួនាទីបន្ទាប់បន្សំក៏ដោយ ក៏ជននេះមានសិទ្ធិស្វ័យសម្រេចលើការអនុវត្តជាយថាហេតុនូវសិទ្ធិក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីនៅតុលាការរដ្ឋប្បវេណី ដែលជាញឹកញយអាស្រ័យទៅលើសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌ មានន័យថាបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងក្នុងពេលតែមួយនឹងបណ្តឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ ហើយបណ្តឹងអាជ្ញាក៏អាចធ្វើនៅ មុខសាលជម្រះរដ្ឋប្បវេណី ក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីត្រូវបានព្យួរ

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ៥។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤០ កថាខណ្ឌទី១។

សិន ដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថានពរមួយ ត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។[31] ហេតុដូច្នេះ ដំណាក់កាលនៃចំណាត់ការសំណុំរឿង ត្រូវស្ថិតក្នុងការសម្រេច ថាតើព្រះរាជអាជ្ញាត្រូវយកផ្លូវណាមួយសម្រាប់ដើរ ដោយអាចតាមរយៈការបញ្ជូនសំណុំរឿងទៅឱ្យយុត្តាធិការស៊ើបសួរដើម្បីរៀបចំសំណុំរឿងនេះ ឬបញ្ជូនផ្ទាល់ទៅយុត្តាធិការជំនុំជម្រះ ឬការតម្កល់ទុកឥតចាត់ការ។

ចំពោះសេចក្តីសម្រេចនៃចំណាត់ការសំណុំរឿង ត្រូវគោរពនូវលក្ខខណ្ឌនៃការពិនិត្យទៅលើភាពអាចទទួលយកបាន (ផ្ទៀងផ្ទាត់ថាតើបទល្មើស ផុតអាជ្ញាយុកាល ឬនៅ) បន្ទាប់មក ត្រូវពិនិត្យទៅលើវិធានសមត្ថកិច្ចរបស់យុត្តាធិការដែលសំណុំរឿងនេះនឹងត្រូវបញ្ជូនទៅ។ ត្រង់ចំណុចនេះដែរ ប្រសិនសំណុំរឿងដែលទទួលបានមានភាពខ្វះខាតគឺ ព្រះរាជអាជ្ញាអាចធ្វើការអនុវត្តវិធានការមួយដោយចេញជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាការស៊ើបសួរអាចប្រព្រឹត្តទៅបានដោយមូលហេតុពីរយ៉ាងគឺ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" និង"ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ឬអាចនិយាយម្យ៉ាងទៀតថាការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ"។

ដើម្បីអាចដំណើរការនៃកិច្ចនីតិវិធីបើកការស៊ើបសួរបាន គឺក្រោយពីទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌មកកាន់អយ្យការ ឬបណ្តឹងពីជនរងគ្រោះផ្ទាល់ ដែលទាំងអស់នេះជាមូលដ្ឋានដើម្បីអាចឱ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ចំពោះបទល្មើសណាមួយបាន។ ក្នុងករណីនេះមួយផងដែរ បើទោះជាមានសំណុំរឿងដែលបញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌ ឬដាក់ដោយជនរងគ្រោះផ្ទាល់មកកាន់ព្រះរាជអាជ្ញាក៏ដោយ តែបើព្រះរាជអាជ្ញាយល់ថា សំណុំរឿងដែលបញ្ជូនមកមិនមែនជាបទល្មើស ឬពិតជាបទល្មើសព្រហ្មទណ្ឌមែន តែមានព្យសនកម្មតិចតួច ដែលព្រះរាជអាជ្ញាគាត់អាចធ្វើការតម្កល់រឿងទុកឥតចាត់ការ។ ក្នុងករណីនេះ កាលណាបណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹង។ ការតម្កល់ឥតចាត់ការនេះ ត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ ការតម្កល់ទុកឥតចាត់ការនេះដែរគ្មានអាជ្ញាអស់ជំនុំទេ។ **ឧទាហរណ៍:** បុគ្គល **ក** បានដាក់ពាក្យប្តឹងមកកាន់អយ្យការលើ **ខ** ដោយប្តឹងពីបទ ហឹង្សាដោយចេតនា ក្នុងករណីនេះ ព្រះរាជអាជ្ញាយល់ឃើញថាព្យសនកម្មតិចតួចពេកដោយពិនិត្យជាក់ស្តែងគ្រាន់តែ **ខ** រអិលជើងធាក់ចំ **ក** តែប៉ុណ្ណោះ។ ករណីមួយទៀត ប្រសិនជាបទល្មើសនោះជាបទឧក្រិដ្ឋវិញ នោះជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញាក្នុងការចេញដីកាសន្និដ្ឋានឱ្យចៅក្រមស៊ើបសួរបើក

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២២។

ការសើុបសួរភ្លាម តែបើជាបទមជ្ឈិមក្នុងច្បាប់ក៏បានកំណត់ថាអាចធ្វើបើកការសើុបសួរក៏បាន និង មិនបាច់ក៏បាន[32] មានន័យថា អាស្រ័យលើភាពស្មុកស្មាញនៃរឿងក្តី។ ករណីនេះចៅក្រមសើុបសួរ មិនអាចបើកការសើុបសួរបានទេបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសើុបសួរពីព្រះរាជអាជ្ញា។[33]

តាមរយៈការបើកការសើុបសួរនេះ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់ចៅក្រមសើុបសួរ ក្នុងគោលបំណងដើម្បីស្វែងរកការពិត និងករណីយកិច្ចសើុបសួររកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។[34] ម្យ៉ាងវិញទៀត ចំពោះការបើកការសើុបសួរផងដែរ នៅក្នុងករណីមានការតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញានោះមិនមែនជាផ្លូវចុងក្រោយនោះ មានន័យថាច្បាប់បានទុកផ្លូវមួយទៀតដល់ជនទាំងឡាយដែលយល់ថាខ្លួនរងគ្រោះ ឬប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួននោះ អាចធ្វើការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបាន ដោយជនរងគ្រោះអាចធ្វើឡើងតាមរយៈពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។[35]

ក៏ដូចគ្នាដែរបើសិនជនរងគ្រោះពុំបានទទួលដំណឹងពីការវិវត្តរបស់បណ្តឹងអាជ្ញានោះទេ ខ្លួនមានជម្រើសក្នុងការប្តឹងទៅអគ្គព្រះរាជអាជ្ញា។ បន្ទាប់ពីបានដឹងហើយថា ការតម្កល់ទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាមិនអានុភាពអាជ្ញាអស់ជំនុំទេ កាលណាជនរងគ្រោះនៃរឿងក្តីយល់ថារឿងគាត់គឺជារឿងព្រហ្មទណ្ឌ ហើយនៅតែចង់បន្តធ្វើការផ្តន្ទាទោសលើជននោះ គាត់អាចដាក់ពាក្យប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ខែ ក្រោយពេលទទួលដំណឹងពីការតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា ក្នុងករណីបណ្តឹងអាជ្ញាមិនទាន់ផុតរលត់។ បណ្តឹងអាជ្ញានេះ អាចធ្វើទៅបានក្នុងករណីដែលមានពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះទៅចៅក្រមសើុបសួរ។

មួយវិញទៀត នៅក្នុងករណីដែលពាក្យប្តឹងរបស់ជនរងគ្រោះស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការពីសំណាក់ព្រះរាជអាជ្ញាជនរងគ្រោះអាចប្តឹងទៅកាន់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[36] ចំពោះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺចៅក្រមសើុបសួរត្រូវធ្វើការកត់សម្គាល់នូវការ ដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈដីកា។ចៅក្រមសើុបសួរបញ្ជូនពាក្យបណ្តឹងនេះទៅកាន់ព្រះរាជអាជ្ញា។ ក្រោយពីបានឃើញ

---

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២២។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៤ កថាខណ្ឌទី៣។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៧ កថាខណ្ឌទី២។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៦។

ពាក្យប្ដឹងដោយមានការប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកានេះអាច ធ្វើឡើងប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចោទលើឈ្មោះបុគ្គលម្នាក់ឬច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ដោយចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ មួយវិញទៀតក្នុងករណីដែលចៅក្រមស៊ើបសួរ នៅតែសម្រេចស៊ើបសួរចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាសម្រេចមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។[37] ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម (ចំពោះបទលហុ មិនអាចធ្វើតាមវិធីនេះបានទេ) អាចដាក់ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាន។ នៅក្នុងករណីបែបនេះលំហូរនៃនីតិវិធីព្រហ្មទណ្ឌមានដូចតទៅ៖[38]

ទោះបីជាចៅក្រមស៊ើបសួរទទួលបានពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវដីកាបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាជាមុនសិន ទើបអាចធ្វើការស៊ើបសួរបាន។ ក្នុងន័យនេះ ក្រោយពីបានទទួលបានពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្ដឹងតាមដីកាហើយបញ្ជូនបណ្ដឹងនេះទៅកាន់ព្រះរាជអាជ្ញា។[39] ពេលដែលទទួលបានការបញ្ជូនបណ្ដឹងនេះ ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (បើការស៊ើបសួរប្រឆាំងអញ្ញាតជន ឬចោទប្រកាន់លើបុគ្គលចំពោះម្នាក់ ឬច្រើន) ប៉ុន្តែព្រះរាជអាជ្ញាក៏អាចប្ដឹងទៅចៅក្រមស៊ើបសួរ ប្រសិនអាជ្ញាយុកាលផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីខាងក្រោយនេះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចស៊ើបសួរ ឬដីកាសម្រេចមិនស៊ើបសួរ ដោយមានសំអាងហេតុ។ ហើយគួរកត់សម្គាល់ដែរថា បណ្ដឹងដោយមានការតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី ជាបណ្ដឹងមួយថ្មីដែលទើបតែបញ្ចូលក្នុងនីតិវិធីព្រហ្ម

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៩។

[38] លោក រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *មេរៀននីតិវិធីព្រហ្មទណ្ឌ*, ២០១៧, ៣៨។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៩។

ទណ្ឌថ្មីនេះឯង ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ប្រាក់តម្កល់ទុកតាមការកំណត់របស់ចៅក្រមស៊ើបសួរ តាមដីកាសម្រេចដោយផ្អែកលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងក្តីដែលអាចឃើញជាមុន តែចៅក្រមស៊ើបសួរក៏អាចលើកលែងមិនឱ្យបង់ប្រាក់នេះបានដែរ។ ប្រសិនបើចៅក្រមស៊ើបសួរ តម្រូវឱ្យបង់ប្រាក់តម្កល់ទុក តែដើមបណ្តឹងរដ្ឋប្បវេណីពុំបង់ក្នុងរយៈពេលកំណត់ដោយចៅក្រមទេ ចៅក្រមស៊ើបសួរត្រូវប្រកាសថាមិនអាចទទួលពាក្យបណ្តឹងនេះបាន។ ការតម្រូវឱ្យមានបង់ប្រាក់តម្កល់នេះ ដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណី ប្រសិនជាចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា ដោយចៅក្រមស៊ើបសួរចេញដីកាសម្រេចឱ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី។[40] តែប្រាក់ពិន័យនេះមិនអាចលើពីប្រាក់តម្កល់បានទេ។ ផ្ទុយទៅវិញប្រសិនបើមិនបង់ប្រាក់ពិន័យរដ្ឋប្បវេណីនេះទេ ប្រាក់តម្កល់នេះត្រូវបង្វិលឱ្យសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី។[41] ក្នុងករណីនេះដែរ ព្រះរាជអាជ្ញាសុំកុំឱ្យចៅក្រមចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរ ចៅក្រមមានជម្រើសពីរយ៉ាង៖

- មិនធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចមានសំអាងហេតុ ហើយធ្វើការជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណី។
- ធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចមានសំអាងហេតុ ហើយធ្វើការជូនដំណឹងទៅព្រះរាជអាជ្ញា។

បុគ្គលដែលមានឈ្មោះក្នុងពាក្យបណ្តឹង អាចប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងពីខ្លួនបាន ប្រសិនបើមានការបើកការស៊ើបសួរ បន្ទាប់ពីមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហើយក្រោយមកចៅក្រមស៊ើបសួរបានលើកលែងចោទប្រកាន់ កាលបើនីតិវិធីបានធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា។[42]

**កថាខណ្ឌទី២ អធិបញ្ញារបស់នាយយ៉ានានុក្រម**

ក្រោយតែពីព្រះរាជអាជ្ញាជាតួអង្គធ្វើការចោទប្រកាន់នេះ នៅពេលមានករណីដែលមានអង្គហេតុ ជាបទល្មើសព្រហ្មទណ្ឌមានភាពមិនប្រក្រតី ដែលសង្គមយល់ឃើញថា ប៉ះពាល់ដល់ប្រយោជន៍សង្គម ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈជាដើម។ ក្នុងករណីទាំងនេះ នៅពេលដែល

---

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤១។
[41] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤០។
[42] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤២។

អយ្យការអមសាលាដំបូងសម្រេចធ្វើការមិនចោទប្រកាន់ ឬតម្កល់ទុកមិនចាត់ការ ឬក្នុងករណីដែលមានអង្គហេតុជារឿងព្រហ្មទណ្ឌដែលអ្នកមាននាយឋានានុក្រម យល់ឃើញថាចាំបាច់ក្នុងករណីធ្វើអធិបញ្ញាទៅកាន់អយ្យការ ដើម្បីធ្វើការចោទប្រកាន់ភ្លាមៗនោះ គឺព្រះរាជអាជ្ញាដែលស្ថិតក្រោមអំណាច ក៏ដូចជាការបង្គាប់បញ្ជានោះ គឺជាចាំបាច់ត្រូវគោរពតាម។ ចំពោះតួអង្គដែលជានាយឋានានុក្រម មានសិទ្ធិអំណាចក្នុងការធ្វើអធិបញ្ញានេះរួមមាន៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ តួអង្គទាំងពីរនេះ គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មាននាយឋានានុក្រមលើគេ។

### ១. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

នៅក្នុងចំណុចនេះ តួនាទីរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញាទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានន័យថាព្រះរាជអាជ្ញានៅសាលាដំបូងតាមបណ្ដារាជធានី-ខេត្តត្រូវស្ថិតក្រោមការបង្គាប់បញ្ជា និងការពិន័យលើព្រះរាជអាជ្ញា ព្រះរាជអាជ្ញាវងណាដែលធ្វើខុសទៅនឹងច្បាប់ ឬក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗ។ ចំពោះដំណាក់កាលនៃការបើកស៊ើបសួរនេះដែរ យើងដឹងរួចមកហើយថា គឺទាល់តែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាទើបចៅក្រមស៊ើបសួរមានអំណាចក៏ដូចជាសមត្ថកិច្ចក្នុងការបើកនីតិវិធីស៊ើបសួរនេះបាន តែក្នុងករណីមួយថា ក្នុងរឿងក្ដីមួយដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិមតែព្រះរាជអាជ្ញាមិនចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដោយមានការជូនដំណឹងពីចៅក្រមស៊ើបសួរត្រង់ចំណុចនេះ ចៅក្រមស៊ើបសួរអាចប្ដឹងទៅអគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រម ក្នុងករណីនេះអគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ថាជាការគួរ។ ក្នុងករណីនេះ ថ្វីត្បិតតែអគ្គព្រះរាជអាជ្ញា មានអំណាចចាត់ឱ្យព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនធ្វើការចោទប្រកាន់ ឬចេញដីកាសន្និដ្ឋានពិតមែន អគ្គព្រះរាជអាជ្ញាគ្មានសិទ្ធិឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកមិនចាត់ការបានទេ។[43]

### ២. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បន្ទាប់បានដឹងថា អគ្គព្រះរាជអាជ្ញាជានាយឋានានុក្រមមានអំណាចលើចៅក្រមអយ្យការទាំងឡាយ ដែលស្ថិតក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ក្នុងនោះដែរ គួរគប្បីដឹងដែរថា បន្ទាប់ពីអគ្គព្រះរាជអាជ្ញា គឺនៅមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជានាយឋានានុក្រមលើគេ ដោយគាត់អាចប្ដឹងបរិហារទៅអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួន

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៩។

បានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ មួយវិញទៀត រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់ទុកមិនចាត់ការនូវរឿងព្រហ្មទណ្ឌណាមួយបានឡើយ។ ហើយចៅក្រមអយ្យការគ្រប់រូប ត្រូវតែគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម។ ប៉ុន្តែ នៅក្នុងសវនាការ ចៅក្រមអយ្យការធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរីតាមដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចធ្វើចំពោះចៅក្រមអយ្យការដោយសារតែវាចាររបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[44]

**កថាខណ្ឌទី៣ ការស្នើសុំដោយយុត្តាធិការព្រហ្មទណ្ឌ**

បន្ទាប់ពីបានសិក្សារួចមកថា ការដែលអាចនាំឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមមាន៖ ការដាក់ពាក្យបណ្ដឹង និងអធិបញ្ញារបស់នាយឋានានុក្រមរួចមក នោះយើងក៏មិនភ្លេចដែរ ចំពោះវិធានការមួយទៀត គឺតាមរយៈការស្នើសុំដោយយុត្តាធិការព្រហ្មទណ្ឌ។ ការស្នើសុំនេះមានពីរផងដែរ គឺការស្នើសុំឱ្យស៊ើបសួរបន្ថែមដោយចៅក្រមស៊ើបសួរ និងការបញ្ជូនរឿងឱ្យបើកការស៊ើបសួរដោយចៅក្រមជំនុំជម្រះ។

**១. ការស្នើសុំឱ្យស៊ើបសួរបន្ថែមដោយចៅក្រមស៊ើបសួរ**

នៅក្នុងការស៊ើបសួរនេះផងដែរ នៅក្នុងករណីដែលការស៊ើបសួរបស់ចៅក្រមស៊ើបសួរនេះប្រសិនបើមានលេចឡើងនូវអង្គហេតុថ្មី ដែលជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរនេះចៅក្រមស៊ើបសួរខ្លួនឯង ត្រូវជូនដំណឹងអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ហើយព្រះរាជអាជ្ញាក៏អាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ ធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែមនេះទេ ចៅក្រមស៊ើបសួរ ឬគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ មួយវិញទៀត ចៅក្រមស៊ើបសួរក៏មិនចាំបាច់ក្នុងការសុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីដែលរកឃើញនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។[45]

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៩។
[45] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៥។

### ២. ការបញ្ជូនរឿងឱ្យស៊ើបសួរដោយចៅក្រមជំនុំជម្រះ

នៅក្នុងពេលនៃការបើកការជំនុំជម្រះនេះរួច ចៅក្រមជំនុំជម្រះគាត់យល់ឃើញថាមិនទាន់មានភាពគ្រប់គ្រាន់ ឬខ្វះខាតព័ត៌មានដែលនាំឱ្យតុលាការមិនអាចវិនិច្ឆ័យបាន ចៅក្រមជំនុំជម្រះចាត់អោយមានការស្រាវជ្រាវបន្ថែមទៀត។ ក្នុងការបញ្ជូនរឿងឱ្យបើកការស៊ើបសួរដោយចៅក្រមជំនុំជម្រះនេះ គឺសំដៅអំពីព័ត៌មានបន្ថែមដែលបង្គាប់ដោយតុលាការ ថាប្រសិនបើយល់ឃើញថាការស្រាវជ្រាវថ្មីជាការចាំបាច់តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម។ នៅក្នុងករណីមួយផងដែរ ដែលក្រមនីតិវិធីបានបញ្ញត្តិ ប្រសិនបើតុលាការទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមនៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពសាំញ៉ាំនៃរឿងទាមទារជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។[46] ចំពោះអ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមនេះរួមមាន៖

- ប្រធានសវនាការ
- ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព
- ចៅក្រមដទៃទៀតនៃតុលាការជាន់ដំបូង។

សាលក្រមដែលបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ។ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាច៖

- ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការ ឬលើគ្រប់វិសាលភាពនៃដែនដីជាតិ
- ស្តាប់ចម្លើយសាក្សី
- ធ្វើការឆែកឆេរ
- ចាប់យកវត្ថុតាង
- បង្គាប់ឱ្យធ្វើកោសលវិច័យ។

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣០៤ កថាខណ្ឌទី១១។

ដើម្បីអាចអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យសួរជំនួសបានដែរ។[47]

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣៣៩។

# ជំពូកទី២
# អំណាចសំខាន់ៗលើការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ

ក្រោយពីបានសិក្សា ពីជំពូកទី១ ទាក់ទងនឹងមូលដ្ឋានគ្រឹះនៃការស៊ើបសួររួចមក បានដឹងថាអំពីចៅក្រមស៊ើបសួរជាអ្នកណា គេបង្កើតឱ្យមានប្រព័ន្ធចៅក្រមស៊ើបសួរនេះក្នុងគោលបំណងអ្វី ហើយចៅក្រមស៊ើបសួរគាត់មានសមត្ថកិច្ចអ្វីខ្លះក្នុងកិច្ចបើកការស៊ើបសួរនេះដែលត្រូវតែបំពេញ ក៏ដូចជាសិទ្ធិអំណាចដែលច្បាប់ប្រគល់ឱ្យ។ មួយវិញទៀតប្រភពចម្បងដែលអាចឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលទាំងនេះជាមូលហេតុនាំឱ្យចៅក្រមស៊ើបសួរមានអំណាច ក៏ដូចជាសិទ្ធិអំណាចមួយចំនួន ក្នុងការបើកការស៊ើបសួរដើម្បីធានាដល់ការស្វែងរកការពិតនៃអង្គហេតុជាបទល្មើសដែលទាំងនេះហើយ ជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះប្រកបដោយយុត្តិធម៌។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការស៊ើបសួរមានប្រសិទ្ធិភាពនោះ ចៅក្រមស៊ើបសួរគាត់បំពេញកិច្ចស្រាវជ្រាវដោយប្រើប្រាស់អំណាចដែលខ្លួនមាន ដើម្បីធ្វើការស៊ើបសួរ ដោយផ្អែកលើអំណាចមួយចំនួនដែល នឹងធ្វើការអត្ថាធិប្បាយខាងក្រោមនេះរួមមាន៖ អំណាចស្រាវជ្រាវដោយខ្លួនឯងផ្ទាល់ អំណាចស្រាវជ្រាវតាមដីកាចាត់ឱ្យស៊ើបសួរជំនួស និងអំណាចស្រាវជ្រាវតាមការស្នើសុំ។

## ផ្នែកទី១ អំណាចស្រាវជ្រាវដោយខ្លួនឯងផ្ទាល់

ដើម្បីធ្វើការបកស្រាយអំណាចក្នុងការស្រាវជ្រាវដោយខ្លួនឯងនេះ ដោយត្រូវគម្បីដឹងថា ចៅក្រមស៊ើបសួរ គឺគាត់មានសិទ្ធិអំណាចក្នុងការបំពេញកិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិត។[48] ដូច្នេះគាត់ដឹកនាំដោយសេរី និងឯករាជ្យនូវកិច្ចស៊ើបសួររបស់ខ្លួន និងមិនទទួលអធិបញ្ញាពីភាគី ឬអាជ្ញាធរណាមួយឡើយ។ កិច្ចស្រាវជ្រាវដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ មិនមានភាពខុសប្លែកពីកិច្ចដែលបំពេញដោយនគរបាលទេ ព្រោះក្នុងករណីនេះ វាជាកិច្ចបង្ហាញនូវភស្តុតាងដល់តុលាការ។ ព្រះរាជអាជ្ញា អាចជួយគ្រប់កិច្ចស៊ើបសួរ និងអាចសុំឱ្យមានកិច្ចស៊ើបសួរនេះទៅចៅក្រមស៊ើបសួរ។

### កថាខណ្ឌទី១ អង្គហេតុដែលមានសញ្ញាណធាតុផ្សំបទល្មើស

ដូចដែលបានសិក្សារួចមកហើយថា ក្នុងអំពើអាចចាត់ទុកជាបទល្មើសមួយបាន គឺត្រូវគោរពនូវធាតុផ្សំបទល្មើស រួមមាន៖ ធាតុអន្តោម័ត ធាតុសត្យានុម័ត និងធាតុនីត្យានុកូល។ អាចធ្វើការ

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៧។

ស្រាវជ្រាវបាន គឺទាល់តែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទើបចៅក្រមស៊ើបសួរមានអំណាចការបើកការស៊ើបសួរ យើងត្រូវគិតពីអំពើដែលបានប្រព្រឹត្តក៏ដូចជាចារិកគ្រោះថ្នាក់នៃអំពើនោះ ជាសញ្ញាណនៃបទល្មើស។ ការស្រាវជ្រាវនេះ គឺរកឱ្យឃើញនូវភាពពិតនៃអង្គហេតុ រួមមានស៊ើបសួរទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ ពាក្យថាភស្តុតាងដាក់បន្ទុកនេះ និងភស្តុតាងដោះបន្ទុកនេះ ដោយយោងទៅលើ កម្មវត្ថុនៃការចោទប្រកាន់ គេអាចឃើញនូវស្ថាន ឬខណៈទាំងឡាយរបស់ជនជាចោទដែលបានប្រព្រឹត្តរួចហើយ ហើយនឹងអ្វីៗដែលបានបន្សល់ទុកពីអំពើនោះ ក្លាយជាកម្មវត្ថុនៃការចោទប្រកាន់។ ពីព្រោះថាការចោទប្រកាន់ទៅលើជនណាម្នាក់ ស្ថានប័នមានសមត្ថកិច្ចត្រូវតែមានភស្តុតាងសមល្មមដែលអាចយល់បានក្នុងដំណាក់កាលនៃ នីតិវិធីការចោទប្រកាន់។ ភស្តុតាងនៅក្នុងក្រុមនេះគេសំអាងសំខាន់នៅ ការផ្តើមចោទប្រកាន់ពីដំបូង និងដោយយោងទៅលើកម្មវត្ថុនៃការចោទប្រកាន់នោះភស្តុតាងចែកចេញពីរប្រភេទ គឺដាក់បន្ទុក និងដោះបន្ទុក។ ចំពោះភស្តុតាងដាក់បន្ទុក គឺជាភស្តុតាងទាំងឡាយណាដែលធ្វើឱ្យមានពិរុទ្ធភាពលើជនជាប់ចោទ ឬភស្តុតាងដែលធ្វើឱ្យមានការទទួលខុសត្រូវនូវកំហុសរបស់ជនដែលបានប្រព្រឹត្តបទល្មើសនោះ។ ទំនាក់នាក់ទំនងដែលពាក់ព័ន្ធនឹងភស្តុតាងរបៀបនេះ វាឈរនៅលើមូលដ្ឋាននៃការចោទប្រកាន់ ឬក៏ខណៈទាំងឡាយណាដែលធ្វើឱ្យមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលដល់ការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ចំណែកឯ ភស្តុតាងដោះបន្ទុកវិញ គឺជាភស្តុតាងទាំងឡាយណាដែលច្រានចោលការចោទប្រកាន់ដោយ កំណត់បាននូវភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬក៏ភស្តុងនោះធ្វើឱ្យថយចុះកាន់តែតូចនូវពិរុទ្ធភាព។ តែអាចនិយាយបានទៀតថា ជាភស្តុតាងដែលកំណត់បាននូវខណៈនានាប្រកបដោយមានស្ថានសម្រាលក្នុងការទទួលខុសត្រូវរបស់ជនជាប់ចោទបានផងដែរ។ ចំពោះការមានការបែកចែកផ្នែកដាក់បន្ទុក និងដោះបន្ទុកនេះ វាមានលក្ខខណ្ឌដោយឡែកត្រង់ថា គ្រប់ភស្តុតាងវាពុំមានចរិតដូចគ្នាទេ ប៉ុន្តែវាមានព្រំដែនរបស់វាច្បាស់លាស់ថាភស្តុតាងជាច្រើន វានាំមកនូវចរិតដាក់បន្ទុក និងចរិតដោះបន្ទុកក្នុងពេលតែមួយ។[49]

ក្នុងករណីក្រោយពីការស៊ើបសួរចប់ ចៅក្រមស៊ើបសួរគាត់រកមិនឃើញថាមានបទល្មើស ឬធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ឬគ្រប់គ្មានយ៉ាងណាចៅក្រមស៊ើបសួរត្រូវចេញដីកាមួយដើម្បីបិទ គឺការចេញដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាលើកលែងការចោទប្រកាន់។[50] ត្រង់ចំណុចនេះ ចំពោះដីកាសន្និដ្ឋានដែលព្រះរាជអាជ្ញាបញ្ជូនឱ្យស៊ើប

---

[49] អ៊ុន បូផា, *នីតិភស្តុតាង*, ២០១២,៣៥។

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៤៧។

សួរត្រូវបានបែងចែកជាពីរ គឺអង្គហេតុក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងអង្គហេតុគ្មានក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។

### ១. អង្គហេតុក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ក្រោយពីបានយល់អំពីមូលហេតុដែលនាំឱ្យចៅក្រមមានអំណាចក្នុងការស៊ើបសួររួចមកកិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរនេះផងដែរ ក៏មិនមានសភាពខុសប្លែកពីកិច្ចដែលបំពេញដោយនគរបាលយុត្តិធម៌ទេ ព្រោះថាករណីទាំងពីរនេះវាជាកិច្ចបង្ហាញភស្តុតាងដល់តុលាការ។ ដោយការស្រាវជ្រាវនេះ ចៅក្រមស៊ើបសួរ អាចបើកការស៊ើបសួរបានត្រឹមកម្រិតដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ការបើកស៊ើបសួរនេះត្រូវតែមានដីកាសន្និដ្ឋានពីព្រះរាជអាជ្ញា ទើបចៅក្រមស៊ើបសួរមានអំណាចបើកការស៊ើបសួរនេះបាន។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងនឹងអញ្ញាតជន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនអាចកំណត់បាន។
- ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទនិងហត្ថលេខា។ ទម្រង់ការបែបនេះត្រូវតែមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវចាត់ទុកជាមោឃៈ។[51]

ចំពោះការស្រាវជ្រាវនេះ ចៅក្រមស៊ើបសួរបំពេញតាមកិច្ចមួយចំនួនដូចខាងក្រោម៖

#### ១.១. ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ នូវបុគ្គលគ្រប់រូបដែលមានតម្រុយពិរុទ្ធភាពច្បាស់លាស់ ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើសទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះក្នុងឋានៈជា ចារី ជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិត។[52] ចំពោះការដាក់

---
[51] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៤។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៦។

ឱ្យស្ថិតក្រោមការត្រួតពិនិត្យ គឺជាវិធីមួយដែលទើបតែមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះប៉ុណ្ណោះ ដោយនេះគឺជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ។ ផងដែរ ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យធ្វើនៅពេលចូលបង្ហាញខ្លួនលើដំបូង ដោយចៅក្រមស៊ើបសួរត្រូវអនុវត្តៈ

- ពិនិត្យអត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រាប់ជនត្រូវចោទពីរឿងរ៉ាវដែលចោទប្រកាន់
- ប្រាប់ពីឈ្មោះបទល្មើសដែលកំណត់ក្នុងច្បាប់
- ប្រាប់ជនត្រូវចោទថា អាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី
- ប្រាប់ពីសិទ្ធិរបស់ជត្រូវចោទក្នុងការជ្រើសរើសមេធាវី ឬសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនដោយអនុវត្តតាមច្បាប់លក្ខន្តិក:មេធាវី។
- ចំពោះជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងក្នុងកថាខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិក:មេធាវី។[53]

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ ហើយអ្នកបកប្រែត្រូវធ្វើសម្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួនថាខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ឬសាក្សីទេ។[54]

### ១.២. ការសួរចម្លើយ និងស្តាប់ចម្លើយរបស់ភាគីពាក់ព័ន្ធ

- ការសួរចម្លើយជនត្រូវចោទ

ការសួចម្លើយជនត្រូវចោទ អាចធ្វើឡើងនៅចំពោះមុខមេធាវីរបស់ជនត្រូវចោទ។ ប៉ុន្តែប្រសិនបើមេធាវិត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវី។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបាន ដោយមិនចាំបាច់កោះហៅមេធាវីបាន ដូចជាមានគ្រោះថ្នាក់បណ្តាលឱ្យស្លាប់ ឬមានការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏មានវត្តមានដែរ ហើយអាចលើកសំណួរទៅជនត្រូវចោទបាន បន្ទាប់ពីការ

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៣។

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៤៤។

អនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិឱ្យជនត្រូវចោទស្នើសុំឱ្យចៅក្រមស៊ើបសួរសួរចម្លើយខ្លួន ឬសួរតទល់ កាលណាថេរវេលា ៤ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមកោះហៅក្នុងថិរវេលា ១ខែ បន្ទាប់ពីការសុំទេជនត្រូវចោទអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ ចំពោះកំណត់ហេតុសួរចម្លើយនេះត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក៏ដូចជាជនត្រូវចោទផងដែរ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃការស៊ើបសួរ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវស្តាប់ដោយមន្ត្រីនគរបាលយុត្តិធម៌ លុះត្រាតែគាត់បានសុំ។ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលជំនួយពីមេធាវីក្នុងពេលកំពុងស្តាប់ចម្លើយ ដោយចៅក្រមស៊ើបសួរ។ ដូច្នេះមេធាវីនេះ ត្រូវទទួលជំនួយពីមេធាវីក្នុងពេលកំពុងស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ។ ដូច្នេះមេធាវីនេះ ត្រូវទទួលបានការកោះហៅក្នុងថិរវេលា ៥ថ្ងៃមុនការស្តាប់ចម្លើយ មានសិទ្ធិពិនិត្យសំណុំរឿងក្នុងថិរវេលានេះ និងអាចទទួលបានដោយចេញសោហ៊ុយខ្លួនឯងនូវឯកសារថតចម្លង និងលិខិតផ្សេងៗទៀតនៃនីតិវិធី ដោយមានការអនុញ្ញាតពីចៅក្រម។ ការស្តាប់ចម្លើយអាចធ្វើបានដោយពុំចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន និងពុំចាំបាច់កោះហៅមេធាវី ក្នុងករណីបន្ទាន់ (គ្រោះថ្នាក់ដល់អាយុជីវិត ហានិភ័យនៃការបាត់បង់តម្រុយភស្តុតាង)។ ដូចពេលសួរចម្លើយ ជនត្រូវចោទដែរ ព្រះរាជអាជ្ញាអាចមានវត្តមាន។ ព្រះរាជអាជ្ញា និងមេធាវីរបស់ជនរងគ្រោះអាចសួរជនរងគ្រោះបានដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ។

- ការស្តាប់ចម្លើយសាក្សី

សាក្សីអាចត្រូវបានគេឱ្យនិយមន័យបានថា ជាបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុ ដែលជាកម្មវត្ថុនៃការចោទប្រកាន់ និងអាចផ្តល់ព័ត៌មានដែលជាប្រយោជន៍ ដល់ការបង្ហាញការពិតទៅចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថា សាក្សីមានសារៈសំខាន់គាត់អាចបញ្ជាឱ្យកោះហៅសាក្សីនោះ។ ដូច្នេះសាក្សីមានកាតព្វកិច្ច ៣យ៉ាង៖ ចូលបង្ហាញខ្លួនភ្លាម ធ្វើពាក្យសម្បថ (ត្រូវបានរួចផុតពីធ្វើពាក្យសម្បថ បុគ្គលដែលស្និតជាមួយជនត្រូវចោទ ដូចជាបុព្វញាតិបច្ឆាញាតិ ឬបងប្អូនជាដើម។[55] បើសាក្សីបដិសេធមិនបង្ហាញខ្លួនចៅក្រមស៊ើបសួរសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន ដោយចេញបញ្ជាឱ្យចូលខ្លួនបង្ហាញខ្លួន ដែលមានចុះពីអត្ត

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៥៦។

សញ្ញាណរបស់សាក្សីកាលបរិច្ឆេទចេញបញ្ជា ហត្ថលេខា និងត្រារបស់ចៅក្រម។ ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចហៅអ្នកបកប្រែដើម្បីស្ដាប់ចម្លើយរបស់សាក្សី។ បើសាក្សីមានជំងឺ ឬមិនអាចធ្វើដំណើរមកបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចទៅកាន់ផ្ទះរបស់សាក្សី ឬទីកន្លែងដែលសាក្សីនោះនៅដើម្បីទទួលយកចម្លើយ។ សាក្សីមិនមែនភាគីនៃការស៊ើបសួរ គាត់មិនទទួលបានសិទ្ធិការពារខ្លួន ដូច្នេះគាត់ត្រូវបានស្ដាប់ចម្លើយតែម្នាក់ឯង ដោយចៅក្រមស៊ើបសួរ។ ប៉ុន្តែគាត់អាចជាកម្មវត្ថុនៃការស៊ើបសួរតទល់ជាមួយ និងភាគីក្នុងសំណុំរឿង។

### ១.៣. ការចុះដល់ទីកន្លែងកើតហេតុ

ការចុះដល់ទីកន្លែងកើតហេតុឆ្លើយតបទៅ នឹងគោលដៅតែមួយដូចក្នុងក្របខណ្ឌនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ដែរ ដូចជាធ្វើការពិនិត្យកត់ត្រា ផ្គុំអង្គហេតុឡើងវិញ ឆែកឆេរ ឬបំពេញគ្រប់កិច្ចស៊ើបសួរផ្សេងទៀតទាំងអស់។ ដើម្បីបំពេញគ្រប់កិច្ចស៊ើបសួរ ចៅក្រមអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីរបស់សាលាដំបូងដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ថាមានប្រយោជន៍។ គាត់ជូនដំណឹងទៅព្រះរាជអាជ្ញាដែលអាចរួមដំណើរជាមួយខ្លួនបាន។ ដោយមានជំនួយក្រឡាបញ្ជីក្នុងពេលចុះដល់ទីកន្លែង ហើយចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីការចុះដល់ទីកន្លែង និងស្ដីពិកិច្ចដែលបានបំពេញនៅនឹងកន្លែង។ ម្យ៉ាងទៀត បើចាំបាច់នៃការស៊ើបសួរតម្រូវ ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីទាំងមូល ដោយជូនដំណឹងជាមុនទៅព្រះរាជអាជ្ញាអមសាលាដំបូង នៅក្នុងដែនដីដែលខ្លួនដំណើរទៅកាន់នោះ។

### ១.៤. ការឆែកឆេរ និងចាប់យកវត្ថុតាង

ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាងនេះ ផ្ទុយពីគំនិតដែលទទួលបានជារួម ការស៊ើបសួរមិនអនុញ្ញាតឱ្យធ្វើការឆែកឆេរគញ្ជរប់ទីកន្លែងដោយពុំមានលក្ខខណ្ឌ ដូចក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្ដែងនោះទេ។ ក្នុងក្របខណ្ឌនៃការស៊ើបសួរការឆែកឆេរត្រូវគោរពពេលម៉ោងដែលច្បាប់កំណត់ដូចក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្ដែងដែរ គឺចន្លោះម៉ោង ១៨ល្ងាច និងម៉ោង ៦ព្រឹក។ គោលការណ៍នេះត្រូវបានលើកលែងក្នុងករណីឆែកឆេរ ដែលបើកឱ្យសាធារណៈជនកន្លែងដែលមានបុគ្គលប្រព្រឹត្តព្យសនកម្ម និងកន្លែងបុគ្គលលក់ ឬប្រើប្រាស់គ្រឿងញៀន។ ដូចគ្នានេះដែរ ការឆែកឆេរក្នុងការិយាល័យមេធាវី ត្រូវធ្វើឡើងដោយមានវត្តមានប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់។ ចំពោះអ្នកកាន់កាប់ទីកន្លែង គឺត្រូវមានវត្តមាន ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវមាន

សាក្សីពីរនាក់ដែលបានចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសាក្សីនោះមិនអាចជាអាវុធហត្ថ ឬនគរបាលទេ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលត្រូវមានចុះអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ និងដោយយថាហេតុ អត្តសញ្ញាណរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់។ ជាចុងក្រោយ កំណត់ហេតុនេះត្រូវចុះហត្ថលេខាពីចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

ចំពោះការចាប់យកវត្ថុតាងវិញ ច្បាប់អនុញ្ញាតឱ្យចៅក្រមស៊ើបសួរចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ នៅពេលក្រោយមកទៀត ដើម្បីឱ្យមានភាពប្រាកដថាវត្ថុដែលបានចាប់យកមកនោះពិតជាវត្ថុដែលបានចាប់យកក្នុងសំណុំរឿងនីតិវិធី វត្ថុ ឬឯកសារត្រូវស្ថិតក្រោមទម្រង់តែមួយនៃការបញ្ជាក់អត្តសញ្ញាណ ដូចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងដែរ។ ជាអាទិ៍វត្ថុត្រូវធ្វើបញ្ជីសាពើភ័ណ្ឌ និងមានបិទស្លាកបន្ទាប់ពីបានបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី។ នៅគ្រប់ពេលនៃការស៊ើបសួរ ចៅក្រមមានអំណាចប្រគល់សងវត្ថុដែលបានចាប់យកនោះវិញ។ គាត់អាចធ្វើដោយឯកឯងបន្ទាប់មានយោបល់ពីព្រះរាជអាជ្ញា ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដោយមានការស្នើសុំពីគូភាគី ឬពីគ្រប់បុគ្គលទាំងអស់ដែលអះអាងថាមានសិទ្ធិលើវត្ថុដែលបានចាប់។ គាត់អាចធ្វើការបដិសេធប្រគល់សងវត្ថុដែលសុំ ដោយផ្អែកលើមូលហេតុដែលបានរៀបរាប់ដោយច្បាប់នៅពេលដែលការប្រគល់វត្ថុដែលជាឧបសគ្គដល់ការសម្តែងឱ្យឃើញការពិត នៅពេលដែលវត្ថុមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិ និងនៅពេលដែលត្រូវបានកាន់កាប់ដោយខុសច្បាប់។ គាត់ត្រូវចេញសេចក្តីសម្រេចដែលទាក់ទងនឹងការប្រគល់សងនេះ តាមរយៈដីកាដែលមានសំអាងហេតុដែលបើកផ្លូវបណ្តឹងឧទ្ធរណ៍។

### ១.៤. ការធ្វើកោសលវិច័យ

ការធ្វើកោសលវិច័យនេះ គឺជាពិនិត្យធ្វើឡើងដោយអ្នកជំនាញចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសុំយោបល់បំភ្លឺលើបញ្ហាបច្ចេកទេសសុទ្ធសាធ លើវិស័យផ្សេងៗនៃវិជ្ជសាស្ត្រ ពេទ្យវិជ្ជានីត្យានុកូល ពិន្ទុវិជ្ជា ជីវសាស្ត្រ ចិត្តវិជ្ជា អង្គុលីទស្សន៍ អង្គុលីលេខ ព័ត៌មានវិទ្យា។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ អាចបញ្ជាឱ្យមានកោសលវិច័យ និងចាត់តាំងអ្នកជំនាញភ្លាមតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬគូភាគី។ ចំពោះការបដិសេដសំណើរសុំនេះត្រូវធ្វើឡើងរយៈដីកាដោយមានសំអាងហេតុ ដែលត្រូវចេញក្នុងរយៈពេល ៥ថ្ងៃប្រសិនបើពាក្យសុំចេញពីព្រះរាជអាជ្ញា និងមួយខែ

ប្រសិនបើចេញពី ជនត្រូវចោទ ឬភាគីរដ្ឋប្បវេណី ជាដីកាបើផ្លូវបណ្ដឹងឧទ្ធរណ៍។ ដោយឡែកអ្នកជំនាញ គឺត្រូវជ្រើសរើសពីបញ្ជីអ្នកជំនាញជាតិដែលធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តធម៌។ បែបបទនៃការចុះឈ្មោះ និងលុបឈ្មោះពីបញ្ជីត្រូវកំណត់ដោយប្រកាស។ អ្នកជំនាញដែលត្រូវចុះក្នុងបញ្ជីនេះត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការដោយស្មោះត្រង់។ បើសិនចៅក្រមចាត់អ្នកបច្ចេកទេសណាម្នាក់មិនមានឈ្មោះក្នុងបញ្ជីទេនោះគាត់ត្រូវឱ្យអ្នកបច្ចេកទេសនោះសម្បថនៅចំពោះមុខគាត់។ សេចក្ដីសម្រេចដែលបញ្ជាឱ្យមានកោសលវិច័យ ត្រូវបញ្ជាក់បេសកម្មរបស់អ្នកជំនាញ ដែលទាក់ទងតែនឹងការពិនិត្យបញ្ហាដែលមានលក្ខណៈបច្ចេកទេស ចិរវេលាដែលអ្នកបច្ចេកទេសត្រូវបំពេញបេសកម្មដែលចិរវេលានេះអាចពន្យាពេលបានដោយសេចក្ដីសម្រេចមានសំអាងហេតុ ព្រមទាំងការយឺតយ៉ាវដែលធ្វើឱ្យមានការផ្លាស់ប្ដូរអ្នកជំនាញ និងការលុបឈ្មោះចេញពីបញ្ជីអ្នកជំនាញ។ ចៅក្រមស៊ើបសួរអាចតែងតាំងអ្នកជំនាញច្រើន។ ក្នុងករណីនេះបើអ្នកជំនាញមានយោបល់ផ្សេងគ្នាអ្នកជំនាញនីមួយៗត្រូវសរសេរប្រាប់ពីយោបល់របស់ខ្លួនផ្ទាល់ ព្រមទាំងដាក់លក្ខខណ្ឌ។ អ្នកជំនាញអាចសុំអនុញ្ញាតពីចៅក្រមស៊ើបសួរ នូវលទ្ធភាពស្ដាប់ចម្លើយ ជនត្រូវចោទដោយមានវត្តមានរបស់មេធាវីលើកលែងតែកោសលវិច័យនោះជាការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ។ អ្នកជំនាញក៏អាចស្ដាប់ចម្លើយគ្រប់បុគ្គលទាំងអស់ក្រៅពីជនត្រូវចោទ។ នៅពេលបញ្ចប់កោសលវិច័យ អ្នកជំនាញដែលត្រូវបានចាត់តាំងត្រូវប្រគល់ជូនចៅក្រមស៊ើបសួរនូវរបាយការណ៍ដែលបានពិពណ៌នាអំពីប្រតិបត្តិការរបស់ខ្លួន និងសេចក្ដីសន្និដ្ឋាន។ នៅពេលដែលបានធ្វើការជូនដំណឹងរួចហើយ ចៅក្រមទុពេលវេលាឱ្យភាគីដើម្បីស្នើសុំជាលាយលក្ខអក្សរ និងមានមូលហេតុត្រឹមត្រូវ ឱ្យធ្វើកោសលវិច័យបន្ថែម ឬឱ្យធ្វើប្រតិកោសលវិច័យ។ ចិរវេលាមិនអាចតិចជាង ១០ថ្ងៃបានទេ។ បើពាក្យសុំធ្វើឡើងដោយព្រះរាជអាជ្ញា ចៅក្រមមានរយៈពេល ៥ថ្ងៃដើម្បីចេញសេចក្ដីសម្រេច។ ចិរវេលានេះនឹងត្រូវលើកទៅ១ ខែបើពាក្យសុំធ្វើធ្វើឡើងដោយជនត្រូវចោទឬដើមបណ្ដឹងរដ្ឋប្បវេណី។ បើពុំសម្រេចក្នុងចិរវេលានេះទេ ភាគីអាចប្ដឹងទៅសភាស៊ើបសួរដោយផ្ទាល់។

### ១.៥. ការស្ដាប់ទូរស័ព្ទ

ចំពោះការស្ដាប់ចម្លើយនេះ គឺជាការស្ដាប់ និងការថតការសន្ទនាតាមទូរស័ព្ទការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារហ្វាក់ ឬសារអាំងទែរនេត។

មានតែចៅក្រមស៊ើបសួរដែលទទួលពាក្យបណ្ដឹងដោយស្របច្បាប់ប៉ុណ្ណោះ ដែលមានអំណាចបញ្ជាឱ្យមានការចាប់ការថត និងការចម្លងមកជាអក្សរនៃការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍។ ម្យ៉ាងទៀត គាត់អាចចុះដល់ទីកន្លែងដែលធ្វើការចាប់ និងការថតនេះ។ ប៉ុន្តែវិធានស៊ើបសួរនេះ ត្រូវតែចាំបាច់ដើម្បីបង្ហាដញការពិត និងត្រូវមានគ្រប់ធាតុនៃកំណត់អត្តសញ្ញាណនៃការទាក់ទងដែលចាប់ បទល្មើសដែលជាមូលហេតុនាំឱ្យមានការចាប់ និងចិរវេលានៃការចាប់នេះ។ ក្នុងការអនុវត្តសេចក្ដីសម្រេចទាំងនេះ គឺជាដីកាចាត់ឱ្យស៊ើបសួរជំនួសដែលជាក់លាក់ពិសេស ដែលប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ចំពោះសេចក្ដីសម្រេចនេះត្រូវមានចុះការចង្អុលបង្ហាញជាក់លាក់នៃឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវបានស្ដាប់ លេខទូរស័ព្ទបើពុំនោះទេ នឹងត្រូវមានមោឃភាពសណ្ដាប់ធ្នាប់សាធារណៈ។

**២. អង្គហេតុគ្មានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ចំពោះអង្គហេតុគ្មានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ មានន័យថាក្រោយពីបានបើកការស៊ើបសួររួចមកចៅក្រមស៊ើបសួរ បានពិនិត្យឃើញថាចំពោះអង្គហេតុក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាចំពោះបទល្មើសមួយដែលប្ដឹងឱ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរ។ ចៅក្រមស៊ើបសួរមិនមានសមត្ថកិច្ចលើអំពើដែលបាន ប្រព្រឹត្តបន្ទាប់ពីកាលបរិច្ឆេទនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ ដូច្នេះគាត់ត្រូវបញ្ជូនសំណុំរឿងរបស់ខ្លួនដើម្បី សុំដីកាសន្និដ្ឋានបន្ថែម។ ត្រង់ចំណុចនេះគឺចៅក្រមស៊ើបសួរពេលទទួលបានបណ្ដឹងពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអង្គហេតុនោះប៉ុណ្ណោះ ប្រសិនបើមានលេចចេញនូវអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប

សួរដំបូង។[56] មួយវិញទៀតនៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថិរវេលាយ៉ាងឆាប់បំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់មាត់តាមរយៈពាក្យសុំទោសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរនោះ។[57] ចៅក្រមស៊ើបសួរដែលទទួលពាក្យបណ្តឹងដោយត្រឹមត្រូវ មានករណីយកិច្ចត្រូវស៊ើបសួរលើបណ្តឹងនោះ។ ដូចនេះចៅក្រមស៊ើបសួរ មិនអាចបដិសេធ ឬយកលេសថាការស៊ើបសួរពុំអាចមានប្រយោជន៍ ការស៊ើបសួរពុំអាចទទួលបានលទ្ធផល ព្រោះអំពើនោះមិនមែនជាបទល្មើសដែលមានចែងក្នុងសេចក្តីសន្និដ្ឋាន ទោះបីជាអំពើល្មើសក៏ដោយ។ ក៏ប៉ុន្តែកាតព្វកិច្ចនេះមានកំណត់ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចផ្ទៀងផ្ទាត់សមត្ថកិច្ចសម្ភារៈ និងសមត្ថកិច្ចដែនដី។ ជាអាទិ៍ ចៅក្រមស៊ើបសួរមិនអាចប្រកាសថាខ្លួនពុំមានសមត្ថកិច្ចខាងដែនដី ដរាបណាចៅក្រមស៊ើបសួរមិនទាន់បានធ្វើការស្រាវជ្រាវចាំបាច់នានា ដើម្បីផ្ទៀងផ្ទាត់សមត្ថកិច្ចរបស់ខ្លួន ជាពិសេសប្រសិនបើគាត់ទទួលបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសរសេរថា ម្នាក់ក្នុងចំណោមជនសង្ស័យ និងដែលត្រូវបរិហាររស់នៅក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ទទួលបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវតែសម្រេចដោយយោងតាមសេចក្តីសន្និដ្ឋានរបស់អយ្យការ។ ក្នុងករណីផ្សេងទៀត ថ្វីបើវាជាសមត្ថកិច្ចតាមសាច់រឿងក្តី និងតាមដែនដីរបស់គាត់ពិតមែនប៉ុន្តែចៅក្រមស៊ើបសួរអាចបដិសេដមិនស៊ើបសួរបាន ដោយចេញដីកាដែលមានសំអាងហេតុ ក្នុងខណៈដែលចោទប្រកាន់ហាក់មិនអាចធ្វើទៅបាន។ **ឧទាហរណ៍:** ករណីរឿងមួយមិនអនុសញ្ញាតឱ្យមានការស៊ើបសួរ ប្រសិនបើអំពើមិនអាចចាត់ទុកជាបទល្មើស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាផុតរលត់ ឬរឿងរ៉ាវត្រូវបានវិនិច្ឆ័យរួចហើយ។ យោងទៅលើមូលហេតុទាក់ទង និងបណ្តឹងអាជ្ញាខ្លួនឯងផ្ទាល់ព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរនូវសេចក្តីសន្និដ្ឋានមិនស៊ើបសួរ ប្រសិនបើអំពើនេះត្រូវបាន

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៥។
[57] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៦។

បង្ហាញ ប៉ុន្តែវាមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចផ្សេងពីនេះ គាត់ត្រូវចេញដីដែលមានសំអាងហេតុ។[58]

**កថាខណ្ឌទី២ អង្គហេតុមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

យើងដឹងហើយថា រាល់មានអំពើដែលបំពានច្បាប់ណាមួយ គឺតែងមានការប៉ះពាល់ដល់សង្គម ក៏ដូចជាសមាជិកសង្គមណាមួយនៃអង្គហេតុ។ ប៉ុន្តែកម្រិតនៃទំហំនៃព្យសនកម្មមានភាពផ្សេងៗគ្នា។ អាស្រ័យហេតុ ទើបទាមទារឱ្យរដ្ឋមានវិធានការក្នុងការដោះស្រាយនូវបញ្ហានេះ ជាមួយនឹងអំពើដែលបំពានច្បាប់បង្កឱ្យមានការអន្តរាយ ណាមួយមានលក្ខណៈតិចតួច ឬខូចខាតលើសម្ភារៈត្រឹមកម្រិតសំណងជាប្រាក់។ មួយវិញទៀតប្រសិនបើអំពើនោះមានការអន្តរាយធ្ងន់ធ្ងរក្នុងដល់សង្គម ឬដល់សមាជិកសង្គមមិនត្រឹមកម្រិតដែលសំណងជាប្រាក់ប៉ុណ្ណោះទេ គឺច្បាប់ត្រូវផ្ដន្ទាទោសលើជនដែលប្រព្រឹត្តនោះ ក្នុងគោលបំណងឱ្យជនដែលប្រព្រឹត្តនោះរាងចាល មិនហ៊ានប្រព្រឹត្តអំពើនោះតទៅទៀត ហើយអាចមករួមរស់ក្នុងសង្គមវិញបាន។ ត្រង់ចំណុចទាំងនេះហើយដែលហេតុអាចឱ្យភាគីរងគ្រោះនៃអំពើបំពារបំពារនោះ មានលទ្ធភាពទាមទារនូវសំណងជំងឺចិត្តមកវិញបាន ដោយតាមរយៈការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះឯង។ ជាដំបូងជនរងគ្រោះនៃអង្គហេតុជាបទល្មើសមានសិទ្ធិដាក់ពាក្យបណ្ដឹង ប្រសិនជាយល់ថាខ្លួនជាជនរងគ្រោះនៃអង្គហេតុជាបទល្មើសនោះ។ នៅក្នុងបញ្ញត្តិដំបូងនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានយកចិត្តទុកដាក់ក្នុងការធានារ៉ាប់រងនូវជោគវាសនាជនរងគ្រោះ។ ក្នុងករណីនេះគេមិនអាចធ្វើការបដិសេដក្នុងការរៀបចំបណ្ដឹងតវ៉ាបានទេ ប្រសិនជនរងគ្រោះបានបង្ហាញខ្លួន។ ក៏ដូចគ្នានេះដែរ បើជនរងគ្រោះពុំបានទទួលដំណឹងអំពីការវិវត្តរបស់បណ្ដឹងនោះទេ គឺខ្លួនមានជម្រើសក្នុងការប្ដឹងទៅអគ្គព្រះរាជអាជ្ញា។ ប៉ុន្តែបណ្ដឹងនេះមិនសំដៅការបើកបណ្ដឹងអាជ្ញាទេ។ បណ្ដឹងអាជ្ញាអាចធ្វើបាន ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរ។

បណ្ដឹងរដ្ឋប្បវេណី គឺផ្ដោតទៅលើការទាមទារការជួសជុលព្យសនកម្មពីអ្នកដែលបានប្រព្រឹត្ត អ្នកសមគំនិត ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដោយមិនគិតពីប្រភេទនៃព្យសនកម្មដែលកើតចេញពីបទល្មើសដែលជនរងគ្រោះបានទទួលរង។ ក្នុងក្រមនីតិព្រហ្មទណ្ឌផងដែរ ក៏បានកំណត់អំពីលក្ខខណ្ឌនៃការជួសជុលនេះ ដែលអាចជាការបង់សំណងជំងឺចិត្ត ការប្រគល់សងនូវវត្ថុដែលខ្លួនបានយកពីជនរងគ្រោះ ការធ្វើឱ្យដូចសភាពដើមវិញនូវវត្ថុដែលគេបានបំផ្លិចបំផ្លាញ ដែល

[58] ឌី លីឡា និងខាន់ សុខា,មេរៀននីតិវិធីព្រហ្មទណ្ឌ, ៦៩។

មានអត្ថិភាពនៃព្យសនកម្មផ្ទាល់ ពិតប្រាកដដែលបានកើតឡើង និងក្នុងពេលបច្ចុប្បន្ន។ មានតែជនរងគ្រោះតែមួយគត់ដែលអាចប្រើប្រាស់សិទ្ធិសុំឱ្យជួសជុលសំណងព្យសនកម្ម ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន ប្រសិនបើជនខ្លួនគ្រោះជាតតិយជន ឬជានីតិជនដែលស្ថិតក្រោមរបបច្បាប់ការពារ។ ប្រសិនបើជនរងគ្រោះនៃបទល្មើសទទួលមរណៈភាព បណ្ដឹងអាចធ្វើឡើងដោយសិទ្ធិវន្តរបស់ខ្លួន។

## ១. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

ក្នុងការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះត្រូវគោរពតាមនីតិវិធីពីរ គឺដោយការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ និងការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវបណ្ដឹង។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ គឺសំដៅដល់ការការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្រោយពេលដែលការស៊ើបសួរត្រូវបានបើក ជាទូទៅ (តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) របស់ព្រះរាជអាជ្ញា។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺទាមទារឱ្យមានការគោរពច្បាស់លាស់ពីលក្ខខណ្ឌទើបទទួលបានគុណវុឌ្ឍិ ក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណីពេញសិទ្ធិ។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថា ជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។ ការតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើយ។ កាលណាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមលិខិត លិខិតនេះត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ កាលណាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងតាមផ្ទាល់មាត់ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។[59]ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ជាយន្តការចុងក្រោយដែលអនុញ្ញាតឱ្យជនរងគ្រោះអាចទទួលបានសំណងពីបទល្មើសព្រហ្មទណ្ឌបាន។ មួយវិញទៀត ចំពោះការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍នេះក៏ធ្វើឡើងនៅមុនការបើកស៊ើបសួរបានផងដែរ គឺតាមរយៈការប្ដឹងតាំងខ្លួនជាដើមបណ្ដឹងនៅចំពោះមុខអយ្យការ។

[59]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៧។

**១.១.ព្យសនកម្មផ្នែកសម្ភារៈ**

កាលដែលមានពាក្យប្តឹងសាមញ្ញមកកាន់អយ្យការ។ បណ្តឹងរដ្ឋប្បវេណីជាបណ្តឹងមួយមានគោលបំណងទាមទារឱ្យមានការជួសជុលព្យសនកម្ម ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីជនរងគ្រោះ និងគោលបំណងឱ្យជនរងគ្រោះទទួលបានសំណងធនល្មមនិងព្យសនកម្មដែលខ្លួនទទួលរង។ ព្យសនកម្មនោះរួមមាន ព្យសនកម្មផ្នែកសំភារៈ ព្យសនកម្មរូបកាយ និងព្យសនកម្មផ្លូវចិត្ត។ គឺនៅពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើសអំពី អំពើរបស់ជនល្មើសបណ្តាលឱ្យការប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងខូចខាតជាច្រើនដែលអំពើនេះបង្កឱ្យមានព្យសនកម្មផ្នែកសម្ភារៈដល់ជនរងគ្រោះ។ ក្នុងករណីនេះជនរងគ្រោះអាចទាមទារឱ្យសំណងព្យសនកម្មដែលខ្លួនទទួលរង។

**ក. ប្រភេទនៃព្យសនកម្មសម្ភារៈ**

ព្យសនកម្មផ្នែកសម្ភារៈ រួមបញ្ចូលទាំងការបាត់បង់ទ្រព្យសម្បត្តិ ឬចំណូល។[60]ព្យសនកម្មនេះអាចធ្វើការទាមទារបានតាមទំហំនៃការខូចខាត។ ចំពោះព្យសនកម្មសម្ភារៈ គេមិនត្រឹមរាប់បញ្ចូលនូវព្យសកម្មដោយផ្ទាល់ទេ តែគេថែមទាំងយល់ឃើញថា ព្យសកម្មដែលបង្កឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះដូចជាកេរ្តិ៍ឈ្មោះរបស់តួសម្តែង សិល្បករជាដើម។ ព្យសនកម្មបែបនេះវាបង្កឱ្យប៉ះពាល់ដលធ្វើការប្រកបវិជ្ជាជីវៈរបស់ពួកគេ និងអាចបណ្តាលឱ្យពួកគេបាត់បង់វិជ្ជាជីវៈ ក៏ដូចជាបាត់បង់ចំណូលសម្រាប់ចិញ្ចឹមជិវិតរបស់ពួកគេជាដើម។ សម្រាប់តុលាការខ្មែរ ប្រហែលជាមិនទាន់ទទួលស្គាល់ការខូចខាតបែបនេះទេ តែសម្រាប់តុលាការបារាំងវិញបានទទួលស្គាល់ និងសម្រេចឱ្យមានការជួសជុលសំណងធ្លាប់បានធ្វើទៅហើយ។[61]

**ខ.ការអនុវត្តការទាមទារ**

ជនរងគ្រោះភាគច្រើនតែងតែធ្វើការទាមទារសំណងខូចខាត របស់ខ្លួនត្រលប់មកវិញនៅចំពោះមុខតុលាការ ប៉ុន្តែក៏មានជនរងគ្រោះមួយចំនួនមិនទាមទារឱ្យមានសំណងការខូចខាតនោះទេ។ ឧទាហរណ៍: តាមរយៈកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ គ ស្តីពីបទល្មើសរំលោភសេចក្តីទុកចិត្ត "ក្នុងពេលនេះនាងខ្ញុំសុំទាមទារប្រាក់ដើមចំនួន២៣០០ ដុល្លា និងមិនទាមទារបន្ថែមទេ"។

**១.២.ព្យសនកម្មរូបកាយ**

[60] សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក. និងអន្តរជាតិសម្រាប់បោះពុម្ពផ្សាយលើកទី១ នៅខែមិថុនា ឆ្នាំ២០១៤ ទំព័រ ១៣, រឿងក្តី ឌុច៖ សាលក្រម អ.វ.ត.ក អ.ជ.ស.ដ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌទី ៦៤១។

[61]សាយ បូរី, *នីតិរដ្ឋបាលទូទៅ*, ២០០៦, ៣៥៧។

ព្យសនកម្មរូបកាយនេះ គឺសំដៅលើព្យសនកម្មទាំងលើរូបកាយ និងសម្ភារៈ ជាព្យសនកម្មងាយស្រួលយល់ និងប៉ាន់ប្រមាណបានដោយអាចដឹងពីទំហំនៃព្យសនកម្ម ដែលអាចងាយស្រួលនៅក្នុងការធ្វើការជួសជុលព្យសនកម្មដែលកើតឡើងនោះ ប្រសិនជាប្រៀបធៀបព្យសនកម្មផ្នែកផ្លូវចិត្ត។

**ក.ការកំណត់អំពីព្យសនកម្មរូបកាយ**

ព្យសនកម្មលើរូបកាយ គឺជាកខូចខាត ឬការប៉ះពាល់ដែលធ្វើឱ្យមានរបួសស្នាម បាក់ខូចរាងកាយ ទោះជាធ្ងន់ស្រាលក៏ដោយ។ ព្យសនកម្មប្រភេទនេះ អាចធ្វើការវាយតម្លៃបានតាមរយៈការភ្ជាប់ឯកសារថ្លៃចំណាយនានា ឬលិខិតបញ្ជាក់អ្នកជំនាញបានដើម្បីអាចឱ្យតុលាការវិនិច្ឆ័យ ក៏ដូចជាវាយតម្លៃបាន។ ឧទាហរណ៍ៈ បទល្មើសបង្ករបួសស្នាម គឺជាព្យសនកម្មកើតឡើងលើរូបកាយជនរងគ្រោះ ហើយការកំណត់របួសធ្ងន់ ឬស្រាល គឺអាចប្រើប្រាស់ការធ្វើកោសលវិច័យ ដែលមានគ្រូពេទ្យជំនាញមកបញ្ជាក់ទំហំនៃការខូចខាត ឬតម្លៃទ្រព្យសម្បត្តិ។

**ខ. បញ្ហាខ្វះខាតការយកចិត្តទុកដាក់**

ជនរងគ្រោះមួយ ជាអនីតិជន និងមិនបានយល់ដឹងច្បាស់ ពីការបង្ហាញភស្តុតាងពាក់ព័ន្ធព្យសនកម្មនេះ។ ជាពិសេស ជនរងគ្រោះខ្លះមិនបានដាក់ឯកសារគ្រប់គ្រាន់សម្រាប់ចៅក្រម យកមកធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃជាភស្តុតាងនោះទេ ពីព្រោះថាជនរងគ្រោះមួយចំនួន គាត់មិនបានយល់ដឹងច្បាស់ពីសារៈសំខាន់នៃការយកភស្តុតាងមកដាក់។

**១.៣. ព្យសនកម្មផ្លូវចិត្ត**

ព្យសនកម្មផ្លូវចិត្ត ជាប្រភេទក្នុងការធ្វើការកំណត់សម្គាល់ និងអាចបង្ហាញឱ្យដឹងថាតើព្យសនកម្មបែបនេះស្ថិតក្នុងកម្រិតបែបណា និងគោរពតាមបទដ្ឋានណាដែរ ដើម្បីអាចយកជាមូលដ្ឋានដល់ចៅក្រមវាយតម្លៃបាន។ ដូចនេះវាទាមទារឱ្យមានការកំណត់ឱ្យបានជាក់លាក់ពីអ្នកជំនាញ និងអាស្រ័យទៅតាមកាលៈទេសៈនៅជុំវិញកត្តាដែលបណ្តាលឱ្យមានការខូចខាត។[62]

**ក.ប្រភេទនៃព្យសនកម្មផ្លូវចិត្ត**

ផ្លូវចិត្តអាចរួមបញ្ចូល វិល្លាសស្មារតី ឬជំងឺផ្លូវចិត្ត ឬសតិអារម្មណ៍របស់ជនរងគ្រោះដូចជាជំងឺបាក់ស្បាត ជាអាទិ៍។ សំណងជំងឺចិត្តក៏ចាត់ទុកជាការជួសជុលព្យសនកម្មផងដែរ គឺជាជួសជុលព្យសនកម្មខាងផ្លូវចិត្ត។ នៅពេលអំពើល្មើសមួយកើតឡើង វាមិនត្រឹមតែបង្កនូវគ្រោះថ្នាក់ និងខូចខាត

[62] ក្រមរដ្ឋប្បវេណី,នស/រកម១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៤០២។

ដល់រូបកាយ និងទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ឬគ្រួសារជនរងគ្រោះប៉ុណ្ណោះទេ តែក៏អាចបង្កជាវិបត្តិផ្នែកផ្លូវចិត្ត ដែលអាចបន្សល់ទុកដល់ជនរងគ្រោះក្នុងថ្ងៃមុខថែមទៀតផង។ សម្រាប់តុលាការបារាំងសម្រេចទទួលយល់ព្រមឱ្យមានសំណង ជាប្រាក់ដល់ព្យសនកម្មផ្លូវចិត្តដែលកើតពីទុក្ខលោក ទោះបីជាគ្មានការខូចខាតរូបកាយក៏ដោយ តែក៏អាចបង្កជាវិបត្តិផ្នែកផ្លូវចិត្ត ដែលអាចបន្សល់ទុកដល់ជនរងគ្រោះនៅក្នុងថ្ងៃមុខបន្ថែមទៀតផង។ សម្រាប់តុលាការបារាំង បានសម្រេចទទួលយល់ព្រមឱ្យមានសំណង ជាប្រាក់ដល់ព្យសនកម្មផ្លូវចិត្ត ដែលកើតពីទុក្ខសោក បើទោះជាគ្មានការខូចខាតផ្លូវកាយ ឬខូចខាតសម្ភារៈអ្វីមួយក៏ដោយ។[63] ការផ្តល់សំណងបែបនេះ ទំនងជាអាចធ្វើទៅបាន តែចំពោះអ្នកដែលមានទំនាក់ទំនងញាតិជាមួយជនរងគ្រោះ ឬដោយជនរងគ្រោះដោយផ្ទាល់នៃអំពើនោះ។

**ខ. របៀបនៃការទាមទារព្យសនកម្មផ្លូវចិត្ត**

ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែការបញ្ជាក់ និងដាក់ភស្តុតាងក្នុងការបង្ហាញពីការខូចខាត និងព្យសនកម្មផ្នែកសតិអារម្មណ៍មកលើខ្លួនឯង។ ប្រសិនជាជនរងគ្រោះមិនបានដាក់បន្ទុកភស្តុតាងគួរឱ្យជឿជាក់នោះទេ តុលាការនឹងធ្វើការសម្រេចសេចក្តីតាមកាលៈទេសៈជាក់ស្តែង។[64] ជាពិសេសបន្ទុកនៃភស្តុតាងផ្នែកផ្លូវចិត្តវាមានសារៈសំខាន់ណាស់ក្នុងការយកមកដាក់ជាបន្ទុកភស្តុតាង ហើយត្រូវមានការចូលរួមពីអ្នកជំនាញ ច្បាស់លាស់ដើម្បីយកមកពិចារណា។

**ឧទាហរណ៍:** បទល្មើសឆបោក គឺជនរងគ្រោះត្រូវតែបង្ហាញថា តើការត្រូវឆបោកមកលើខ្លួនមានការប៉ះពាល់ផ្លូវចិត្ត ថាខ្លួនទទួលរងការឈឺចាប់ ឬការបំពារបំពានបែបណាខ្លះ ទើបអាចឱ្យចៅក្រមយកមកធ្វើជាមូលដ្ឋាន ក្នុងការយកមកបង្កើតធ្វើការវាយតម្លៃផ្នែកចិត្តសាស្ត្របាន។

**២. ករណីមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង**

ការតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង គឺសំដៅដល់ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរដែលជាយន្តការថ្មី ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតឱ្យមានដើម្បីធានាការពារសិទ្ធិរបស់ជនរងគ្រោះដោយបទល្មើស។ ការតាំងខ្លួនជាដើមបណ្តឹងតាមផ្លូវបណ្តឹងនេះក្នុងករណីដែលស្ថិតក្នុងដំណាក់កាលបើកការស៊ើបសួរ របស់ចៅក្រមស៊ើបសួរភ្លាមនោះជនរងគ្រោះ ឬអ្នកដែលយល់ថាខ្លួនបានបាត់បង់ផលប្រយោជន៍ដោយសារអំពើជបទល្មើស

[63]សាយ បូរី, *នីតិរដ្ឋបាលទូទៅ*, ២០០៦, ៣៥៩។

[64] ក្រមរដ្ឋប្បវេណី,នស/រកម១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៥០២។

នោះដោយប្ដឹងនៅចំពោះមុខចៅក្រមស៊ើបសួរ។[65] បើកាលណាចៅក្រមស៊ើបសួរទទួលពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវអនុវត្តកាតព្វកិច្ចធ្វើការកត់សម្គាល់នូវពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមរយៈដីកា ហើយចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្ដឹងនេះទៅកាន់ព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរួចមក ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយដីកានេះ គឺអាចធ្វើឡើងប្រឆាំងនឹងអញ្ញាតជនទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចោទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។

ផងនោះដែរព្រះរាជអាជ្ញាអាចសុំឱ្យចៅស៊ើបសួរកុំស៊ើបសួរ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានរលត់ ឬប្រសិនអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ហើយនៅពេលដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយនៅក្នុងករណីដែលចៅក្រមស៊ើបសួរ នៅសម្រេចស៊ើបសួរវិញនោះ ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាដូចគ្នាដោយមានសំអាងហេតុ ជូនដំណឹងបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា។[66] ចំពោះការតាំងខ្លួនជាដើមបណ្ដឹងនេះ គឺត្រូវទាមទារឱ្យមានការបង់ប្រាក់តម្កល់ ដោយផ្អែកលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាននៃរឿងក្ដីដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់នេះផង។ ប្រសិនដើមបណ្ដឹងរដ្ឋប្បវេណីគ្មានលទ្ធភាពអាចបង់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះ។ ដោយដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីមានការបង់ប្រាក់តម្កល់ទុក ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃឱ្យដែលមានចុះហត្ថលេខាដោយប្រធានតុលាការព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ប្រសិនបើប្រាក់តម្កល់មិនត្រូវបានបង់នៅក្នុងរយៈពេល ដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្ដឹងមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។ ចៅក្រមរូបនេះ សម្រេចតាមដីកាដែលត្រូវជូនដំណឹងបន្ទាន់ទៅដើមបណ្ដឹងរដ្ឋប្បវេណី។

[65] ឯកសារជំនួយស្មារតីសម្រាប់ផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយៈ កើត រិទ្ធិ

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៩។

ដោយប្រាក់តម្កល់នេះត្រូវតម្កល់ទុកក្នុងគណនីពិសេស ដែលបើកនៅក្នុងធនាគារ ឬរក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ ដោយត្រូវជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា។ ប្រាក់តម្កល់នេះដែរ ត្រូវបង្វិលទៅសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី លើកលែងតែត្រូវអនុវត្តបណ្តឹងធ្វើឡើងដោយបំពាន ឬបណ្តឹងមានការអូសបន្លាយពេលវេលា។[67]

## ផ្នែកទី២ អំណាចស្រាវជ្រាវតាមដីកាចាត់ឱ្យស៊ើបសួរជំនួស

បើពិនិត្យមើលក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានពន្លេចឡើងនូវអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការធ្វើការស្រាវជ្រាវទៅលើដែនសមត្ថកិច្ចផ្សេង ក្រៅពីដែនសមត្ថកិច្ចរបស់ខ្លួនបានក្នុងនោះទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលមានចែងនៅក្នុង **ផ្នែកទី៨ ដីការចាត់ឱ្យស៊ើបសួរជំនួស នៃក្រមនីតិវិធីព្រហ្មទណ្ឌ។**

អ្វីទៅជា "**ដីកាចាត់ឱ្យស៊ើបសួរជំនួស**" ?

តាមរយៈដីការចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត ហើយក៏អាចចាត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរបានដែរ។[68] ក្នុងន័យនេះដែលជាលក្ខណៈទ្រឹស្តីអាចឱ្យអត្ថន័យបានថា ដីកាចាត់ឱ្យស៊ើបសួរជំនួស គឺជាការផ្ទេរនូវអំណាចស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចទៅ ចៅក្រមផ្សេង ឬ ចៅក្រមស៊ើបសួរដ៏ទៃទៀតឱ្យបំពេញកិច្ចស្រាវជ្រាវបទល្មើសជួសខ្លួន គឺផ្តល់ទាំងសិទ្ធនិងកាតព្វកិច្ចដែលខ្លួនប្រើប្រាស់ទាំងអស់ដូចគ្នា។ ដីការចាត់ឱ្យស៊ើបសួរជំនួសត្រូវបានធ្វើឡើងជាពីរបែបគឺ៖ ដីកាចាត់ឱ្យស៊ើបសួរជំនួសទៅចៅក្រមស៊ើបសួរផ្សេង និង ដីកាចាត់ឱ្យស៊ើបសួរជំនួសចាត់តាំងឱ្យមន្ត្រីនគរបាលយុត្តិធម៌។

### កថាខណ្ឌទី១ ការចាត់តាំងចៅក្រមផ្សេងឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរ ដែលកំពុងបំពេញសំណុំរឿងក្តី ដែលមាននៅក្នុងដៃខ្លួនហើយយល់ឃើញថា មានភាពចាំបាច់សម្រាប់ធ្វើកិច្ចអ្វីមួយ ដើម្បីបំភ្លឺនូវអង្គហេតុ ឬភាពសង្ស័យរបស់ខ្លួន ប៉ុន្តែខ្លួនមិនអាចចុះទៅដោយផ្ទាល់បានដោយសារតែកាលៈទេសៈ ឬស្ថានភាពក្នុងការធ្វើដំណើរពិបាក និងត្រូវចំណាយក្នុងការចុះទៅទីកន្លែងឆ្ងាយៗពីទីកន្លែងបទល្មើស។ ដោយហេតុផលទាំងនេះចៅក្រមស៊ើបសួរអាចពឹងពាក់ចៅក្រមផ្សេងឬ មន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើកិច្ចការជំនួសខ្លួនបានតាមរយៈដីកា

[67]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១៩១។
[68] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១៧៣។

ចាត់ឱ្យសើុបសួរជំនួស។ ក្នុងដីការចាត់ឱ្យសើុបសួរជំនួសដោយមានការចាត់តាំងចៅក្រមផ្សេងឱ្យប្រតិបត្តិការជំនួសនេះត្រូវបានបែងចែកជាពីរផងដែរ៖ ការចាត់តាំងចៅក្រមនៅសាលាដំបូងដែលមានសមត្ថកិច្ច និងការចាត់តាំងចៅក្រមនៃសាលាដំបូងផ្សេងទៀត។ ក្នុងការចាត់តាំងចៅក្រមដែលមានសមត្ថកិច្ចនៅសាលាដំបូងដូចគ្នា ឬចៅក្រមផ្សេងដែលពុំស្ថិតនៅក្នុងសាលាដំបូងតែមួយតើមានលក្ខណៈដូចគ្នា ឬខុសគ្នាយ៉ាងណាហើយសិទ្ធនឹងកាតាព្វកិច្ចត្រូវតម្រូវដូចគ្នាយ៉ាងដូចម្តេចដែរ។ ទាំងអស់នេះយើងនឹងធ្វើការបកស្រាយ ក៏ដូចជាលើកយកមកបង្ហាញទៅលើការចាត់តាំងចៅក្រម ឬមន្ត្រីនគរបាលយុត្តិធម៌នៃចំណុចទាំងពីរនេះឱ្យបានក្បោះក្បាយ។

### ១. ការចាត់តាំងចៅក្រមនៅសាលាដំបូងដែលមានសមត្ថកិច្ច

នៅក្នុងសាលាដំបូងរាជធានី-ខេត្ត នីមួយៗមានចៅក្រមដែលបំពេញការងារជាច្រើនរូបដើម្បីដោះស្រាយនូវវិវាទ ក៏ដូចជាបង្ក្រាបនូវបទល្មើសដែលកើតឡើង។ ចៅក្រមសើុបសួរក្រោយពីបានសិក្សាទៅលើសំណុំរឿងរបស់ខ្លួនហើយនោះ ខ្លួនយល់ឃើញថានូវមានការសង្ស័យ ឬពុំច្បាស់លាស់ទៅលើភស្តុតាងដើម្បីដាក់បន្ទុក ឬដោះបន្ទុកណាមួយ នោះការចាត់តាំងចៅក្រមសាលាដំបូងដែលខ្លួនកំពុងស្ថិតនៅជាមួយគ្នា អាចធ្វើទៅបានដោយសារតែមានភាពចាំបាច់ក្នុងករណីដែលខ្លួនមិនអាចបំពេញកិច្ចការស្រាវជ្រាវនោះបាន។ ក្នុងនោះដែលឃើញថាការចេញនូវដីកាចាត់ឱ្យសើុបសួរជំនួសនេះទៅចៅក្រមដែលនៅក្នុងសមត្ថកិច្ចសាលាដំបូងជាមួយខ្លួននោះ ចៅក្រមសើុបសួរដែលជាអ្នកកាន់សំណុំរឿងត្រូវចេញដីកាដោយមានបញ្ជាក់អំពីប្រភេទ នៃកិច្ចសើុបសួរឱ្យច្បាស់លាស់នឹងជាក់លាក់តាមការណែនាំដែលចាត់ទៅឱ្យចៅក្រមដែលជំនួសខ្លួននោះដើម្បីធ្វើកិច្ចនោះបន្តតាមអំណាច នៃដីកាចាត់ឱ្យសើុបសួរជំនួសនេះផងដែរ។

**ឧទាហរណ៍៖** ក្នុងករណីចៅក្រមសើុបសួរធ្វើការចេញដីកាចាត់ឱ្យសើុបសួរជំនួស ទៅលើការធ្វើកំណត់ហេតុសួរចម្លើយ និងការចាត់ឱ្យចេញដីកាបង្គាប់ឱ្យចូលខ្លួនទៅចៅក្រមម្នាក់ទៀតជាអាទ៏។ នេះមានន័យថាចៅក្រមសើុបសួរដែលទទួលនូវដីកានេះត្រូវអនុវត្តតែអំណាចធ្វើកំណត់ហេតុសួរចម្លើយ និង បង្គាប់ឱ្យចូលខ្លួនតែប៉ុណ្ណោះ។

កាលណាដីកាចាត់ឱ្យសើុបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនេះអាចប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមសើុបសួរ។[69] ដីការចាត់ឱ្យសើុបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទ

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៥។

ប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមាន លក្ខណៈជាទូទៅទេ ត្រូវតែណែនាំឱ្យបានច្បាស់លាស់។

ចៅក្រមស៊ើបសួរកំណត់ថិរវេលាដែលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។

ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ នឹងមានបោះត្រាផង។

ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេល។[70] ក្នុងស្មារតីនេះ ចង់បង្ហាញឱ្យឃើញនូវការប្រើប្រាស់នូវអំណាចជំនួស គ្នាទៅវិញទៅមករវាងចៅក្រមស៊ើបសួរ នឹងចៅក្រមផ្សេងដែលនៅក្នុងសាលាដំបូងតែមួយប៉ុន្តែមិនមែនប្រើប្រាស់ទៅតាមអំពើចិត្តឡើយ គឺធ្វើស្របទៅតាមការកំណត់ដែលមាននៅក្នុងដីកាដែលចាត់ឱ្យស៊ើបសួរជំនួសនោះ ស្របទៅតាមច្បាប់នីតិវិធីព្រហ្មទណ្ឌដែលផ្តល់ឱ្យ។ ក្នុងនោះដែលបើពិនិត្យលើក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ជាក់ឱ្យកាត់តែច្បាស់ទៀតថាការអនុវត្តខ្លឹមសារនៃដីកានេះ គឺចៅក្រមស៊ើបសួរដែលទទួលការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសគឺប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដូចទៅនឹង ចៅក្រមស៊ើបសួរដែលជាអ្នកទទួលនូវសំណុំរឿងនោះផ្ទាល់ផងដែរ។

**២. ការចាត់តាំងចៅក្រមសាលាដំបូងផ្សេងទៀត**

ការចាត់តាំងចៅក្រមនៅសាលាដំបូងផ្សេងនេះ គឺស្របពេលដែលស្ថិតនៅក្នុងកាលៈទេសៈដែលចៅក្រមស៊ើបសួរដែលជាអ្នកទទួលបន្ទុកសំណុំរឿងពិបាកក្នុងការ ធ្វើចំណាត់ការទៅលើការស្រាវជ្រាវស្វែងរកនូវភាពពិតរបស់អង្គហេតុដែលខ្លួនបានសិក្សារ ដោយសារតែជនត្រូវចោទពុំមានវត្តមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬអាចនិយាយបានថាដោយសារបទល្មើសកើតឡើងនៅលើដែនសមត្ថកិច្ចនៃសាលាដំបូងផ្សេងបែបនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាបានរំលិចឡើងនូវយន្តការថ្មីនេះឡើងដើម្បីស្វែងរកឱ្យឃើញនូវភាពពិតប្រាកដ និងផ្តល់នូវភាពយុត្តិធម៌ទៅដល់ជនរងគ្រោះ ថែមទាំងជនត្រូវចោទផងដែរ។ ស្របទៅតាមខ្លឹមសារនូវដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ គឺមានលក្ខខណ្ឌក្នុងការអនុវត្តអំណាចដូចគ្នាទៅ នឹងការចាត់តាំងទៅតាមដីកាឱ្យស៊ើបសួរជំនួសដែលចេញឱ្យចៅក្រមនៅសាលាដំបូងដូចគ្នានោះ ដែលបានបកស្រាយខាងលើផងដែរ។ **ឧទាហរណ៍៖** ចៅក្រមស៊ើបសួរនៅសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យចៅក្រមនៅសាលាដំបូងខេត្តកណ្តាល ឱ្យបំពេញកិច្ច កោសលវិច័យ ធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង និងធ្វើការស្តាប់ចម្លើយសាក្សីជាអាទ៍។

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៤។

## កថាខណ្ឌទី២ ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យស៊ើបសួរជំនួស

យើងបានដឹងហើយថា មន្ត្រីនគរបាលយុត្តិធម៌គឺជាជំនួយរបស់អំណាចតុលាការ។ ក្នុងនោះដែលមន្ត្រីនគរបាលមានតួនាទីក៏ដូចជាភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនល្មើសផងដែល។ បើយើងពិនិត្យឱ្យកាន់តែស៊ីជម្រៅ យើញថាវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ពិតជាមានសារៈសំខាន់ណាស់ នៅគ្រប់ដំណាក់កាលទាំងអស់ក្នុងរឿងព្រហ្មទណ្ឌ។ គ្រាន់តែថាភារកិច្ច នឹងអំណាចត្រូវបានកំណត់ជាក់លាក់នៅក្នុងដំណាក់កាលដីមួយៗ គឺថានៅដំណាក់កាលអយ្យការមន្ត្រីនគរបាលមានតួនាទីផ្សេង នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរមន្ត្រីនគរបាលយុត្តិធម៌មានតួនាទីផ្សេង និងមិនតែប៉ុណ្ណោះនៅក្នុងដំណាក់កាលជំនុំជម្រះមន្ត្រីនគរបាលយុត្តិធម៌មានតួនាទីផ្សេងផងដែល។ តាមតម្រូវការជាក់ស្តែងដើម្បីភាពងាយស្រួលក្នុងការស្រាវជ្រាវបទល្មើសមួយផ្នែកនោះ ចៅក្រមស៊ើបសួរច្រើនតែចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យបំពេញកិច្ចស្រាវជ្រាវណាមួយតាមលិទ្ធភាពដែលមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើទៅបាន។ យ៉ាងណាមិញក្នុងន័យនេះ យើងនឹងធ្វើការបកស្រាយតែទៅលើតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានលើភារកិច្ចរបស់គាត់ ដែលត្រូវចាត់ឱ្យដោយចៅក្រមស៊ើបសួរតាមដីកាចាត់ឱ្យស៊ើបសួរជំនួសតែប៉ុណ្ណោះ។

### ១. ការចាត់តាំងមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងនៅក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ។

ចំពោះការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរនេះតែប៉ុណ្ណោះ។[71] ក្នុងការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការជំនួស ទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសគឺហាក់ដូចជាមានភាពល្អិតល្អន់ជាង ពីព្រោះថាមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ធ្វើការបំពេញភារៈកិច្ចរបស់ខ្លួនពេលនេះ គឺស្ថិតក្នុងការបង្គាប់បញ្ជារបស់ចៅក្រមស៊ើបសួរជាអ្នកកំណត់អំពីសិទ្ធិដែលខ្លួនត្រូវធ្វើទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសនេះផងដែរ ត្រង់ចំណុចនេះចង់បង្ហាញថាមន្ត្រីនគរបាលយុត្តិគឺជាជំនួយរបស់ចៅក្រមស៊ើបសួរ។ មិនតែប៉ុណ្ណោះយើងឃើញថាចៅក្រមស៊ើបសួរគឺខ្លួនអាចចាត់តាំងតែចំពោះមន្ត្រីនគរបាល ឬអង្គភាពនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចពាក់

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៦។

ព័ន្ធឱ្យធ្វើការស្រាវជ្រាវ ក៏ដូចជាប្រតិបត្តិការជំនួសខ្លួនផង ដែលទាក់ទងទៅនឹងការពន្លាតសមត្ថកិច្ចក្នុងការស្រាវជ្រាវនេះក៏ អាចធ្វើបានដែលប្រសិនបើចៅក្រមស៊ើបសួរគិតថាមានភាពចាំបាច់ក្នុងការស្វែងរកតម្រុយនូវ ភស្តុតាងដើម្បីបញ្ជាក់នូវភាពពិត។ មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ និងទី ៣ មាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ។[72] អ្វីដែលសំខាន់សម្រាប់ការចេញនូវដីការឱ្យស៊ើបសួរជំនួស ដែលចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ធ្វើដែលស្ថិតនៅក្រោមការកំណត់ដោយដីកានេះ នឹងក្រោមអំណាចរបស់ចៅក្រមស៊ើបសួរដែលអាចនិយាយបានថា ជាបញ្ជាដាច់ខាត់ដោយដីកាចាត់ឱ្យស៊ើបសួរជំនួសចេញឱ្យមន្ត្រីនគរបាលយុត្តិធម៌។

## ២. ប្រតិបត្តិការតាមការចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

នៅក្នុងការប្រតិបត្តិការ ក៏ដូចជាការអនុវត្តទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ គឺមានការចង្អុលបង្ហាញយ៉ាងច្បាស់លាស់ និងជាក់លាក់ទៅលើបុគ្គល ទីកន្លែងដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅស្រាវជ្រាវ ដោយមានការចុះនូវនិទ្ទេសដោយចៅក្រមស៊ើបសួរដែលបានចេញដីកានោះ។ ក្នុងនោះដែលយើងឃើញថា ការប្រតិបត្តិការនេះ មានដូចជា ការធ្វើកំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យ, វិធានទាក់ទងនឹងការស្តាប់ចម្លើយ, ការឆែកឆេរ និងការចាប់យក, ការឃាត់ខ្លួននៅក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស, ការស្តាប់ទូរស័ព្ទជាអាទ៍។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។[73] ក្នុងនោះដែលយើងឃើញថា ទាក់ទងទៅនឹងការស្តាប់ចម្លើយដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ គឺធ្វើទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ ក្នុងនោះដែលបើយើងពិនិត្យទៅលើក្រមនីតិវិធិព្រហ្មទណ្ឌយើង គឺផ្តល់នូវសិទ្ធិអំណាចតែទៅតាមការបង្គាប់បញ្ជារបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ ចំពោះការស្តាប់ចម្លើយសាក្សីដែលចៅក្រមស៊ើបសួរបានឱ្យស្តាប់ចម្លើយជំនួសអាចធ្វើការកោះហៅសាក្សី ឱ្យចូលមកចំពោះមុខខ្លួនបាន តែក្នុងករណីរឹងទទឹងមិនព្រមចូលខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំបញ្ជាឱ្យចូលខ្លួន ចំពោះមុខចៅក្រមស៊ើបសួរបាន។ ករណីដែលស្តាប់ចម្លើយរបស់សាក្សីណាមួយហើយបានលេចឡើងតម្រុយពិរុទ្ធភាពលើជននោះគឺត្រូវបញ្ឈប់និងរាយការណ៍ជាបន្ទាន់ដល់ចៅក្រមស៊ើបសួរ។ ចំពោះវិធានការនៃការស្រាវជ្រាវ ក៏ដូចជាការអនុវត្ត

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៧។

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៧៨។

របស់មន្ត្រីនគរបាលយុត្តិធម៌ គឺអនុវត្តទៅតាមបទប្បញ្ញត្តិរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមានចែង នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

**ផ្នែកទី៣ អំណាចស្រាវជ្រាវតាមការស្នើសុំ**

ទាក់ទងទៅនឹងអំណាចនេះផងដែលយើងឃើញថា នៅពេលដែលកំពុងធ្វើការស្រាវជ្រាវទៅលើការតាមដាន ក៏ដូចជាការសិក្សារទៅលើសំណុំរឿង ដើម្បីស្វែងរកភស្តុតាងមកធ្វើការវិនិច្ឆ័យទៅលើការចោទប្រកាន់តាមដីកាដំណោះស្រាយគួរតែលើកលែងបទចោទប្រកាន់ ឬបញ្ជូនជននោះទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ។ ក្នុងនោះដែលយើងឃើញថានៅពេលដែលកំពុងធ្វើការបើកការស៊ើបសួរភាគីក៏ដូចជា ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចណាមួយដែលខ្លួនយល់ឃើញគួរតែធ្វើដើម្បីបង្ហាញភាពពិត និងមិនតែប៉ុណ្ណោះក៏អាចស្នើសុំឱ្យបំពេញកិច្ចណាមួយដែលចៅក្រមស៊ើបសួរពុំបានធ្វើ ឬ ក៏ចៅក្រមពុំចាប់អារម្មណ៍ថាកិច្ចនេះសំខាន់ ដូច្នេះភាគីដែលពាក់ព័ន្ធអាចស្នើសុំទៅចៅក្រមស៊ើបសួរ ឱ្យបំពេញកិច្ចទាំងនេះដែលក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិឱ្យ។ ក្នុងនោះដែលបើពិនិត្យទៅលើក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ទៅលើបុគ្គល ដែលអាចស្នើសុំឱ្យបំពេញកិច្ចបានក្នុងនោះគឺមាន ដូចជាព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

**កថាខណ្ឌទី១ ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា**

នៅក្នុងរឿងព្រហ្មទណ្ឌព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ក៏ជាគូរក្តីដើមនៅពេលសវនាជាដែលខ្លួនជាអ្នកធានាសណ្តាប់ធ្នាប់សាធារណៈ ជាអ្នកប្តឹងសុំឱ្យមានការអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ បើពិនិត្យមើលនៅក្នុងដំណាក់កាលស៊ើបសួរយើងឃើញថាព្រះរាជអាជ្ញាមានវត្តមានគ្រប់ពេលក្នុងការតាមដាននូវរាល់សកម្មភាពរបស់ចៅក្រមស៊ើបសួរក្នុងពេលប្រតិបត្តិការនីតិវិធីស្រាវជ្រាវបទល្មើស ហើយក៏អាចពិនិត្យមើលសំណុំរឿងគ្រប់ពេលវេលាបានផងដែរ។ ព្រះរាជអាជ្ញាអាចមានវត្តមាននៅក្នុងគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ និងក្នុងការស្តាប់ចម្លើយ។[74] នៅគ្រប់ពេលវេលាព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងស៊ើបសួរ ឬ ស្នើសុំឱ្យបញ្ជូនសំណុំរឿងមកពិនិត្យ ប៉ុន្តែត្រូវមានភារៈកិច្ចបង្វិលសំណុំរឿងនេះទៅវិញ នៅក្នុងថេរវេលា ២៤(ម្ភៃបួន) ម៉ោង។[75] ដោយសារតែព្រះរាជអាជ្ញាមានវត្តមាន និងទំនាក់ទំនង នៅគ្រប់កិច្ចស៊ើបសួរនេះហើយទើបធ្វើឱ្យព្រះរាជអាជ្ញាអាចស្វែងរកការពិតបន្ថែមទៀត ក៏ដូចជាការស្វែងរកនូវភស្តុតាងដាក់បន្ទុកទៅតាមការស្នើសុំឱ្យបំពេញទៅចៅក្រម

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៦។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៣៥។

ស៊ើបសួរ។ ចំពោះការស្នើសុំឱ្យបំពេញកិច្ចនេះទៀតសោត ព្រះរាជអាជ្ញាត្រូវតែគោរពនូវគោលការណ៍ដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលជាលក្ខខណ្ឌក្នុងស្នើសុំឱ្យបំពេញកិច្ច។

**១. លក្ខខណ្ឌក្នុងការស្នើសុំ**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ នោះចៅក្រមរូននេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថេរវេលាយ៉ាងឆាប់បំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[76] ដោយចៅក្រមស៊ើបសួរជាចៅក្រមឯករាជ្យមិនចំណុះឱ្យស្ថាប័នអយ្យការ បែបនេះ ហើយនៅពេលដែលមានការស្នើសុំឱ្យបំពេញកិច្ចរបស់ព្រះរាជអាជ្ញាមិនចងកាតាព្វកិច្ចរបស់ចៅក្រមស៊ើបសួរនោះទេ នៅពេលមានការស្នើសុំនេះចៅក្រមស៊ើបសួរគឺអាចពិចារណាថាគួរឬមិនគួរក្នុងរយៈពេល១៥ថ្ងៃ។

មិនតែប៉ុណ្ណោះក្នុងបទប្បញ្ញត្តិនៃមាត្រា ១៣២ ក៏បង្ហាញឱ្យឃើញនូវផ្លូវប្តឹងទៅនាយហានានុក្រមរបស់ចៅក្រមស៊ើបសួរនៅពេលដែលចៅក្រមស៊ើបសួរមិនបានធ្វើសកម្មភាព ឬជាការមិនបំពេញនូវកិច្ចដែលបានស្នើសុំពីព្រះរាជអាជ្ញា នោះព្រះរាជអាជ្ញាត្រូវប្តឹងទៅសភាស៊ើបសួរដើម្បីធ្វើការសម្រេចថាគួរមានកិច្ចតាមការស្នើសុំនេះ ឬអត់ដោយសម្រេចជំនួសចៅក្រមស៊ើបសួរ។ មិនតែប៉ុណ្ណោះទៀតសោតព្រះរាជអាជ្ញា ក៏អាចស្នើសុំឱ្យបំពេញកិច្ចនៅពេលដែលចៅក្រមស៊ើបសួរបិទការស៊ើបសួរ ដោយតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាបានផងដែរ។ ប្រសិនបើព្រះរាជអាជ្ញាខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា១៣២ (ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនេះ។[77]

**២. ការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចបដិសេធ**

បើពីនិត្យទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាបានបើកផ្លូវឱ្យព្រះរាជអាជ្ញាប្តឹងទៅលើការបដិសេធរបស់ចៅក្រមស៊ើបសួរនៅពេល ដែលមានការស្នើសុំឱ្យបំពេញកិច្ចហើយចៅក្រមស៊ើបសួរមិនធ្វើតាមការស្នើសុំនោះ ដូច្នេះហើយព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ទៅលើដីកាសម្រេចនោះបានគ្រប់ពេល។ ទោះបីជាយ៉ាងណាក៏ដោយយើងពិនិត្យតែលើការ ប្តឹង

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣២។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៤៦។

មោឃភាពទៅជាន់សាលាឧទ្ធរណ៍នៅក្នុងរឿងព្រហ្មទណ្ឌគឺឃើញថាមាន យុត្តាធិការសភាស៊ើបសួរ និងយុត្តាធិការត្រួតពិនិត្យ។ យុត្តាធិការសភាស៊ើបសួរគឺមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យទៅលើការប្តឹងសុំមោឃភាពចំពោះតែកិច្ចប្រតិបត្តិការស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ ចំណែកឯយុត្តាធិការត្រួតពិនិត្យវិញចង់សំដៅទៅលើសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ទៅលើកិច្ចនីតិវិធីក្នុងការកំណត់អំពីនិយ័តភាព នៃកិច្ចនីតិវិធីក្នុងការប្តឹងទៅឧទ្ធរណ៍ទៅលើកិច្ចនីតិវិធីណាមួយនូវរាល់គ្រប់ដំណាក់ការនីតិវិធីព្រហ្មទណ្ឌ ចំពោះការអនុវត្តមិនស្របទៅនិងនីតិវិធីព្រហ្មទណ្ឌ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរ។[78] បទប្បញ្ញត្តិនៃមាត្រា ២៦៦ គឺចង់បង្ហាញចំពោះការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរគឺព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអាចប្តឹងទៅសាលាឧទ្ធរណ៍ ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលចំពោះដីកាបដិសេធមិនបំពេញកិច្ចដែលបានស្នើសុំឱ្យបំពេញកិច្ចនោះផងដែរ។

### កថាខណ្ឌទី២ ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

មិនត្រឹមតែព្រះរាជអាជ្ញាទេដែលអាច ស្នើសុំទៅចៅក្រមស៊ើបសួរឱ្យបំពេញកិច្ចក្នុងនោះដែលក៏យើងឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានផ្តល់សិទ្ធិឱ្យជនត្រូវចោទក្នុងការស្នើសុំទៅចៅក្រមស៊ើបសួរឱ្យបំពេញកិច្ចបន្ថែមដែលខ្លួនយល់ឃើញអាចផ្តល់នូវភាពពិតដល់ខ្លួនផងដែរ។

#### ១. លក្ខខណ្ឌក្នុងការស្នើសុំ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងថេរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

ប្រសិនបើចៅក្រមស៊ើបសួរមិននបានសម្រេចក្នុងថិរវេលា ១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[79] បើពិនិត្យទៅលើបញ្ញត្តិនេះ គឺចង់បង្ហាញឱ្យឃើញនូវលក្ខខណ្ឌដែល ជនត្រូវចោទអាចធ្វើការស្នើសុំឱ្យចៅក្រមស៊ើបសួរ បំពេញនូវកិច្ចមួយចំនួនដែលខ្លួនយល់ឃើញថាអាចផ្តល់នូវភាពពិត នៃអង្គហេតុក៏ដូចជាស្នើសុំទៅ

---

[78]ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ២៦៦។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ១៣៣។

ចៅក្រមស៊ើបសួរឱ្យជួយបំពេញកិច្ចមួយចំនួនដែលចៅក្រមស៊ើបសួរមិនបានធ្វើ ដែលជាហេតុអាចផ្តល់ផលប្រយោជន៍នៅក្នុងសំណុំរឿងរបស់ខ្លួនផ្ទាល់ ព្រោះថាចៅក្រមស៊ើបសួរជាអ្នកស្វែងរកបន្ទុកនូវភស្តុតាង។

### ២. ការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចបដិសេធ

នៅពេលដែលមានការស្នើសុំទៅចៅក្រមស៊ើបសួរ ធ្វើឡើងក្នុងការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទហើយនោះចៅក្រមស៊ើបសួរមានថេរវេលា ១ខែ ក្នុងការមិនព្រមធ្វើតាមពាក្យសុំដែលជនត្រូវចោទបានធ្វើទៅឱ្យខ្លួន បន្ទាប់ពីទទួលពាក្យសុំ។ មិនតែប៉ុណ្ណោះទៀតសោត ក៏ផ្តល់នូវការប្តឹងនូវការមិនបំពេញកិច្ចនេះ ជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរចំពោះការមិនធ្វើកិច្ចនេះផងដែរ។ ក្នុងនោះដែលឃើញថានៅពេលដែលចៅក្រមស៊ើបសួរ មិនព្រមធ្វើកិច្ចដែលខ្លួនសុំនោះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធដែលត្រូវជូនដំណឹងនេះទៅព្រះរាជអាជ្ញា និងជនត្រូវចោទផងដែរ។ ចំពោះពាក្យប្តឹងនេះផងដែលជាការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ។ ជនត្រូវចោទអាចប្តឹងឧទ្ធណ៍ចំពោះដីកាដូចខាងក្រោម[80]:

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា ១៣៣ (ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ)

-ដីកាមិនព្រមប្រគល់វត្ថុដែលចាប់ឱ្យទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬសុំឱ្យធ្វើប្រតិកោសលវិច័យដូចដែលមានចែងក្នុងកថាខណ្ឌទី៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ) និង

-ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលមានចែងក្នុងផ្នែកទី ៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងផ្នែកទី៧ ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃជំពូកទី៣ ស្តីពីវិធានការណ៍និរន្តរាយ ក្នុងមាតិកាទី១ នៃគន្ថីនេះ និងមាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ។ ចំពោះបទប្បញ្ញត្តិនៃមាត្រានេះយើងឃើញថា ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរតែចំពោះតែដីកាណាដែលប៉ះពាល់ទៅនឹងផលប្រយោជន៍ផ្ទាល់ខ្លួនតែ

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧,មាត្រា ២៦៧។

ប៉ុណ្ណោះ ទាក់ទងទៅនឹងបញ្ហានេះទៀតសោតយើងឃើញថា ចំពោះដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ក៏ជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បានផងដែលនៅពេលដែលគ្រប់ថេរវេលានៃការប្តឹងសុំខាងលើ។

**កថាខណ្ឌទី ៣ ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី**

ដូចជាបានបកស្រាយខាងពីរចំណុចខាងលើដែលទាក់ទងនឹង ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា និងជនត្រូវចោទរួចហើយថា ក្រមនីតិវិធីព្រហ្មទណ្ឌយើងបានផ្តល់សិទ្ធិឱ្យមានការសុំឱ្យបំពេញកិច្ចនេះព្រោះអាចនិយាយបានថាដោយសារពេលខ្លះការបំពេញ នូវកិច្ចប្រតិបត្តិការនីតិវិធីដែលធ្វើ របស់ចៅក្រមស៊ើបសួរអាចនឹង មានការភ្លាំងភ្លាត់ដោយសារកាលៈទេសៈ ឬក៏បញ្ហាណាមួយដែលចៅក្រមស៊ើបសួរមិនបានធ្វើ។ ក្នុងនោះដែលយើងឃើញថាដើមបណ្តឹងរដ្ឋប្បវេណីក៏មានសិទ្ធិក្នុងការស្នើសុំឱ្យបំពេញកិច្ចបានផងដែរ។

**១. លក្ខខណ្ឌក្នុងការស្នើសុំ**

នៅគ្រប់ពេវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសុំដល់ចៅក្រមស៊ើបសួរឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទសួរតទល់គ្នា ឬ ចុះទៅទីកន្លែង។ ពាក្យសុំត្រូវជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងថេរវេលា ១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថេរវេលា ១(មួយ) ខែទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[81] ចំពោះបទប្បញ្ញត្តិនៃមាត្រានេះក៏មិនខុសពីការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា និងជនត្រូវចោទផងដែលមិនតែប៉ុណ្ណោះឃើញថា ចំពោះការបដិសេធមិនព្រមបំពេញកិច្ចចៅក្រមស៊ើបសួរ ត្រូវតែសម្រេចក្នុងរយៈពេលដែលច្បាប់កំណត់ដើម្បីជាផ្លូវក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទៅលើដីកាបដិសេធនេះដោយដើមបណ្តឹងរដ្ឋប្បវេណី។

**២. ការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចបដិសេធ**

ចំពោះការប្តឹងឧទ្ធរណ៍នេះផងដែលយើងឃើញថា គឺជាការផ្តល់នូវសិទ្ធិក្នុងការប្តឹងតវ៉ាទៅលើការមិនសុខចិត្តចំពោះការសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងការសម្រេចបដិសេធ ចំពោះកិច្ច

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៤។

ដែលខ្លួនស្នើសុំ ដែលសិទ្ធិនេះទៀតសោតគឺជាការធ្វើនូវបណ្ដឹងតាមរបៀបរបបដែលក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ[82] ៖

– ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៤(ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី)

– ដីកាមិនព្រមស៊ើបសួរដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា)

– ដីកាកំនត់ចំនួនប្រាក់កក់ ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក)

– ដីកាប្រកាសមិនទទួលពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ

– ដីកាផ្ដន្ទាទោសដើមបណ្ដឹងរដ្ឋប្បវេណី ដូចមានចែងក្នុងមាត្រា ១៤១ (បណ្ដឹងដោយបំពាន ឬបណ្ដឹងដោយអូសបន្លាយពេល)

– ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យក ទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)

– ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ)

– ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬសុំឱ្យធ្វើប្រតិកោសលវិច័យដូចដែលមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្ដីសន្និដ្ឋាននៃកោសលវិស័យ)

– ដីកាដំណោះស្រាយដូចដែលមានចែងក្នុងមាត្រា ២៤៧ (ដីកាដំណោះស្រាយ) នៃក្រមនេះ។

ចំពោះដីកាទាំងអស់នេះគឺជាដីកាដែលបើកផ្លូវឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះដីកាទាំងឡាយដែលបានរៀបរាប់ខាងលើនៅពេលខ្លួនមិនសុខចិត្តទៅ នឹងសម្រេចក្នុងការចេញនូវដីការបស់ចៅក្រមស៊ើបសួរ ម្យ៉ាងវិញទៀតយើងឃើញថាទាក់ទងទៅនឹងដីកាដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ក៏ឃើញថាមានការធ្វើបណ្ដឹងឧទ្ធរណ៍ទៅនឹងការសម្រេចនៃដីកានេះផងដែលនេះគឺជាការផ្ដល់នូវផលប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដែលចៅក្រមស៊ើបសួរបដិសេធទៅលើពាក្យសុំឱ្យបំពេញកិច្ចដែលខ្លួនបានស្នើសុំនោះផងដែរ។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៦៨។

# សេចក្តីសន្និដ្ឋាន

ជារួមមកវិញ ចំពោះការស្រាវជ្រាវមួយនេះត្រូវបានផ្តោតសំខាន់ទៅលើកិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ ក៏ដូចជាសិទ្ធិអំណាចដែលទទួលបាននៅពេលដែលមានការដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងនៅពេលដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះជាដើម។ អ្វីដែលសំខាន់បំផុតនៅក្នុងដំណើរការនីតិវិធីនេះ គឺការស្រាវជ្រាវស្វែងរកការពិតនៃអង្គហេតុដែលជារឿងព្រហ្មទណ្ឌ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាធានាឱ្យបាននូវជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋនៅក្នុងសង្គមទាំងមូលក្នុងការស្វែងរកយុត្តិធម៌ មានតម្លាភាព និងធានាបាននូវសមភាពក្នុងការទទួលបាននូវសេវាយុត្តិធម៌គ្មានការប្រកាន់នូវ អ្នកមានអ្នកក្រ ឋានៈតួនាទី កម្រិតសិក្សារៀនសូត្រនោះទេ។

ចំណុចនេះហើយ បានធ្វើឱ្យចៅក្រមស៊ើបសួរ មានតួនាទីសំខាន់មួយត្រង់ថា ប្រព័ន្ធចៅក្រមស៊ើបសួរជាប្រព័ន្ធមួយ ដែលស្ថិតនៅចន្លោះកណ្តាលនៃដំណាក់កាលផ្តើមចោទប្រកាន់របស់ព្រះរាជអាជ្ញាក្នុងការស៊ើបអង្កេតដោយនគរបាលយុត្តិធម៌ និងដំណាក់កាលចៅក្រមជំនុំជម្រះ។ មានន័យថាចៅក្រមស៊ើបសួរប្រៀបដូចជាស្នូលនៃកិច្ចនីតិវិធីរបស់តុលាការព្រហ្មទណ្ឌ ដោយចៅក្រមស៊ើបសួរជាតួអង្គម្នាក់ដែលស្ថិតនៅកណ្តាល ដែលមានភាពឯករាជ្យដែលច្បាប់ប្រគល់ឱ្យដោយមិនលម្អៀងទៅរកភាគីណាម្ខាងឡើយនៃរឿងក្តី ចំពោះកាតព្វកិច្ចរបស់គាត់ គឺស្រាវជ្រាវទៅលើភស្តុតាងទាំងឡាយ រួមមានភស្តុតាងដាក់បន្ទុក និងដោះបន្ទុកនៃរឿងព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរ ក៏ត្រូវធ្វើកិច្ចស្រាវជ្រាវដោយផ្អែកចម្បងលើមូលដ្ឋានច្បាប់ និងការវិនិច្ឆ័យលើភាពសមហេតុផលប្រកបដោយយុត្តិធម៌ស្របតាម គុណធម៌ សីលធម៌ និងវិជ្ជាជីវៈ ដើម្បីភាពសាកសមជាអ្នកស្វែងរកយុត្តិធម៌ពិតប្រាកដជូនសង្គម។ មួយវិញទៀត ចៅក្រមស៊ើបសួរ មិនមែនសុទ្ធតែតម្រូវធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនោះទេ គឺនៅក្នុងករណីមួយនៅកំពុងដំណើរការនៃកិច្ចនីតិវិធីស្រាប់តែចៅក្រមស៊ើបសួរគាត់រកឃើញនូវភស្តុតាងថ្មីដែលត្រឹមតែជាស្ថានទម្ងន់ទោសនៃបទល្មើសនៃបទល្មើស ដែលព្រះរាជអាជ្ញាចោទតាមរយៈដីកា។

ក្រោយមកបន្ទាប់ពី ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ដោយពិនិត្យនូវតម្រុយពិរុទ្ធភាពរបស់ជនល្មើស ភស្តុតាងដែលបានប្រមូលបាន និងស្ថានភាពមួយខ្លួនយល់ថាដែលអាចបង្ហាញនូវការពិតបានហើយនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាមួយ ហៅថាដីកាដំណោះស្រាយបញ្ចប់កិច្ចនីតិវិធី។

# ឯកសារយោង


- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ចក សម្បត្តិ.២០១៧. *ការដាក់ឲ្យស្ថិតក្រោមការពិនិត្យខ្លឹមសារនៃប្រព័ន្ធចៅក្រម. ស៊ើបសួរ.* ភ្នំពេញ។
- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។
- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត.២០១៧. មេរៀននីតិវិធិព្រហ្មទណ្ឌ។
- សាយ បូរី.២០០៦.*នីតិរដ្ឋបាលទូទៅ.* ភ្នំពេញ។
- អង្គការសហប្រជាជាតិសិទ្ធិមនុស្សកម្ពុជា.២០១៤. *សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក. និងអន្តរជាតិ* ភ្នំពេញ៖ អង្គការសហប្រជាជាតិសិទ្ធិមនុស្សកម្ពុជា។
- ឯកសារជំនួយស្មារតីការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ កើត រិទ្ធ។
- អ៊ុន បូផា. ២០១៦. *នីតិភស្តុតាង.* ភ្នំពេញ។

# អនុសាសន៍

ដើម្បីជាការផ្តល់ជាគំនិតក្នុងគោលបំណងរួមមួយ គឺធ្វើយ៉ាងណាឱ្យប្រព័ន្ធការស្រាវជ្រាវក៏ដូចជាសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការស្វែងរកការពិតនេះ ឱ្យប្រកបដោយភាពសុក្រិត្យ តម្លាភាព សមភាព និងធានាបានឱ្យមានភាពជឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋទាំងឡាយទូទាំងប្រទេស ក៏ដូចជាធានាបាននូវភាពស្អាតស្អំរបស់ស្ថាប័នតុលាការដែលផ្តល់នូវសេវាយុត្តិធម៌នេះ គឺជាចាំបាច់ដោយមើលតាមស្ថានភាពជាក់ស្តែង បង្ហាញឱ្យឃើញចៅក្រមស៊ើបសួរត្រូវបានចាត់តាំងដោយប្រធានតុលាការផ្ទាល់ ដោយធ្វើការជ្រើសយកចៅក្រមអាសនៈនៃតុលាការដើម្បីធ្វើកិច្ចស៊ើបសួរនេះ ហើយករណីខ្លះដែលចៅក្រមស៊ើបសួរត្រូវបានចាត់តាំងនោះ មិនអាចបំពេញនូវភារកិច្ចស៊ើបសួរដោយ ហេតុជំងឺ ឬការចាំបាច់ណាមួយ គឺត្រូវចាត់តាំងចៅក្រមអាសនៈផ្សេងទៀត មកជំនួសក្នុងការបំពេញកិច្ចស៊ើបសួរនេះ។

តាមរយៈការអនុវត្តកន្លងមក បានបញ្ជាក់ឱ្យឃើញបានថានៅមានភាពមិនទាន់ល្អប្រសើរនៅឡើយ ចំពោះការចាត់តាំងចៅក្រមស៊ើបសួរនេះ ដើម្បីជាជំនួយឱ្យប្រព័ន្ធស៊ើបសួរមានភាពល្អប្រសើរនោះ គួរតែនៅគ្រប់តុលាការដំបូងត្រូវមានមន្ទីស៊ើបសួរមួយច្បាស់លាស់ ដែលបំពេញភារកិច្ចតែរឿងស៊ើបសួរមួយតែប៉ុណ្ណោះជាសមត្ថកិច្ចដាច់ដោយឡែក។ ម្យ៉ាងវិញទៀតជៀសវាងក្នុងការលាយឡំគ្នារវាងចៅក្រមដែលស្ថិតនៅក្នុងយុត្តាធិការជំនុំជម្រះ និងយុត្តិធិការស៊ើបសួរ ដោយតួនាទីនៅក្នុងការស៊ើបសួរនេះ ជារឿងមួយសំខាន់ណាស់ដើម្បីឱ្យការស្រាវជាវស្វែងរកភាពពិតនៃអង្គហេតុនៃរឿងព្រហ្មទណ្ឌមួយ ដើម្បីសម្រេចនូវគោលដៅរកឱ្យឃើញនូវជនល្មើសពិតប្រាកដ ជៀសវាងការផ្តន្ទាទោសខុសលើជនសុច្ចរិត ដោយជារឿងមួយចាំបាច់ត្រូវមានការគិតគូរពិចារណាក្នុងការវិនិច្ឆ័យឱ្យបានស៊ីជម្រៅរបស់ចៅក្រមស៊ើបសួរ។ កាតព្វកិច្ចក្នុងការស៊ើបសួរមិនត្រូវមានការថ្លោះធ្លោយឡើយ ដែលវាសំខាន់ណាស់តម្រូវឱ្យចៅក្រមស៊ើបសួរមានសមត្ថភាពខាងផ្នែកទ្រឹស្តីច្បាប់ និងបច្ចេកទេសខាងផ្នែកចិត្តសាស្ត្រ ក៏ដូចជាយុត្តិសាស្ត្រក្នុងការប្រតិបត្តិការនូវកិច្ចរបស់ចៅក្រមស៊ើបសួរផងដែរ។ ដូច្នេះហើយទើបតម្រូវឱ្យមានការបណ្តុះបណ្តាលជំនាញបច្ចេកទេសនៃកិច្ចស្រាវជ្រាវដល់ចៅក្រមស៊ើបសួរ ធានាបានថាតុលាការមានប្រព័ន្ធស៊ើបសួររឹងមាំច្បាស់លាស់។ កាលណាប្រព័ន្ធស៊ើបសួររឹងមាំនិងស្ថិតនៅក្នុងភាពដែលជាជំហរច្បាស់លាស់ហើយនោះ ទើបការស៊ើបសួរប្រកបដោយភាពកក់ក្តៅសម្រាប់ភាគីដែលមកពឹងពាក់តុលាការដើម្បីស្វែងរកយុត្តិធម៌ជូន

ខ្លួន។ មិនតែប៉ុណ្ណោះធ្វើឱ្យសេចក្តីសម្រេចមួយរបស់តុលាការប្រកបដោយភាពត្រឹមត្រូវ ដែលផ្តល់នូវសាលក្រមមួយប្រកបដោយប្រសិទ្ធភាពរឹងមាំតាមផ្លូវច្បាប់។

ជាចុងក្រោយ ក្នុងការលើកឡើងនូវអនុសាសន៍ខាងលើនេះគឺមានគោលបំណងតែម្យ៉ាងគត់ គឺដើម្បីធ្វើឱ្យប្រព័ន្ធស៊ើបសួររបស់ប្រទេសកម្ពុជាយើងមានភាពស្អង់ដា ដែលមិនស្ថិតក្នុងការតិះដៀលពីប្រជាពលរដ្ឋដើម្បីជាសេចក្តីទុកចិត្តលើស្ថាប័នតុលាការដែលជាស្ថាប័នអំណាចមួយក្នុងអំណាចទាំងបីនៃការដឹងនាំប្រទេស។

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យស្នើសុំបញ្ជូលសាក្សី</u>

ខ្ញុំបាទឈ្មោះ ... អាយុ ៣៥ឆ្នាំ មានអាស័យដ្ឋាននៅផ្ទះលេខ ... ផ្លូវលំ ក្រុម ២ ភូមិខ្វរ សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ ....

ខ្ញុំបាទឈ្មោះ ... អាយុ ៣៥ឆ្នាំ មានអាស័យដ្ឋាននៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិព្រែកលាប សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ ...

ខ្ញុំបាទឈ្មោះ ... អាយុ ៥៩ឆ្នាំ មានអាស័យដ្ឋាននៅផ្ទះលេខ ... ផ្លូវលំ ក្រុម ២ ភូមិព្រែកលាប សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ ...

**<u>សូមគោរពជូន</u>**

**លោក ... ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** សំណើសុំបញ្ជូនសាក្សីចំនួន ០៣នាក់។

**យោង:** -សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥។

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ពួកយើងខ្ញុំបាទសូមគោរព **លោកចៅក្រម** មេត្តាជ្រាបថា កាលពីថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ នៅចំណុចក្រុម ២ ភូមិព្រែកលាប សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មានករណីហិង្សាមួយបានកើតឡើង ហើយពួកយើងខ្ញុំបានទទួលដំណឹងភ្លាម ក៏ចុះទៅអន្តរាគមន៍ យកជនរងគ្រោះទៅមន្ទីរពេទ្យ តែត្រូវបានជនរងគ្រោះប្តឹងពួកយើងខ្ញុំទៅវិញ ថាប្រើអំពើហិង្សាទៅលើពួកគេទៅវិញ ដូច្នេះពួកសុំជូនសំអាងជាសាក្សីមានឈ្មោះដូចខាងក្រោម:

១.ឈ្មោះ ... ភេទប្រុស អាយុ ៣៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រែកលាប សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ...

២.ឈ្មោះ ... ភេទប្រុស អាយុ ៣៨ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រែកលាប សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ...

៣.ឈ្មោះ ... ភេទប្រុស អាយុ ៥២ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រៃកលាប សង្កាត់ព្រៃកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ...

អាស្រ័យហេតុនេះ សូម **លោកចៅក្រម** មេត្តាទទួលយកសាក្សីបំភ្លឺដោយក្តីអនុគ្រោះ។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីពួកយើងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

## <u>ដីកាកោះ</u>

យើង ... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ...
ចុះថ្ងៃទី ២៣-០៤-២០១៨

| | | |
|---|---|---|
| អញ្ជើញឈ្មោះ | : | .... ភេទស្រី អាយុ ៥០ឆ្នាំ |
| ជា | : | ដើមបណ្តឹង |
| ទូរស័ព្ទលេខ | : | .... |
| អាស័យដ្ឋាន | : | ផ្ទះលេខ... ផ្លូវលេខ៣៦៣ ភូមិកណ្តាល សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ |
| ឲ្យចូលទៅកាន់ | : | **សាលាដំបូងរាជធានីភ្នំពេញ បន្ទប់** "..." |
| នៅថ្ងៃទី | : | **០៨ ខែឧសភា ឆ្នាំ២០១៨** |
| វេលាម៉ោង | : | **៨:៣០ ព្រឹក** |
| ដើម្បី | : | សាកសួរ |
| ពីដំណើររឿង | : | **ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅមុខផ្ទះលេខ... ផ្លូវលេខ៣៦៣ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨ |

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

## <u>កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ</u>

(មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

សំណុំរឿងព្រហ្មទណ្ឌ
លេខ ...
ចុះថ្ងៃទី២៦-០២-២០១៦
សំណុំរឿងស៊ើបសួរ
លេខ ...
ចុះថ្ងៃទី....-....-....

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងដប់ប្រាំមួយដប់នាទី

លោក .... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បានមកបង្ហាញខ្លួនក្នុងនាមជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានសញ្ញាណដូចខាងក្រោម:

នាមត្រកូល ... នាមខ្លួន ... ហៅ ... ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ មុខរបរ គ្មាន ទីកន្លែងកំណើតនៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ មានអាស័យដ្ឋាននៅផ្ទះលេខ ... ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ..."..." ម្តាយឈ្មោះ ... "..." នៅលីវ ជាអនីតិជន។

អ្នកបកប្រែឈ្មោះ ................ អាសយដ្ឋាននៅ ..........................................................................

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនគ្មានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិការផ្តន្ទាទោសដោយតុលាការ គ្មាន

☐ជននេះ៖ ☐ចេះនិយាយ ☐ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

☐ជននេះ៖ ☐មិនចេះនិយាយ ☐មិនេចះអាន ☐មិនេចះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ... **អ.យ.ថ. ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៦**។

ដែលជាហេតុនាំឲ្យជននេះ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ និង ☐ការឃុំខ្លួនបណ្តោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ..........................................................................................

ជនត្រូវចោទអមដោយលោកស្រី ... ជាមេធាវីការពារក្តីឲ្យជនត្រូវចោទ។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា៖

**សួរ-ឆ្លើយ:** ចំពោះកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ នៅចំពោះមុខសមត្ថកិច្ច និងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ នៅចំពោះមុខតំណាងអយ្យការ ខ្ញុំសុំទទួលស្គាល់ទាំងស្រុងដដែល។

**សួរ-ឆ្លើយ:** កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ វេលាម៉ោង ៦ល្ងាច ខ្ញុំ និងឈ្មោះ ... បានជិះម៉ូតូម៉ាក Smash Revo ស៊េរីឆ្នាំ ២០១៣ ពណ៌ក្រហម ជាកម្មសិទ្ធិរបស់គេដែលយកមកដាក់បញ្ចាំខ្ញុំ ទៅដើរនៅកោះពេជ្រ ពេលទៅដល់កោះពេជ្រ ក៏ជួបឈ្មោះ ... ហៅ ... , ឈ្មោះ ... និងឈ្មោះ ... ដែលជាអ្នកស្គាល់គ្នា ហើយជិះម៉ូតូដើរលេងជុំវិញកោះពេជ្រ លុះដក់ម៉ោង ១២រំលងអាធ្រាត ឈានចូលថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ពួកខ្លួនទាំង ០៥នាក់ បានចេញពីកោះពេជ្រវិញ ដោយបានរៀបគំរោងកាប់យកម៉ូតូរបស់គេតាមផ្លូវ ហើយខ្លួន និងឈ្មោះ ... ជិះម៉ូតូពីមុខម៉ូតូរបស់ឈ្មោះ ... ហៅ..., ឈ្មោះ ... និងឈ្មោះ ... ពេលធ្វើដំណើរដល់មុខសាលារៀនបឹងត្របែក ខ្លួនឃើញជនរងគ្រោះចំនួន ០២ ជិះម៉ូតូ ZUSUKI LET`S ស៊េរីឆ្នាំ ២០១៥ ពណ៌ស ខ្លួនក៏ទាញកាំបិទកាប់ទៅជនរងគ្រោះ បណ្តាលឲ្យដួលម៉ូតូ ហើយជនរងគ្រោះរត់ចោលម៉ូតូ ពេលនោះឈ្មោះ ... រត់ទៅលើកម៉ូតូរបស់ជនរងគ្រោះជិះគេចខ្លួន តែមិនដឹងវាយកម៉ូតូទៅលក់ឬអត់ទេ។

**សួរ-ឆ្លើយ:** លុះមកដល់ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបានតែម្តងពេលខ្លួនកំពុងសម្រាក់នៅផ្ទះ។

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណាត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☐បាននអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោងដប់ប្រាំមួយកន្លះ នាថ្ងៃខែឆ្នាំដូចខាងលើ។

**ជនត្រូវចោទ អ្នកបកប្រែ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# លិខិតអញ្ជើញមេធាវី

យើង ... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ....

ចុះថ្ងៃទី ០៨-៩-២០១៥

| | | |
|---|---|---|
| បានឃើញ | : | ពាក្យការពារក្តី ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨ របស់ លោកមេធាវី ... និង លោកស្រីមេធាវី ... ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ .... |
| អញ្ជើញមេធាវី | : | លោក .... និង ... |
| ទូរស័ព្ទលេខ | : | ....... |
| ការិយាល័យ | : | **ការិយាល័យមេធាវី** ផ្ទះលេខ... ផ្លូវបេតុង សង្កាត់ទួលសង្កែ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| ឲ្យចូលទៅកាន់ | : | **សាលាដំបូងរាជធានីភ្នំពេញ បន្ទប់** "..." |
| នៅថ្ងៃទី | : | **២៩ ខែ ធ្នូ ឆ្នាំ ២០១៥** |
| វេលាម៉ោង | : | **១៤ : ៣០ រសៀល** |
| ដើម្បី | : | ចូលរួមស្តាប់ការសាកសួរកូនក្តី |
| ពីដំណើររឿង | : | **មិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ** ប្រព្រឹត្តនៅដីលេខ ... ផ្លូវលេខ ... សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៥ |

សាមីខ្លួនត្រូវអញ្ជើញតាមលិខិតអញ្ជើញនេះឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ .... ត.ព្រ

# <u>ដីកាបង្គាប់ឲ្យនាំជនត្រូវចោទទៅកាន់សាលាដំបូងរាជធានីភ្នំពេញ</u>

## យើង .... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

ជម្រាបមក **ប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ)** ឲ្យនាំជនត្រូវចោទក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ដូចមានឈ្មោះខាងក្រោមទៅកាន់ **សាលាដំបូងរាជធានីភ្នំពេញ** បន្ទប់ស៊ើបសួរ "..." **នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥ វេលាម៉ោង ៨ : ៣០ ព្រឹក** ដើម្បី: **សួរចម្លើយ។**

| **ល.រ** | **នាមត្រកូល-នាមខ្លួន** | **ភេទ** | **អាយុ** | **ថ្ងៃខែឆ្នាំ ឃុំខ្លួន** | **បទល្មើស** |
|---|---|---|---|---|---|
| ០១ | ... ហៅ ... ហៅ ... | ប្រុស | ៤១ឆ្នាំ | បន្ទប់លេខ ... នៃពន្ធនាគាររាជធានីភ្នំពេញ (PJ) | ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅបន្ទប់ឃុំខ្លួនលេខ ... និងលេខ ... នៃពន្ធនាគាររាជធានីភ្នំពេញ (PJ) ស្ថិតនៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៥ |
| ០២ | ... ហៅ .... | ប្រុស | ៤០ឆ្នាំ | បន្ទប់លេខ ... នៃពន្ធនាគាររាជធានីភ្នំពេញ (PJ) | រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅបន្ទប់ឃុំខ្លួនលេខ ... និងលេខ ... នៃពន្ធនាគាររាជធានីភ្នំពេញ (PJ) ស្ថិតនៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៥ |

យើង ...................... ប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ) សូមបញ្ជាក់ថា ឈ្មោះខាងលើនេះពិតជាជាប់ឃុំនៅពន្ធនាគាររបស់យើងប្រាកដមែន ហើយយើងនឹងចាត់បញ្ជូនជននេះឲ្យទាន់ពេលវេលា តាមការកំណត់របស់តុលាការ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "..."

ខ ............... "" ដ.ព.ស

# <u>ដីកាសម្រេចបញ្ចូលសំណុំរឿង</u>

យើង ... ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ... អ.យ.ធ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ... អ.យ.យ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ពាក្យសុំបញ្ចូលសំណុំរឿង ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់លោកមេធាវី ... ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ... ភេទស្រី អាយុ ៣៥ឆ្នាំ។

## <u>សំអាងហេតុ</u>

១.តាមពាក្យសុំបញ្ចូលសំណុំរឿង ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់លោកមេធាវី ... ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ ... បានបញ្ជាក់ថា៖

ក.សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ តាមពាក្យបណ្តឹង ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ ... បានប្តឹងកូនក្តីខ្លួនឈ្មោះ ... ថាបានក្លែងឯកសារនៅក្នុងពាក់កណ្តាលខែ វិច្ឆិកា ឆ្នាំ ២០១៥ ក្រោយចំណាត់ការរបស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងមហាផ្ទៃ ក្រោយមកកូនក្តីខ្លួនត្រូវបានឃាត់ខ្លួន ហើយបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បន្ទាប់មកទៀតកូនក្តីខ្លួនត្រូវបានអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ផ្តើមចោទប្រកាន់ពីបទ **ក្លែងបន្លំឯកសារ** និង **លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅចំណុចភូមិទឹកល្អក់ ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្ត

កំពង់ស្ពឺ កាលពីថ្ងៃទី ០១ , ០៣ ខែ មករា ឆ្នាំ ២០១៤ និងឆ្នាំ ២០១៦ តាមមាត្រា ៦២៦ , ៦២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល ហើយបញ្ជូនកូនក្តីខ្លួន ព្រមទាំងសំណុំរឿងមកថៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ... អ.យ.យ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ កូនក្តីខ្លួនត្រូវបានថៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន តាមរយៈដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ... "..." ដ.យ.ដ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦

ខ.សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ តាមពាក្យបណ្តឹង ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៦ របស់ឈ្មោះ ...... បានប្តឹងកូនក្តីខ្លួនឈ្មោះ .... ថាបានលួចយកឯកសាររបស់ក្រុមហ៊ុននៅក្នុងអំឡុងខែ វិច្ឆិកា ឆ្នាំ ២០១៥ ក្រោយចំណាត់ការរបស់លោក ហ៊ឹង ប៊ុនថន ព្រះរាជអាជ្ញារង នៃអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចោទប្រកាន់ពីបទ **ក្លែងបន្លំ** និង **ប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៦ តាមមាត្រា ៦២៦ , ៦២៧ , ៦២៨ នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ... អ.យ.ធ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៧

ដោយពិនិត្យឃើញថា សំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ និងសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ មានហេតុ និងបច្ច័យទាក់ ទងគ្នាគ្រប់អង្គហេតុទាំងអស់ គឺដើមបណ្តឹងតែម្នាក់គឺឈ្មោះ ...... ប្តឹងលើឈ្មោះ .... តែម្នាក់ ដែលមានអង្គហេតុពាក់ព័ន្ធទៅនឹងលិខិត ចំនួន ០២ គឺកំណត់ហេតុប្រជុំ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ និងលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៤ ដែលតំណាងអយ្យការសន្មត់ថាកូនក្តីខ្លួនជាអ្នករៀបចំក្លែងឯកសារទាំង ០២ ខាងលើ។ ដូច្នេះដើម្បីងាយស្រួលដល់ការស៊ើបសួរ ក៏ដូចជាការចោទប្រកាន់ ជាន់គ្នាលើអង្គហេតុតែមួយមកលើកូនក្តីខ្លួន ខ្លួនស្នើសុំដល់លោថៅក្រមស៊ើបសួរមេត្តាពិនិត្យ និងសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ និងសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦។

២. ការស្នើសុំបញ្ចូលសំណុំរឿងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ មានមូលហេតុច្បាស់ លាស់ដែលអាចឲ្យតុលាការធ្វើការពិចារណាបាន ។

៣. ដើម្បីដំណើរការនីតិវិធីនៃរឿងក្តីនេះឲ្យបានឆាប់រហ័ស គប្បីសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌទាំង ០២ ឲ្យទៅជាសំណុំរឿងតែមួយ។

## <u>ហេតុដូច្នេះសម្រេច</u>

បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

## កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

សំណុំរឿងព្រហ្មទណ្ឌ
លេខ ....
ចុះថ្ងៃទី២៦-០២-២០១៦
សំណុំរឿងស៊ើបសួរ
លេខ ...
ចុះថ្ងៃទី....-....-....

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងដប់ប្រាំមួយ

លោក .... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បានមកបង្ហាញខ្លួនក្នុងនាមជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានសញ្ញាណដូចខាងក្រោមៈ

នាមត្រកូល ... នាមខ្លួន .... ហៅ ... ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ មុខរបរ គ្មាន ទីកន្លែងកំណើតនៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ មានអាស័យដ្ឋាននៅផ្ទះលេខ .... ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ... "..." ម្តាយឈ្មោះ .... "..." នៅលីវ ជាអនីតិជន។

តើអ្នកឯងចេះអាន និងចេះសរសេរភាសាខ្មែរដែរ និងនិយាយភាសាខ្មែរ ឬទេ? ចេះ

ជននេះត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅមុខសាលារៀនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោកស្រីមេធាវី .... ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញនៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយ នឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូង។

យើងបានប្រាប់ដល់ជនត្រូវចោទថាៈ

-យើងមានបំណងសម្រេចឃុំខ្លួន ជនត្រូវចោទជាបណ្តោះអាសន្ន។

-ជនត្រូវចោទអាចស្នើសុំពន្យាពេល ដើម្បីរៀបចំការពារខ្លួន។

-យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ។

ជនត្រូវចោទបានប្រកាសប្រាប់ថាៈ ខ្ញុំបាទមិនទទួលយកការចោទប្រកាន់របស់តំណាងអយ្យការ។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទង និងការឃុំខ្លួនបណ្តោះអាសន្នៈ

ត្រូវបានធ្វើ

ត្រូវបានលើកទៅថ្ងៃទី.... ខែ.......ឆ្នាំ...........តាមសំណូមពររបស់ ..........................................

តំណាងអយ្យការបានបង្ហាញនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ

.....................................

.........................................................................................................................................................

.........................................................................................................................................................

.........................

ស្នើសុំឃុំខ្លួនជាបណ្តោះអាសន្ន និងឲ្យតុលាការដំណើរការតាមនីតិវិធី ។

ជនត្រូវចោទបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ

.....................................................

.........................................................................................................................................................

.............

លោកស្រីមេធាវី .... បានបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ ស្នើសុំឲ្យចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនកូនក្តី ដោយក្តីអនុគ្រោះ។

□យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ។

□យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

□យើងបានអានស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

□បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

**អ្នកបកប្រែ ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

សាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង**

(មាត្រា ១៤៣ មាត្រា ១៤៤ មាត្រា ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

សំណុំរឿងព្រហ្មទណ្ឌ
លេខ ....
ចុះថ្ងៃទី២៦-០២-២០១៦

សំណុំរឿងស៊ើបសួរ
លេខ ...
ចុះថ្ងៃទី....-....-....

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងដប់ប្រាំហាសិបនាទី

លោក .... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល .... នាមខ្លួន .... ហៅ ... ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ មុខរបរ គ្មាន ទីកន្លែងកំណើតនៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ មានអាសយដ្ឋាននៅផ្ទះលេខ ... ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ... "..." ម្តាយឈ្មោះ ... "..." នៅលីវ ជាអនីតិជន។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ប្រវត្តិការផ្តន្ទាទោសដោយតុលាការ ៖ គ្មាន

☐ជននេះ ចេះនិយាយ ចេះអាន ចេះសរសេរអក្សរខ្មែរ

☐ជននេះ មិនចេះនិយាយ មិនចេះអាន មិនេចះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ .... **អ.យ.ច ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៦** ដែលជាហេតុនាំឲ្យមានការបង្ហាញជននេះនៅចំពោះមុខយើងព្រមទាំងប្រាប់ជននេះឲ្យដឹងអំពីបទចោទប្រកាន់ចំពោះ រឿងរ៉ាវដូចខាងក្រោម៖

ពីបទ **លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅមុខសាលារៀនបឹងត្របែក សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងរ៉ាវដែល យើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់។

□លោកស្រី .... មេធាវី នៃជនត្រូវចោទ ហើយដើម្បីឲ្យលោកមេធាវីអាចត្រៀមរៀបចំការពារកូនក្តីខ្លួនបាន

យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យគេចាត់តាំងមេធាវីណាម្នាក់ឲ្យរូបគាត់។

យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូប នឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

+ជននេះ បានប្រកាសប្រាប់ថា៖

□ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

□ខ្ញុំអាចស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

□ខ្ញុំសុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដលើជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬអាចធ្វើសេចក្តីប្រកាស ផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន។

ជននេះបានប្រកាសប្រាប់ថា ខ្ញុំបាទអាចឆ្លើយជូនតុលាការបានជុំវិញករណីចោទប្រកាន់ដោយមានវត្តមានរបស់លោកមេធាវី ចូលរួមស្តាប់ផងដែរ ។

លោកស្រីមេធាវី .... បានផ្តល់សេចក្តីកត់សម្គាល់ការពារថា៖ ស្នើសុំឲ្យចៅក្រមស៊ើបសួរជួយជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ៖

ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង។

ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះ អំពីឈ្មោះ នៃបទល្មើសគឺបទ

..........................................................................................................................................។

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឲ្យយើធ្វើកិច្ចការស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹង សុំមោឃភាព នៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាន នៃមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍ តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុង ពេល នៃដំណើរការ នៃការស៊ើបសួរ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ នឹងបើសិនជាមានសំណើ

សុំយើងនឹងចាត់តាំងមេធាវីមួយរូប ជូន(សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ)។

+ជននេះបានប្រកាសប្រាប់ថា៖

☐ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☐ខ្ញុំបដិសេធជំនួយពីមេធាវី

☐យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះ យើងសម្រេចដាក់គាត់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវ តុលាការ និងប្រាប់គាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេច ឃុំខ្លួនជាបណ្តោះអាសន្ន។

☐យើងបានប្រាប់ដល់ ជនត្រូវចោទថា៖

គាត់ត្រូវប្រកាសប្រាប់ពីអាសយដ្ឋានដែលអាចជាអាសដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឲ្យគាត់ ប្រសិនបើគាត់អាចផ្តល់ឲ្យភ្លាមនូវការព្រមព្រៀងជាលាយ ល័ក្ខណ៍អក្សររបស់តតិយជននោះ។

អាសយដ្ឋានដែលត្រូវប្រកាសត្រូវមានទីតាំងស្ថិតនៅ

.....................................................................

ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោម៖

☐អាសយដ្ឋាននេះ ជាអាសយដ្ឋានផ្ទាល់ខ្លួន។

☐អាសយដ្ឋាននេះ ជាអាសយដ្ឋានរបស់ ...................................................................................។

☐យើងបានប្រកាសដល់ជនត្រូវចោទបន្ថែម៖

រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋាន ដែលបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ។

គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសដ្ឋាន ដែលបានប្រកាសប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ ទុលថា ជូនដំណឹងដល់បុគ្គលជនត្រូវចោទ។

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

□យើងបានអានស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។

| | | | | |
|---|---|---|---|---|
| **អ្នកបកប្រែ** | **ជនត្រូវចោទ** | **មេធាវី** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
បន្ទប់ស៊ើបសួរ "..."
លេខ ................ "..." ព្រ

# លិខិតជូនដំណឹង
## <u>ដល់តំណាងអយ្យការ</u>

យើង .... ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ .... អ.យ.ន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចចោទប្រកាន់លើៈ

១.ឈ្មោះ .... ភេទប្រុស អាយុ ១៩ឆ្នាំ

ពីបទ **លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៧ តាមបញ្ញត្តិមាត្រា៣៥៣ និង៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**ជម្រាបមកលោកតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៧ យើងធ្វើការស៊ើបសួរចប់តាមនីតិវិធីហើយ។

នោះយើងសម្រេច **បិទការស៊ើបសួរ**។

<u>បានទទួលដំណឹង</u> រាជធានីភ្នំពេញ, ថ្ងៃទី ........ ខែ កក្កដា ឆ្នាំ ២០១៧ រាជធានីភ្នំពេញ, ថ្ងៃទី ......... ខែ កក្កដា ឆ្នាំ ២០១៧ **ចៅក្រមស៊ើបសួរ**

**តំណាងអយ្យការ**

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "..."

លេខ ................ "..." ព្រ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតជូនដំណឹង ឬ ព័ត៌មានបិទការស៊ើបសួរ
## <u>ដល់តំណាងអយ្យការ</u>

យើង .... ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ .... អ.យ.ន ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចចោទប្រកាន់លើឈ្មោះ ... ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ តាមមាត្រា ៣៩១ , ៣៩២ នៃក្រមព្រហ្មទណ្ឌ។

### ជម្រាបមកលោកតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥ យើងធ្វើការស៊ើបសួរចប់តាមនីតិវិធីហើយ។

នោះយើងសម្រេច **បិទការស៊ើបសួរ**។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ចៅក្រមស៊ើបសួរ**

<u>**បានទទួលដំណឹង**</u>

រាជធានីភ្នំពេញ, ថ្ងៃទី ......... ខែ កុម្ភៈ ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ.....................ដ/ប២០១៤

# ដីកាបញ្ជូន

## គោរពជូន តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | សំរង់សេចក្ដីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤។ | ០២ ច្បាប់ | "ដើម្បីមេត្តាជួយ អនុវត្តតាមនីតិវិធី" |
| | | | |

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រមជំនុំជម្រះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ.....................ដ/ប២០១៤

**ដីកាបញ្ជូន**

**គោរពជូន ប្រធានពន្ធនាគារខេត្តកណ្ដាល**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | សំរង់សេចក្ដីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤។ | ០២ ច្បាប់ | "ដើម្បីមេត្តាជួយ អនុវត្តតាមនីតិវិធី" |
| | | | |

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រមជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ....................ដ/ប២០១៥

# ដីកាបញ្ជូន

**គោរពជូន ឯកឧត្តម មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជា មេបញ្ជាការ កងរាជអាវុធហត្ថ រាជធានីភ្នំពេញ**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ ................. ត.ព្រ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ | ០២ច្បាប់ | "ដើម្បីអនុវត្តតាមនីតិវិធី" |
| | | | |

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥

**ចៅក្រមស៊ើបសួ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ .............................. ជ.ប

# ដីកាបញ្ជូន

**គោរពជូន លោកប្រធានមន្ទីររៀបចំដែនដី**
**នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | -លិខិតលេខ ៣១៣៨ ព្រ.ទ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ | ០២ច្បាប់ | "ដើម្បីអនុវត្ត" |
| | | | |

ចៅក្រមស៊ើបសួរ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ .............................. ដ.ប

## ដីកាបញ្ជូន

**គោរពជូន ឯកឧត្តម នាយកមន្ទីរប្រឆាំងគ្រឿងញៀន**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១<br><br><br><br>០២ | -ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ .................................. ត.ព្រ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។<br><br>-លិខិតអញ្ជើញ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ | ០២ច្បាប់<br><br><br><br>០២ច្បាប់ | "ដើម្បីអនុវត្ត" |
| | | | |

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ .............................. ដ.ប

## ដីកាបញ្ជូន

### គោរពជូន ឯកឧត្តម នាយកមន្ទីរប្រឆាំងគ្រឿងញៀន

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | -លិខិតលេខ .................... "រ" រ.ប ចុះថ្ងៃទី ...... ខែ មករា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ | ០២ច្បាប់ | "ដើម្បីអនុវត្ត" |
| | | | |

រាជធានីភ្នំពេញ, ថ្ងៃទី ......... ខែ មករា ឆ្នាំ ២០១៦

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ................................. ជ.ប

**ដីកាបញ្ជូន**

**គោរពជូន លោកប្រធាន សាលាដំបូងខេត្តកណ្ដាល**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាកោះ ចុះថ្ងៃទី ........... ខែ កក្កដា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ | ០៣ច្បាប់ | "ដើម្បីមេត្តាជួយអនុវត្តតាមនីតិវិធី" |
| | | | |

រាជធានីភ្នំពេញ, ថ្ងៃទី ......... ខែ កក្កដា ឆ្នាំ ២០១៦

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ ............................. ដ.ប

## ដីកាបញ្ជូន

## គោរពជូន ឯកឧត្តម ព្រះរាជអាជ្ញា នៃអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ............................. ត.ព្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ។ | ០៣ច្បាប់ | "ដើម្បីអនុវត្ត" |
| ០២ | -ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ............................. ត.ព្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ របស់ចៅក្រមជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ។ | ០៣ច្បាប់ | |

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥

**ចៅក្រមជំនុំជម្រះ**